សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ការលែងលះរវាងសហព័ន្ធខ្មែរ

( ស្រាវជ្រាវចាប់ពីថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០២៤ ដល់ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២៤ )

ស្រាវជ្រាវដោយ ៖

និស្សិតឈ្មោះ លោក **ទ៉ា ទណ្ណា** | ណែនាំដោយ

លោក **អឿ ដាវីត** | លោក **តា សុទ្ធា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា ២០២០

ជំនាន់ទី ២៤ | ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការលែងលះរវាងសហព័ទ្ធខ្មែរ

( ស្រាវជ្រាវចាប់ពីថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០២៤ ដល់ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២៤ )


ស្រាវជ្រាវដោយ ៖

និស្សិតឈ្មោះ លោក **ទ៉ា ចណ្ណា**

លោក **អឿ ដាវីត**

ណែនាំដោយ

លោក **តា សុទ្ធា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ឈ្មោះ វ៉ា វណ្ណា** និង **ឈ្មោះ អឿ ដាវីត** ជានិស្សិតជំនាន់ទី២៤ ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្ត ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំសិក្សា២០២០ ២០២៤។ សូមសម្តែងនូវកត្តញ្ញូ និងដឹងគុណដ៏ជ្រាលជ្រៅ មិនអាចកាត់ថ្លៃបានដល់លោកអ្នកមានគុណ ដែលបានផ្តល់នូវកំណើតរូបយើងខ្ញុំនិងចិញ្ចឹមបីបាច់ថែរក្សាព្រមទាំងផ្តល់នូវការស្នាក់នៅ និងការរៀនសូត្រតាំងពីថ្នាក់ មត្តេយ្យរហូតមកដល់កម្រិតថ្នាក់ បរិញ្ញាបត្រ។ លោកបានចូលរួមចំណែកនូវកម្លាំងចិត្ត ការអប់រំ ការទូន្មានប្រៀនប្រដៅ ផ្តល់នូវព្រហ្មវិហាធម៌ និង តម្រង់ទិសកូនឲ្យក្លាយជាពលរដ្ឋល្អក្នុងសង្គម។

ទន្ទឹមនឹងនេះយើងខ្ញុំសូមថ្លែងអំណរគុណដល់ **ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ សាកលវិទ្យាល័យធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងលោក លោកស្រី សាស្រ្តាចារ្យទាំងអស់នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច** ដែលបានផ្តល់ឱកាសអោយយើងខ្ញុំទាំងពីររូបបានចូលសិក្សាទទួលនូវចំណេះដឹង និងសមត្ថភាពក៏ ដូចជាបង្ហាត់បង្ហាញចំពោះផ្នែកនីតិសាស្រ្តនេះតាំងពីឆ្នាំទីមួយរហូតមកដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្រ្តប្រកបដោយភាពជោគជ័យផ្លែផ្កា និងសមិទ្ធផលចំណេះដឹងយ៉ាងគាប់ប្រសើរ។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណររគុណដល់លោកគ្រូ **តា សុទ្ធា** ដែលណែនាំយើងខ្ញុំក្នុងការសរសេរ ចងក្រងសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្តនេះផងដែរ ដែលបានចំណាយពេលដ៏មានតម្លៃដើម្បីធ្វើការបង្ហាត់បង្ហាញអស់ពីកម្លាំងកាយកម្លាំងចិត្ត និងណែនាំកែតម្រូវផ្តល់ចំណេះដឹងយ៉ាងច្រើនក៏ដូចជា ផ្តល់ជាអនុសាសន៍ និងតម្រង់ទិសដៅ អោយយើងខ្ញុំក្នុងការបង្កើតកិច្ចការស្រាវជ្រាវបានជោគជ័យ។

ជាចុងបញ្ចប់ យើងខ្ញុំសូមបួងសួងទៅដល់វត្ថុស័ក្កសិទ្ធិទាំងអស់ក្នុងលោកជួយថែរក្សាការពារ និងប្រសិទ្ធពរជ័យជូនដល់អស់លោកទាំងអស់ជួបតែសេចក្តីចម្រើន សុខភាពល្អ អាយុយឺនយូរ និង ទទួលបានជោគជ័យគ្រប់ភារកិច្ចនិងជួបតែពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

ជាក់ស្តែងបន្ទាប់ពីបានសិក្សាយ៉ាងល់អិតអស់រយៈពេលបួនឆ្នាំលើផ្នែកនីតិសាស្ត្រក្រោមការបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់បំផុតពីសំណាក់ លោក លោកស្រី សាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចកន្លងមកនេះធ្វើឲ្យយើងខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងដែលបានទទួលឱកាសក្នុងការសរសេរសារណាបញ្ចប់ការសិក្សាក្នុងឆ្នាំនេះ។ ទន្ទឹមនឹងនេះផងដែរចំពោះការសរសេរសារណាបញ្ចប់ការសិក្សានេះទៀតសោតយើងខ្ញុំទាំងពីរនាក់មានគោលបំណងរួមគ្នានោះគឺដើម្បីសិក្សាស្រាវជ្រាវស្វែងយល់និងបន្ថែមទៅលើចំណេះដឹងដែលមានស្រាប់ដោយទទួលបានពីលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ ព្រមទាំងសិស្សច្បងទាំងអស់គ្នាដែលតែងតែផ្តល់មកយើងខ្ញុំកន្លងមក។ លើសពីនេះយើងខ្ញុំបានចងក្រងស្នាដៃមួយនេះទុកសម្រាប់ឲ្យនិស្សិតជំនាន់ក្រោយបានសិក្សាស្វែងយល់ឲ្យកាន់តែច្បាស់និងជាមូលដ្ឋានសម្រាប់ស្រាវជ្រាវបន្ថែមទៀត។ មួយវិញទៀតបើតាមទិដ្ឋភាពជាក់ស្តែងនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ននាពេលនេះបានកើតនូវបញ្ហាជាច្រើនដែលជាប់ពាក់ព័ន្ធនឹងការរស់នៅមិនចុះសម្រុងនឹងគ្នាហើយក៏តែងតែបែកបាក់គ្នាទៅវិញ។ ហេតុនេះហើយទើបយើងខ្ញុំទាំងពីរនាក់សម្រេចចងក្រងសារណាមួយនេះឡើងដើម្បីឲ្យសិស្ស និស្សិតស្វែងយល់ឲ្យកាន់តែច្បាស់នូវនីតិវិធីនៃការលែងលះ។ អាស្រ័យហេតុនេះយើងខ្ញុំក៏បានសម្រេចជ្រើសរើសប្រធានបទ " **ការលែងលះរវាងសហព័ន្ធខ្មែរ** " ដើម្បីចងក្រងធ្វើជាសារណាបញ្ចប់ការសិក្សានៅឆ្នាំ ២០២៤ នេះ។

ដោយឡែយើងខ្ញុំសង្ឃឹមថាសារណាមួយនេះនឹងអាចឆ្លើយតបទៅនិងតម្រូវការនិងអាចជាចំណែកមួយក្នុងការជួយសម្រួលដល់ប្រជាពលរដ្ឋទាំងឡាយអោយកានតែជ្រាបច្បាស់និង យល់ដឹងបន្ថែមអំពីការលែងលះហើយក៏អាចនិងក្លាយជាការសិក្សាស្រាវជ្រាវ និងឯកសារជំនួយដល់សិស្សនិស្សិតជំនាន់ក្រោយ។ ម្យ៉ាងទៀតនៅក្នុងការចងក្រងសារណាមួយនេះ យើងខ្ញុំបានរៀបរៀង និងបានខិតខំព្យាយាម ពុះពារ ដោយតាក់តែងដើម្បីឲ្យបងប្អូននិស្សិត និងមិត្តអ្នកអាន ងាយស្រួលយល់ និងឆាប់ចាប់បានពីគោលបំណង និងបែបបទនៃសារណាមួយនេះព្រមទាំងអាចឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកអាន ដែលមានបំណងចង់ចេះ ចង់ដឹងសម្រាប់ជាមូលដ្ឋាននៃការស្វែងយល់នូវលិខិតបទដ្ឋានគតិយុត្តសំខាន់ៗដែលមានពាក់ព័ន្ធនឹងប្រធានបទមួយនេះ។

យើងខ្ញុំក៏សូមអភ័យទោសទុកជាមុននូវរាល់កំហុសខុសឆ្គងទាំងឡាយណា ឬ មានចំណុចខ្វះខាតក្នុងប្រការណាមួយដោយអចេតនាពាក្យពេចន៍ក៏ដូចជាអក្ខរាវិរុទ្ធដែលមាននៅក្នុងកិច្ចការស្រាវជ្រាវមួយនេះយើងខ្ញុំនឹងទទួលស្វាគមន៍ជានិច្ចរាល់ការរិះគន់ក្នុងន័យស្ថាបនានូវចំណេះដឹងរបស់យើងខ្ញុំដើម្បីបំពេញចំណុចខ្វះខាតនិងកែលំអរអោយប្រសើរជាងមុន។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........................................ ១

## ជំពូកទី១

## សញ្ញាណទូទៅនិងមូលហេតុដែលនាំឲ្យមានការលែងលះ

**១.១. សញ្ញាណទូទៅនៃការលែងលះ** ........................................ ៤

១.១.១. ភាពចុះសម្រុងក្រោយអាពាហ៍ពិពាហ៍ ........................................ ៤

១.១.២. ភាពមិនចុះសម្រុងនាំឲ្យមានការលែងលះ ........................................ ៥

**១.២. ប្រភេទនៃការលែងលះ** ........................................ ៦

១.២.១. ការលែងលះដោយការព្រមព្រៀង ........................................ ៦

១.២.២. ការលែងលះដោយគ្មានការព្រមព្រៀង ........................................ ៧

**១.៣. កត្តាដែលនាំឲ្យមានការលែងលះ** ........................................ ៨

១.៣.១. ការប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធ ........................................ ៨

១.៣.២. ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ ........................................ ៩

១.៣.៣. ការមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ឬរស់អស់រយៈពេលជាងមួយឆ្នាំ ........................................ ១០

១.៣.៤. ការរស់នៅបែកបាក់គ្នារបស់សហព័ទ្ធអស់រយៈពេលមួយឆ្នាំ ........................................ ១១

១.៣.៥. ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ........................................ ១១

# ជំពូកទី២

# នីតិវិធីនៃការលែងលះ

**២.១. នីតិវិធីនៃការលែងលះដោយមានការព្រមព្រៀង**......១៣

២.១.១. ការសម្តែងឆន្ទៈក្នុងការលែងលះ......១៣

២.១.២. ពាក្យសុំលែងលះ ......១៤

២.១.៣. សមត្ថកិច្ចដោះស្រាយតាមរយៈក្រុមប្រឹក្សា ឃុំសង្កាត់......១៦

២.១.៤. សមត្ថកិច្ចដោះស្រាយតាមរយៈតុលាការ......១៧

២.១.៥.  ការចេញដីការសម្រេច ......១៩

**២.២. នីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀងតាមផ្លូវតុលាការ**......២១

២.២.១. តុលាការមានសមត្ថកិច្ច......២១

២.២.២ បណ្តឹងលែងលះ......២២

២.២.៣. ការផ្សះផ្សារដោយតុលាការ......២៣

២.២.៤. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល......២៣

២.២.៥. ការទាញហេតុផលដោយផ្ទាល់មាត់......២៤

២.២.៦. សេចក្តីសម្រេចក្នុងរឿងលែងលះ......២៥

២.២.៧. ការចាត់ចែងរក្សាការពារ ......២៦

# ជំពូកទី៣

# អានុភាពនៃការលែងលះ

**៣.១. អានុភាពនៃការលែងលះចំពោះទំនាក់ទំនងផ្ទាល់ខ្លួនរបស់សហព័ន្ធ** .........២៧

៣.១.១. ចំពោះភាគីទាំងសងខាង........................................................................២៧

៣.១.២. ចំពោះឈ្មោះរបស់សហព័ន្ធ និង ញាតិ.........................................................២៨

៣.១.៣. ចំពោះអត្តាធិនភាព ...............................................................................២៩

៣.១.៤.កាតព្វកិច្ចសងសំណងជម្ងឺចិត្តអាចកើតមាន..................................................៣០

**៣.២. អានុភាពនៃការលែងលះៈចំពោះទ្រព្យសម្បត្តិ**...................................................៣១

៣.២.១. ទ្រព្យសម្បត្តិអកម្ម....................................................................................៣១

៣.២.២. ទ្រព្យសម្បត្តិសកម្ម.................................................................................. ៣២

៣.២.៣. ទ្រព្យសម្បត្តិរបស់សហព័ន្ធតាមកិច្ចសន្យា .................................................. ៣២

៣.២.៤. ទ្រព្យសម្បត្តិរបស់សហព័ន្ធដែលកំណត់ដោយច្បាប់........................................ ៣៣

៣.២.៥. ទ្រព្យសម្បត្តិដោយឡែក .......................................................................... ៣៣

៣.២.៦. ទ្រព្យសម្បត្តិរួម .......................................................................................៣៤

**៣.៣. អានុភាពនៃការលែងលះៈចំពោះការផ្តល់អាហារកាតព្វកិច្ច**..................................៣៤

៣.៣.១. ការកំណត់អំណាចមេបា..............................................................................៣៥

៣.៣.២. អាហារកាតព្វកិច្ចចំពោះកូន..........................................................................៣៦

៣.៣.៣. អាហារកាតព្វកិច្ចចំពោះសហព័ន្ធ ............................................................... ៣៧

**សេចក្តីសន្និដ្ឋាន** ........................................................................................................ ៣៨

**អនុសាសន៍** ........................................................................................................ ៤០

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នៅក្នុងសង្គមយើងបច្ចុប្បន្ននេះ នៅពេលដែលពេញវ័យកំលោះ ក្រមុំ រមែងតែងតែមានគូគាប់សម្រាប់ជីវិតរបស់គេម្នាក់ៗដើម្បីបង្កើតបានគ្រួសារមួយ។ ហេតុដូចនេះនៅពេលដែលបង្កើតបានគ្រួសារមួយបានតែងតែមានមនោសញ្ចេតនាជាមួយគ្នា ហើយរួមរស់ជាមួយគ្នាប្រកបដោយសុភមង្គលជាមួយគ្នា។មួយវិញទៀតដើម្បីបង្កើតបានគ្រួសារមួយបានពួកគេត្រូវឆ្លងកាត់ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និងស្របទៅតាមលក្ខខណ្ឌគតិយុត្តដែលបានកំណត់សម្រាប់ការបង្កើតអាពាហ៍ពិពាហ៍នោះ ទើបពួកគេក្លាយជាប្តីប្រពន្ធស្របទៅតាមច្បាប់។ ជាមួយគ្នានេះផងដែរបន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍ស្របទៅតាមច្បាប់ហើយនោះបុរស និង ស្ត្រី ត្រូវទៅចុះសំបុត្រអាពាហ៍ពិពាហ៍ (អេតាស៊ីវិល)ទើបបុរស និង ស្ត្រីនោះអាចក្លាយជាប្តីប្រពន្ធស្របច្បាប់។ តែបើក្រឡេកមកមើលតាមស្ថានភាពនៃច្បាប់ជាក់ស្តែងវិញ ប្រសិនបើបុរស និង នារីណាគ្រាន់តែបានរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណីទំនៀមទំម្លាប់ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននោះមិនអាចចាត់ទុកថាមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ជាប្តីប្រពន្ធឡើយ។ ហើយការរស់ជាមួយគ្នាបែបនេះដោយមិនមានចំណងអាពាហ៍ពិពាហ៍ទៅតាមផ្លូវច្បាប់បែបនេះគេហៅថា អនីតិសង្វាស។ ការដែលរួមរស់ជាមួយគ្នាបែបអនីតិសង្វាសនេះផងដែរ ប្រសិនបើភាគីម្ខាង ឬទាំងសងខាងអស់មនោសញ្ចេតនាលែងចង់រួមរស់ជាមួយគ្នាតទៅទៀតដោយពួកគេគ្រាន់តែសម្រេចចិត្តដើរចេញរស់នៅបែកលំនៅឋានគ្នាលែងរួមរស់ជាមួយគ្នាទៀតដោយគ្រាន់តែមានការដឹងឮពីឃុំសង្កាត់ជាការស្រេច ប៉ុន្តែចំពោះទ្រព្យសម្បត្តិ និងអំណាចមេបាលើកូនវិញមិនអាចដោះស្រាយត្រឹមឃុំសង្កាត់បានទេត្រូវតែដោះស្រាយតាមប្រព័ន្ធតុលាការដដែល។

ជាការពិតណាស់ការរៀបអាពាហ៍ពិពាហ៍កើតមានឡើងជាហូរហែរខណៈពេលដែលការលែងលះក៏បានកើតមានឡើងជាបន្តបន្ទាប់។ ការមានគ្នាជាគូរជីវិតដែលបង្កើតបានគ្រួសារមួយដ៏ល្អតែងតែចង់បង្កើតនូវទ្រព្យសម្បត្តិ មានកូនមានចៅ តាមបែបបទនៃការចិញ្ចឹមកូន និងការទទួលខុសត្រូវចំពោះកូនចៅឲ្យបានល្អប្រពៃក្នុងនាមជាឪពុកម្តាយបន្តទៅថ្ងៃខាងមុខទៀត។ ជាក់ស្តែងនៅពេលដែលបង្កើតបានគ្រួសារមួយដែលមាន សុភមង្គល និង មានភាពកក់ក្តៅហើយនោះតែងតែមានរឿងឈ្លោះប្រកែកទាស់ពាក្យសម្តីដោយចៀសមិនផុតហើយនៅពេលដែលរស់នៅជាមួយគ្នាមិនចុះសម្រុង និងនៅមិនយល់ចិត្តគ្នាមិនចេះឲ្យតម្លៃគ្នាទៅវិញទៅមក មិនចេះអត់ឱអធ្យាស្រ័យឲ្យគ្នានោះប្រាកដណាស់ថានឹងនៅរួមរស់ជាមួយគ្នាទៀតច្បាស់ជាមិនបានសុខសាន្តនឹងមានសុភមង្គលទៀតឡើយ រហូតឈានដល់ការបែកបាក់គ្នាដែលជាហេតុនាំឲ្យមានការលែងលះនៅក្នុងគ្រួសារ។ ការលែងលះគឺជាមធ្យោបាយមួយដែលនាំឲ្យចំណងអាពាហ៍ពិពាហ៍ស្របច្បាប់មួយត្រូវបានបញ្ចប់ និងការផ្តាច់ចំណងអាពាហ៍ពិពាហ៍ទៅតាមផ្លូវតុលាការដែលតម្រូវឲ្យមានសេចក្តីសម្រេចពីតុលាការ ឬសាលក្រមស្ថាពរ ដើម្បីបញ្ជាក់អំពីការរំលាយចំណងអាពាហ៍ពិពាហ៍នោះ។ លើសពីនេះទៅទៀតការលែងលះរវាងសហព័ទ្ធខ្មែរ និង សហព័ទ្ធខ្មែរនៅប្រទេសកម្ពុជាតែងតែមានចំណុះ

ដែលជាប់ពាក់ព័ន្ធជាច្រើន ដូចជាការប្រគល់អំណាចមេបាការបែងចែក ទ្រព្យសម្បត្តិការផ្តល់អាហារកិច្ចលែងលះជាដើម។ ដូច្នេះតើការលែងលះជាអ្វី? តើកត្តាអ្វីខ្លះដែលជាមូលហេតុបណ្តាលឲ្យមានការលែងលះកើតឡើង? តើដំណើរការនិងនីតិវិធីក្នុងរឿងក្តីលែងលះរវាងសហព័ទ្ធខ្មែរ និងសហព័ទ្ធខ្មែរប្រព្រឹត្តទៅបានយ៉ាងដូចម្តេច? ចំណែកឯកូន និងការបែងចែកទ្រព្យសម្បត្តិការផ្តល់អាហារកិច្ចផ្សេងៗទៀតត្រូវចាត់ចែងយ៉ាងដូចម្តេច?

យ៉ាងណាមិញយើងខ្ញុំសង្កេតឃើញថាការលែងលះរវាងសហព័ទ្ធខ្មែរនិងសហព័ទ្ធខ្មែរពិតជាមានលក្ខណៈស្មុគស្មាញណាស់ ដែលវាបានបន្សល់ទុកចម្ងល់ជាច្រើនដល់ប្រជាពលរដ្ឋនៅក្នុងសង្គមជាពិសេសនោះសាមីខ្លួនផ្ទាល់ដែលមានបំណងចង់លែងលះទើបជាហេតុនាំឲ្យយើងខ្ញុំមានចំណាប់អារម្មណ៍ចង់ធ្វើការ ចងក្រងនិងស្រាវជ្រាវប្រធានបទមួយនេះឡើងដើម្បីទុកជាស្នាដៃ ហើយបានបញ្ចេញនូវចំណេះដឹងនិងទទួលបានបទពិសោធន៍ល្អៗពីលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យដែលធ្វើឲ្យយើងខ្ញុំមានឱកាសក្នុងការស្រាវជ្រាវកាន់តែច្បាស់លាស់បន្ថែមទៀតទៅលើបញ្ហាលែងលះនៅកម្ពុជា។ មិនតែប៉ុណ្ណោះវាក៏ជាឯកសារមួយសម្រាប់តម្កល់ទុកក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យដើម្បីឲ្យនិស្សិតជំនាន់ក្រោយអាចធ្វើការសិក្សាជាបន្ទាប់បន្សំថែមទៀត។ ដោយក្នុងគោលបំណងចង់អោយប្រជាពលរដ្ឋយល់ដឹងអំពីច្បាប់ យល់ដឹងអំពីការលែងលះយល់ដឹងពីនីតិវិធីនៃការលែងលះដោយមានការព្រមព្រៀង និងគ្មានការព្រមព្រៀងព្រមទាំងអានុភាពនៃការលែងលះរវាងសហព័ទ្ធខ្មែរ នីតិវិធីនៃការបែងចែកទ្រព្យសម្បត្តិ ការប្រគល់អំណាចមេបា និងការផ្តាច់អាហារកាតព្វកិច្ចផងដែរ។ លើសពីនេះទៅទៀតដើម្បីអោយអាជ្ញាធរមានសមត្ថកិច្ចដែលមានតួនាទីភារៈកិច្ចទាក់ទងទៅនិងផ្នែកនេះអាចអនុវត្តការងារឲ្យកាន់តែច្បាស់លាស់ និងមានភាពទំនួលខុសត្រូវដើម្បីផ្តល់ភាពងាយស្រួលនិងបង្កើនទំនុកចិត្តដល់ប្រជាពលរដ្ឋដែលមានបញ្ហាក្នុងរឿងក្តីលែងលះ។ មួយវិញទៀតការបកស្រាយប្រធានបទមួយនេះគឺមានទំហំត្រឹមតែការបកស្រាយទៅលើសញ្ញាណទូទៅនិងមូលហេតុដែលនាំឲ្យមានការលែងលះ ប្រភេទនៃការលែងលះ កត្តាដែលនាំឲ្យមានការលែងលះ នីតិវិធីនៃការលែងលះដោយមានការព្រមព្រៀង នីតិវិធីនៃការលែងលះដោយមានពាក្យបណ្តឹង អានុភាពចំពោះទំនាក់ទំនងផ្ទាល់ខ្លួនរបស់សហព័ទ្ធ អានុភាពនៃការលែងលះចំពោះទ្រព្យសម្បត្តិ អានុភាពនៃការផ្តល់អាហារកាតព្វកិច្ច ដែលជាប់ពាក់ព័ន្ធនឹងការលែងលះរវាងសហព័ទ្ធខ្មែរនៅកម្ពុជាតែប៉ុណ្ណោះ។ ម្យ៉ាងទៀតការលែងលះនៅកម្ពុជាមានពីរ ប្រភេទគឺការលែងលះរវាងសហព័ទ្ធខ្មែរ និងការលែងលះរវាងសហព័ទ្ធខ្មែរ និង ជនបរទេស។ដូច្នេះយើងខ្ញុំសូមបញ្ជាក់អោយបានច្បាស់ថាការបកស្រាយរបស់យើងខ្ញុំគឺផ្តោតទៅលើតែការលែងលះរវាងសហព័ទ្ធខ្មែរនៅកម្ពុជាតែប៉ុណ្ណោះ។

យើងខ្ញុំសង្ឃឹមថាការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ និងមានសារៈប្រយោជន៍គឺអាចដោះស្រាយចម្ងល់ដែលបងប្អូននិស្សិតជំនាន់ក្រោយ ឬអ្នកអានទាំងអស់បានយ៉ាងពិតប្រាកដ។ ហើយអាចជាសៀវភៅដ៏សំខាន់សម្រាប់អ្នកដែលបានអានទាំងឡាយដើម្បីយល់ដឹងកាន់តែស៊ីជម្រៅអំពីនីតិវិធីនៅក្នុង

ការលែងលះ និងចំណុចផ្សេងៗដែលបន្សល់ទុកបន្ទាប់ពីការលែងលះត្រូវបានបញ្ចប់។ ជាងនេះទៅទៀត ការរៀបចំ ចងក្រងប្រធានបទមួយនេះឡើងដើម្បីបំភ្លឺចម្ងល់ផ្សេងៗពាក់ព័ន្ធនឹងរឿងក្តីលែងលះរួមទាំងចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រព័ន្ធច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាអោយកាន់តែមានភាពរីកចម្រើនបន្ថែមទៀតផងដែរ។

ប្រធានបទស្តីពី " **ការលែងលះរវាងសហព័ទ្ធខ្មែរ** " នេះមានដែនកំណត់ស្ថិតនៅក្រោម រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ ច្បាប់ស្តីពីឯកពន្ធភាពឆ្នាំ២០០៦ ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនិងឋានៈបុគ្គល២០១០ ច្បាប់ស្តីពី បណ្តឹងវិវាទគ្រួសារ ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង២០១០ និង អនុក្រឹត្យស្តីពីអាត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មឆ្នាំ២០២៣។ រួមទាំងបានខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវដោយប្រមូលឯកសារច្បាប់ដែលពាក់ព័ន្ធនានាតាមប្រព័ន្ធអ៊ីនធឺណេត នឹងចំណេះដឹងដែលទទួលបានមកពីលោកគ្រូ អ្នកគ្រូ ដើម្បីចងក្រងបង្កើតស្នាដៃមួយនេះឡើង។

នៅក្នុងការបកស្រាយប្រធានបទសារណាស្តីពី " **ការលែងលះរវាងសហព័ទ្ធខ្មែរ** " មានភាពងាយស្រួលនៅក្នុងការសិក្សាអំពីដំណាក់កាល និងនីតិវិធីនៃការលែងលះត្រង់ចំណុចនីមួយៗឲ្យកាន់តែច្បាស់លាស់ យើងខ្ញុំបានបែងចែកវាជា ៣ ជំពូករួមមាន៖

ជំពូកទី១៖ សញ្ញាណទូទៅនិងមូលហេតុនៃការលែងលះ

ជំពូកទី២៖ នីតិវិធីនៃការលែងលះ

ជំពូកទី៣៖ អានុភាពនៃការលែងលះ

# ជំពូកទី១
# សញ្ញាណទូទៅនិងមូល ហេតុដែលនាំឲ្យមានការ លែងលះ

# ជំពូកទី១

# សញ្ញាណទូទៅនិងមូលហេតុដែលនាំឲ្យមានការលែងលះ

## ១.១. សញ្ញាណទូទៅនៃការលែងលះ

ជាទូទៅប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានចំណងអាពាហ៍ពិពាហ៍ត្រូវគោរពគោលការណ៍ឯកពន្ធភាពដោយស្ម័គ្រចិត្តប្តីមួយប្រពន្ធមួយដោយមានចុះបញ្ជីអាពាហ៍ពិពាហ៍នៅមុខ មន្ត្រីអត្រានុកូលដ្ឋាន។[1] ដោយហេតុថា ការចុះបញ្ជីអាពាហ៍ពិពាហ៍គឺជាកិច្ចសន្យាដ៏ឱឡារិក ហេតុនេះអាពាហ៍ពិពាហ៍ នឹងមានអានុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងស្របតាមក្បួនខ្នាតដែលមាន ចែងក្នុងច្បាប់ជាធរមាន។ គួរបញ្ជាក់ផងដែរថា បុរស និងនារី មានសេរីភាពពេញលេញក្នុងការជ្រើសរើសគូស្រករក្នុងគោលដៅកសាងគ្រួសារដោយរួមរស់នៅជាមួយគ្នារួមសុខរួមទុក្ខជាមួយគ្នាទៅថ្ងៃមុខ និងឈានដល់បង្កើតឱ្យមានចំណងគតិយុត្តរវាងគ្នា និងគ្នារហូតដល់មានបុត្រមានទ្រព្យសម្បត្តិរួមគ្នាព្រមទាំងមានសិទ្ធិ និងកាតព្វកិច្ចផ្សេងទៀតជាមួយគ្នាផងដែរ។ យ៉ាងណាមិញបើយើងក្រឡេកទៅមើលគូស្វាមីភរិយាជាច្រើនបន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍ ក៏បង្កើតគ្រួសារមួយប្រកបដោយសុភមង្គល និងមានសេចក្តីសុខ។ ទន្ទឹមគ្នាផងដែរគ្រួសារមួយចំនួន ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នារួចមកហាក់បីជារស់នៅជាមួយគ្នាមិនចុះសម្រុងដោយមានភាពល្អក់កករហើយមានតែបញ្ហាផ្សេងៗដែលកើតចេញពីមូលហេតជាច្រើន រួចឈានទៅដល់ការបង្កឲ្យមានទំនាស់នៅក្នុងគ្រួសារដែលពុំអាចរួមរស់ជាមួយគ្នាតទៅមុខទៀត។ ដូច្នេះប្រសិនបើសហព័ទ្ធណាម្ខាង ឬទាំងសងខាងយល់ឃើញថាខ្លួនពិតជាមិនអាចរស់នៅជាប្តីប្រពន្ធនឹងគ្នាទៀតបានទេនោះពួកគេអាចដាក់ពាក្យសុំលែងលះបាន ដែលគោរពទៅតាមលក្ខខណ្ឌដែលច្បាប់បានកំណត់។ មុនបកស្រាយពីការលែងលះ យើងត្រូវស្វែងយល់ពីជីវិតប្តីប្រពន្ធដែលមានភាពចុះសម្រុងក្រោយអាពាហ៍ពិពាហ៍ និងភាពមិនចុះសម្រុងនាំឲ្យមានការលែងលះគ្នា ជាមុនសិន។

### ១.១.១. ភាពចុះសម្រុងក្រោយអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍គឺជាកិច្ចសន្យាមួយដ៏ឱឡារិកដែលបានធ្វើឡើងដោយបុរស និង ស្ត្រីម្នាក់ដែលប្តេជ្ញាថាខ្លួននឹងរួមរស់ជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយមិនអាចរំលាយទៅវិញតាមទំនើងចិត្តរបស់ខ្លួនឡើយ។ចំពោះកិច្ចសន្យាធម្មតាអោយ តែសំណើនិងស្វីការត្រូវគ្នា គឺកិច្ចសន្យានឹងត្រូវបានបង្កើតឡើង បើទោះជាធ្វើឬមិនធ្វើជាលាយលក្ខណ៍អក្សរក៏ដោយ ប៉ុន្តែកិច្ចសន្យាក្នុងរឿងអាពាហ៍ពិពាហ៍វិញ ត្រូវតែប្រិតប្រៀងបំផុតនិងត្រូវគោរពតាមមាត្រា៩៥៥នៃក្រម រដ្ឋប្បវេណី ហើយកិច្ចសន្យាក្នុងរឿងអាពាហ៍ពិពាហ៍ មិនអាចធ្វើដោយផ្ទាល់មាត់បានទេ

[1] ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦, មាត្រា២។

ថ្វីបើសំណើសុំរៀបអាពាហ៍ពិពាហ៍ត្រូវគ្នាជាមួយនឹងស្ទីការការរៀបអាពាហ៍ពិពាហ៍ក៏ដោយ។ មួយវិញទៀត អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈច្បាប់បានលុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងស្របទៅតាមច្បាប់បានកំណត់។[2] ហើយភាគីម្ខាងមិនអាចបង្ខំឆន្ទះរបស់ភាគីម្ខាងទៀតបានឡើយក្នុងករណីដែលបុរស ឬនារីដែលមានអាយុពេញលក្ខណៈច្បាប់ មានសិទ្ធិពេញលេញក្នុងការសម្រេចឲ្យរៀបអាពាហ៍ពិពាហ៍ប្រសិនបើអាពាហ៍ពិពាហ៍នោះរៀបចំឡើងត្រឹមត្រូវតាមក្បួនខ្នាតដែលច្បាប់បានបញ្ញត្តិ។[3] ការរស់នៅជាប្តីប្រពន្ធដោយចុះសម្រុងជាមួយគ្នាយូរៗទៅ នឹងអាចបង្កើតជាគ្រួសារដ៏ធំដោយអាចមានកូនក្នុងបន្ទុកផងដែរ។ ភាគច្រើនយើងឃើញថាស្វាមីភរិយាទាំងនោះមានសុភមង្គលល្អដែលចេះអត់ឱនឲ្យគ្នា ចេះយោគយល់គ្នា ចេះសហការគ្នាគ្រប់បែបយ៉ាង។ ប៉ុន្តែទន្ទឹមនឹងនោះយើងជួបប្រទះស្វាមីភរិយាមួយចំនួនដែលពុំអាចរស់នៅចុះសម្រុងគ្នាសោះ។

### ១.១.២. ភាពមិនចុះសម្រុងនាំឲ្យមានការលែងលះ

ការលែងលះគឺជាការផ្តាច់ចំណងអាពាហ៍ពិពាហ៍នៃប្តីប្រពន្ធដែលបានរៀបការពេញច្បាប់ក្នុងពេលរស់នៅជាមួយគ្នាទាំងពីរនាក់។[4] នៅក្នុងក្រមរដ្ឋប្បវេណីមាត្រា៩៧៩ បានចែងថាតុលាការអាចឲ្យលែងលះគ្នាបានក្រោយពីយល់ឃើញថាភាគីទាំងសងខាងមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍។[5]

នៅក្នុងសង្គមយើងសព្វថ្ងៃការលែងលះកំពុងតែគ្របដណ្តប់គ្រប់ទិសទី ការចែកផ្លូវគ្នារបស់សហព័ទ្ធមិនមែនជារឿងងាយស្រួលដូចលុបសំបុត្រអាពាហ៏ពិពាហ៏នៅតុលាការឡើយ ការលែងលះបន្សល់ទុកនូវការឈឺចាប់ដល់ភាគីទាំងសងខាង បើពួកគេគ្មានកូននោះមិនអីទេ។ ផ្ទុយទៅវិញបើពួកគេមានកូនបញ្ហាកាន់តែស្មុកស្មាញកូននិងក្លាយទៅជាជនរងគ្រោះដោយសារការលែងលះពេលនោះបញ្ហានិងកើតមានឡើងចំពោះអ្នកទាំងពីរគឺការចិញ្ចឹមបីបាច់ថែរក្សាកូនក្រោយពេលលែងលះគ្នា។ ហើយបញ្ហាលែងលះភាគច្រើនកើតឡើងដោយសារៈ ជឿរពាក្យសម្តីសាច់ថ្លៃឬសាច់បង្កើតគ្រួសារបែកបាក់ ដោយសារមានអ្នកថ្មី ហិង្សាក្នុងគ្រួសារជីវៈភាពក្រីក្រពេកធ្វើអោយមានបញ្ហាក្នុងគ្រួសាររហូតឈានដល់ការលែងលះ ខ្វះខាតចំណេះដឹងវ័យរៀបការនៅក្មេងពេក។[6] មិនទាន់បានត្រៀមខ្លួនរួចរាល់ពេលក្លាយជាសហព័ទ្ធ ផ្ទត់គំនិតក្មេងខ្ចីរបស់គូស្វាមីភរិយា កង្វះមធ្យោបាយចិញ្ចឹមជីវិត ចំណេះដឹងយុវជននិងអាណាព្យាបាលនៅមានកម្រិត កង្វះផែនការគ្រួសារបទពិសោធន៍សង្គមធ្វើឲ្យពួកគេពិបាកសម្របខ្លួនរស់នៅជាមួយគ្នា។[7] ឥឡូវនេះយើងនិងស្វែងយល់ពីប្រភេទនៃកាលែងលះ។

---

[2] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា២។

[3] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ឆ្នាំ១៩៨៩, មាត្រា៤។

[4] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ,លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៣៨។

[5] ក្រមរដ្ឋប្បវេណី,លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា៩៧៩។

[6] https://youtu.be/h_IgXaiufA8?si=Lj_ACVf9IsmgNJG4

[7] https://youtu.be/-FcXyqu1I7Y

## ១.២. ប្រភេទនៃការលែងលះ

សហព័ទ្ធទាំងពីរ អាចធ្វើការលែងលះគ្នាដោយមានការព្រមព្រៀងពីសំណាក់ភាគីទាំងសងខាងដោយគ្មានកំហុសរបស់សហព័ទ្ធណាមួយឡើយ តែផ្ទុយទៅវិញ គឺជាការព្រមព្រៀងរវាងសហព័ទ្ធទាំងសងខាងដោយយល់ឃើញថាជីវិតអាពាហ៍ពិពាហ៍របស់ពួកគាត់មិនអាចបន្តទៅមុខទៀតបានទេឡើយ។ នៅក្នុងករណីនេះដែរ តុលាការនឹងសម្រេចឱ្យមានការលែងលះគ្នាប្រសិនបើតុលាការយល់ឃើញថាភាគីទាំងសងខាងមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍។ ដូច្នេះហើយទើបក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ញតិថាការលែងលះមានពី ប្រភេទគឺការលែងលះដោយការព្រមព្រៀង និងការលែងលះដោយគ្មានការព្រមព្រៀង។

### ១.២.១. ការលែងលះដោយការព្រមព្រៀង

ការលែងលះដោយការព្រមព្រៀងគ្នាមានន័យថាភាគីនៃអាពាហ៍ពិពាហ៍ណាម្ខាងអាចដាក់ពាក្យសុំលែងលះទៅតុលាការនៃលំនៅឋានរបស់ប្ដីប្រពន្ធបានក្នុងករណីដែលភាគីទាំងសងខាងបានព្រមព្រៀងអំពីការលែងលះគ្នា។ ការលែងលះដោយមានការព្រមព្រៀងចង់សំដៅទៅលើការសម្រេចចិត្តលែងលះ ដោយផ្អែកលើឆន្ទៈពិតប្រាកដរបស់សហព័ទ្ធទាំងពីរ ក្នុងការផ្ដាច់នូវចំណងអាពាហ៍ពិពាហ៍ ពេលមិនមានភាគីណាមួយជំទាស់ ឬមាន វិវាទមិនព្រមលែងលះនោះឡើយ។ ដោយយល់ឃើញថាភាគីទាំងសងខាង អស់និស្ស័យ អស់មនោសញ្ចេតនា ជាមួយនឹងគ្នាឬ មិនអាចបន្តរស់នៅជាមួយគ្នាតទៅមុខទៀតបាន។ មួយវិញទៀតការលែងលះដោយមានការព្រមព្រៀងនេះអាចប្រព្រឹត្តទៅបាន គឺនៅពេលដែលសហព័ទ្ធទាំងពីរមានឆន្ទៈស្របគ្នាក្នុងការព្រមព្រៀងលែងលះហើយថែមទាំងបានព្រមព្រៀងគ្នារួចជាស្រេចក្នុងការកំណត់អំពីការបែងចែកទ្រព្យសម្បត្តិក្រោយការលែងលះ ឬ ការព្រមព្រៀងលើការកំណត់ពីអំណាចមេបា ឬអាហារកាតព្វកិច្ចជាដើម។ បន្ថែមឲ្យកាន់តែច្បាស់ទៅលើចំណុចនេះគឺចង់សំដៅថាករណីដែលសហព័ទ្ធមានការព្រមព្រៀងលែងលះគ្នាដោយការឯកភាពនេះមានត្រឹមតែការព្រមព្រៀងផ្ដាច់នូវចំណងអាពាហ៍ពិពាហ៍ ក៏ប៉ុន្តែភាគីពុំមានការព្រមព្រៀងគ្នាទៅលើការបែងចែកសិទ្ធិនិងកាតព្វកិច្ចផ្សេងៗ ក្រោយការលែងលះនោះតាមរយៈស្មារតីនៃច្បាប់រដ្ឋប្បវេណីមិនកំណត់ថាចូលជាការលែងលះដោយព្រមព្រៀងឡើយ។ ការលែងលះដោយព្រមព្រៀងអាចប្រព្រឹត្តទៅបានលុះត្រាតែភាគីបានព្រមព្រៀងគ្នារួចជាស្រេចលើសិទ្ធិ និងកាតព្វកិច្ចដោយពុំមានវិវាទ រវាងគ្នាហើយសកម្មភាពនេះកើតឡើងដោយឆន្ទៈផ្ទាល់ និងពិតប្រាកដរបស់ភាគី។ ក្រោយពីទទួលពាក្យសុំលែងលះដោយព្រមព្រៀងគ្នា តុលាការអាចឱ្យភាគីលែងលះគ្នាបានក្រោយពីឆ្លងកាត់នីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់។ បើយល់ឃើញថាភាគីសងខាងមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ តុលាការអាចចេញដីកាសម្រេចតាមពាក្យសុំឱ្យលែងលះបាន។[៩] ភាគីនៃអាពាហ៍ពិពាហ៍អាចដាក់ពាក្យបណ្ដឹងលែងលះទៅតុលាការបានក្នុងករណីដែលភាគីសងខាងបានព្រមព្រៀងអំពីការលែងលះគ្នា។ ប៉ុន្តែតុលាការអាចឱ្យលែងលះគ្នាបានក្រោយពីបានយល់ឃើញ

[៩] សៀវភៅនីតិរដ្ឋប្បវេណី, ប៊ួយ ធីតា, ឆ្នាំ២០២៤ ទំព័រ២៥៧។

ថាភាគីសងខាងមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍។[9] ប្រសិនបើសេចក្ដីសម្រេចឱ្យលែងលះចេញដោយសាលាឧទ្ធរណ៍ ឬ តុលាការកំពូល អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ ឬ អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលដែលចេញសេចក្ដីសម្រេចនោះត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចនោះទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។[10] ជួនកាលក៏កើតឡើងនូវការលែងលះដោយគ្មានការព្រមព្រៀងផងដែរ។

### ១.២.២. ការលែងលះដោយគ្មានការព្រមព្រៀង

ការលែងលះដោយគ្មានការព្រមព្រៀង គឺជាការទាមទារឲ្យបញ្ចប់ចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ដោយសាលក្រមរបស់តុលាការតាមរយៈការដាក់ពាក្យបណ្ដឹងដោយភាគី។ ការលែងលះដោយគ្មានការព្រមព្រៀងនេះកើតមានជារឿយៗនៅក្នុងសង្គមខ្មែរបច្ចុប្បន្នដោយសារតែភាគីលែងលះមិនចុះសម្រុងរវាងគ្នារហូតឈានដល់ការសម្រេចចិត្តចែកផ្លូវគ្នាទាំងជម្លោះ។ ការបែកបាក់ទំនាក់ទំនងអាពាហ៍ពិពាហ៍បែបនេះមិនមែនបញ្ចប់ដោយសន្តិវិធីនោះទេពោលគឺភាគីអាចមានមូលហេតុច្រើនដែលនាំឲ្យខ្វែងគំនិតយោបល់ឆន្ទៈផ្ទុយគ្នាបណ្ដាលឲ្យមានការប្ដឹងលែងលះ។ នៅពេលដែលគូស្វាមីភរិយារស់នៅមិនចុះសម្រុងនឹងគ្នាដែលឈានទៅដល់ការទាមទារលែងលះដោយភាគីណាម្ខាងហើយភាគីម្ខាងទៀតមិនយល់ព្រម ឬមានចំណុចវិវាទបែងចែកទ្រព្យសម្បត្តិបំណុលជាអាទិ៍។ ក្នុង ករណីនេះភាគីណាម្ខាងអាចដាក់ពាក្យប្ដឹងទៅតុលាការដើម្បីសុំលែងលះ និងមានកម្មវត្ថុនៃការទាមទារផ្សេងទៀតតាមករណីជាក់ស្ដែងនីមួយៗ។[11] ការបែកបាក់ទំនាក់ទំនងអាពាហ៍ពិពាហ៍បែបនេះមិនមែនបញ្ចប់ដោយសន្តិវិធីនោះទេពោលគឺភាគីអាចមានមូលហេតុច្រើនដែលនាំឲ្យខ្វែងគំនិតយោបល់ឆន្ទៈផ្ទុយគ្នាបណ្ដាលឲ្យមានការប្ដឹងលែងលះ។ គួរបញ្ជាក់ផងដែរថាការលែងលះដោយគ្មានការព្រមព្រៀងកើតឡើងដោយសារស្ថានភាពវិវាទរបស់ភាគីណាមួយដែលទាមទារលែងលះតែភាគីម្ខាងទៀតមិនឯកភាពលែងលះ ឬបញ្ហាមិនព្រមព្រៀងលើការបែងចែកទ្រព្យសម្បត្តិ និង អំណាចមេបាលើកូនៗ។ ប្រសិនបើសហព័ទ្ធម្ខាងនោះមានការមិនសុខចិត្តដែលទទួលរងនូវទង្វើទាំងនោះសហព័ទ្ធម្ខាងនោះអាចដាក់ពាក្យសុំលែងលះដើម្បីអោយតុលាការធ្វើការវិនិច្ឆ័យ ហើយចេញសាលក្រមលែងលះ ដោយឆ្លើយតបទៅនឹងជនរងគ្រោះដែលជាដើមបណ្ដឹងទាមទារ។ បំណងនៃការទាមទារលែងលះអាចធ្វើទៅបានលុះត្រាតែមានមូលហេតុត្រឹមត្រូវដូចមានចែងនៅក្នុងមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី។ ភាគីមានសិទ្ធិក្នុងការដាក់បណ្ដឹងទាមទារលែងលះនៅតុលាការដែលមានសមត្ថកិច្ច ឬនៅក្រុមប្រឹក្សាឃុំ-សង្កាត់ដោយយោងតាមបញ្ញត្តិ មាត្រា១០ (សមត្ថកិច្ចសាលាជម្រះក្ដីពិសេសលើរឿងក្ដីលែងលះគ្នានិងរឿងក្ដីអំពីបុត្តភាព)នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន។[12] បើទោះបីជា ពាក្យបណ្ដឹងទាមទារការលែងលះរបស់ភាគី មានមូលហេតុដូចមានចែងក្នុងច្បាប់ក៏ដោយ ប៉ុន្តែប្រសិន បើតុលាការយល់ឃើញថាការ

---

[9] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា៩៧៩។

[10] ច្បាប់ស្ដីពីអត្រានុកូលស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, នស/រកម/០៧២៣/០០៩, ០១ កក្កដា ២០២៣ មាត្រា៧៨។

[11] សៀវភៅនីតិរដ្ឋប្បវេណី ប៊ួយ ធីតា, ឆ្នាំ២០២៤ ទំព័រ២៥៨។

[12] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា៩៨២។

លែងលះនោះ បណ្តាលឲ្យការទ្រទ្រង់ជីវភាពរបស់ប្តី ប្រពន្ធ ឬកូន ក្រលំបាក មានការឈឺចាប់ដែលពុំអាចទ្រាំទ្របាន ឬដោយសារតែការទាមទារនោះផ្ទុយនឹងភាពសុចរិតនោះ តុលាការអាចច្រានចោល ការទាមទារលែងលះគ្នានោះបាន ដោយពិចារណាលើស្ថានភាពជាក់ស្តែង ឬដោយឆន្ទានុសិទ្ធិ។ ហើយការលែងលះគ្នាអាចបណ្តាលមកពីកត្តាជាច្រើន។

## ១.៣. កត្តាដែលនាំឱ្យមានការលែងលះ

ប្រសិនបើសហព័ទ្ធរស់នៅជាមួយគ្នាមិនមានការចុះសម្រុងគ្នា ឬសហព័ទ្ធណាម្នាក់បានប្រព្រឹត្តនូវអំពើអបាយមុខដែលធ្វើអោយសហព័ទ្ធម្ខាងទៀតមិនអាចទទួលយកបាន និងឈានដល់ការព្រមព្រៀមលែងលះ។ មួយវិញទៀតបើភាគីខាងណាមិនព្រមលែងលះតែការលែងលះអាចធ្វើទៅបានលុះត្រាតែស្ថិតនៅក្នុងក្របខណ្ឌនៃបញ្ញាត្តិច្បាប់។ ជាការពិតណាស់ នៅក្នុងរង្វង់គ្រួសារនីមួយៗ តែងតែកើតមានបញ្ហាខុសប្លែកគ្នា ដែលមានតែសមាជិកនៃក្រុមគ្រួសារផ្ទាល់តែប៉ុណ្ណោះដែលដឹង ហេតុនេះការបែកបាក់នៃចំណងអាពាហ៍ពិពាហ៍រហូតឈានដល់ការលែងលះ អាចបណ្តាលមកពីមូលហេតុផ្សេងៗគ្នាចំពោះគ្រួសារនីមួយៗ។ ច្បាប់ត្រូវបានបង្កើតឡើងដើម្បីធានា និងការពារផលប្រយោជន៍របស់មនុស្សក្នុងសង្គម ជាពិសេសបញ្ញត្តិអំពី អាពាហ៍ពិពាហ៍ត្រូវបានការពារដោយច្បាប់រដ្ឋប្បវេណី ក្នុងគោលបំណងរក្សាសុភមង្គលក្នុងគ្រួសារ ហេតុនេះស្មារតីរបស់ច្បាប់រដ្ឋប្បវេណីក៏គ្មានចរិកលក្ខណៈបង្ខំឲ្យមនុស្សពីរនាក់ដែលមិនមានមនោសញ្ចេតនានឹងគ្នា បន្តរស់នៅជាមួយគ្នាទាំងលំបាកនោះឡើយ។ ដូចនេះការលែងលះអាចសម្រេចទៅបានកាលបើមានមូលហេតុគ្រប់គ្រាន់ត្រឹមត្រូវ និងច្បាស់លាស់ក្នុងការបញ្ជាក់ថាខ្លួនពុំអាចរួមរស់ចុះសម្រុងនឹងគ្នាបានតទៅទៀតទៅតាមមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណីដែលបញ្ញត្តិអំពីមូលហេតុនៃការលែងលះ។[13] មូលហេតុនៃការលែងលះរវាងសហព័ទ្ធខ្មែរ នៅកម្ពុជាដែលសមហេតុផលទៅតាមច្បាប់បច្ចុប្បន្នមានដូចជា៖ (១.៣.១.) **ការប្រព្រឹត្តអំពើផិតក្បត់ទៅលើ សហព័ទ្ធ**, (១.៣.២.) **ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ**, (១.៣.៣.) **ការមិនដឹងច្បាស់ថា សហព័ទ្ធស្លាប់ឬរស់អស់រយៈពេលជាងមួយឆ្នាំ**, (១.៣.៤.) **ការរស់នៅបែកបាក់គ្នារបស់សហព័ទ្ធអស់រយៈពេលមួយឆ្នាំ**, (១.៣.៥.) **ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់។**

### ១.៣.១. ការប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធ

អំពើផិតក្បត់ គឺជាមូលហេតុមួយដែលត្រូវបានកំណត់ដោយក្រមរដ្ឋប្បវេណី ដែលភាគីមានសិទ្ធិលើកជាមូលហេតុក្នុងការដាក់ពាក្យបណ្តឹងលែងលះ ដោយសំអាងលើចំណុចនេះ។[14] ត្រូវចាត់ទុកថាផិត គឺការរួម

[13] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា៩៧៨។

[14] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា៩៧៨ (១)(ក)។

សេវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្តីរបស់ខ្លួន។[15]

ស្វែងយល់ពីតថភាពជាក់ស្តែងនៅក្នុងសង្គមវិញបានបង្ហាញថា អាពាហ៍ពិពាហ៍ដែលមានជនទីបីជ្រៀតជ្រែក មានការលួចលាក់ គ្មានភាពស្មោះត្រង់នឹងគ្នា គឺជាអាពាហ៍ពិពាហ៍ដែលប្រេះស្រាំ ហើយទង្វើផិតក្បត់នេះក៏ជះឥទ្ធិពលមិនល្អដល់ប្រពៃណីទំនៀមទម្លាប់ និងសេចក្តីថ្លៃថ្នូរនៅក្នុងសង្គមផងដែរ។ អំពើផិតក្បត់ផ្តល់នូវទុក្ខទាំងផ្លូវកាយ និង ផ្លូវចិត្តចំពោះភាគីនៃអាពាហ៍ពិពាហ៍ ហេតុនេះហើយទើបក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា កំណត់ថា អំពើផិតក្បត់ជាមូលហេតុដើម្បីទាមទារការលែងលះ។

**ឧទាហរណ៍៖** លោក សុផល និងលោក ស្រី សយ បានរៀបការជាមួយគ្នាស្របទៅតាមច្បាប់។ ៥ឆ្នាំក្រោយ លោក សុផល បានលួចចិញ្ចឹមស្រីកំណាន់ចិត្តម្នាក់ឈ្មោះ ចិន្តា នៅថ្ងៃមួយលោក សុផលបាននាំ ចិន្តាទៅរួមសម្ពសង្វាសនៅឯផ្ទះសំណាក់មួយកន្លែង។ នៅពេលលោកស្រី សយ តាមទាន់លោក សុផល និង ចិន្តា នៅបន្ទប់ផ្ទះសំណាក់គាត់មានការឈឺចាប់យ៉ាងខ្លាំង និងលែងចង់បន្តរួមរស់ជាមួយលោក សុផលតទៅទៀត។ នៅក្នុងករណីនេះលោកស្រី សយ អាចធ្វើការសុំលែងលះជាមួយលោក សុផល បានដោយផ្អែកលើមូលហេតុការប្រព្រឹត្តនូវអំពើផិតក្បត់។

### ១.៣.២. ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ

ចំពោះចំណុចនេះចង់សំដៅទៅលើការបោះបង់ចោលប្តី ឬប្រពន្ធដោយមិនមានមូលហេតុត្រឹមត្រូវ។ ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវគឺជាការមិនបានរួមរស់ជីវភាពជាមួយគ្នា មិនសហការគ្នាមិនសង្គ្រោះគ្នាទៅវិញទៅមកហើយដែលគេអាចទទួលស្គាល់ថាគូរភាគីមិនមានឆន្ទៈបន្តជីវភាពរស់នៅជាប្តីប្រពន្ធតទៅទៀតឡើយ។[16] ទង្វើនៃការបោះបង់សហព័ទ្ធម្ខាងចោលជាទង្វើដែលអគតិមួយប្រសិនបើមនុស្សដែលចេះគិតគូរដល់គ្រួសារពិតប្រាកដពិតជាមិនអាចធ្វើទង្វើនេះទៅរួចបានឡើយ។

ការបោះបង់សហព័ទ្ធម្ខាងចោលគឺមានន័យថាសហព័ទ្ធនោះពុំបានគិតទៅដល់សុខទុក្ខក្នុងគ្រួសារក៏ដូចជាប្រពន្ធកូន ការខ្វះខាតប្រាក់ឧបត្ថម្ភស្បៀងអាហារហូបចុកសំរាប់ជីវភាពចិញ្ចឹមជីវិតប្រចាំថ្ងៃ ការផ្គត់ផ្គង់លើថ្លៃសិក្សារបស់កូននិងការបាត់បង់ភាពកក់ក្តៅនៃសុភមង្គលគ្រួសារ។

ការបោះបង់សហព័ទ្ធចោលដោយគ្មាន មូលហេតុត្រឹមត្រូវបែបនេះ គឺជាទង្វើមិនត្រឹមត្រូវ ដូចនេះ ការដែលឲ្យភាគីម្ខាងទន្ទឹងរង់ចាំទាំងបែបនេះមិន យុត្តិធម៌ឡើយ។ មនុស្សម្នាក់ៗគួរតែទទួលបានសិទ្ធិ និង សេរីភាព និង

---

[15] ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦, មាត្រា៧។
[16] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា៩៧៨ (១)(ខ)។

សុភមង្គល ហេតុនេះការដែលទទួលរង ការបោះបង់ចោលដោយសហព័ទ្ធ ទាំងដែលទង្វើនោះគ្មានមូលហេតុត្រឹមត្រូវទាល់តែសោះ ភាគីរងគ្រោះអាច លើកចំណុចនេះជាមូលហេតុ នៃបណ្តឹងទាមទារលែងលះបាន។

**ឧទាហរណ៍៖** លោក ថា និងលោកស្រី នី ជាប្តីប្រពន្ធនឹងគ្នា។ ស្រាប់តែថ្ងៃមួយលោកស្រី នី បានចុះ ចេញពីផ្ទះចោលលោក ថា រួចទៅរស់នៅជាមួយឪពុកម្តាយរបស់លោកស្រីវិញដោយមិនបានឈ្លោះប្រកែកគ្នាអ្វីសោះឡើយ។ លោកស្រី នី បានចុះចេញដោយស្ងាត់ៗ ដោយមិនមានមូលហេតុត្រឹមត្រូវនោះទេ។ ក្នុងករណីនេះ ទង្វើរបស់លោកស្រី នី ដែលបានបោះបង់សហព័ទ្ធចោលដោយមិនបានប្រាប់ពីមូលហេតុបែបនេះ គឺជាហេតុដែលនាំឲ្យភាគីម្ខាងទៀតគឺលោក ថា ដែលជាប្តីរបស់លោកស្រី នី នោះអាចដាក់ពាក្យបណ្តឹងសុំលែងលះពី លោកស្រី នី ទៅតុលាការបាន។

## ១.៣.៣. ការមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ឬរស់អស់រយៈពេលជាងមួយឆ្នាំ

សហព័ទ្ធណាម្ខាងដែលមិនបានផ្តល់ដំណឹងដល់សហព័ទ្ធម្ខាងទៀតអំពីដំណើររបស់ខ្លួនដែលបានចេញទៅអស់រយៈពេលលើសពី១ឆ្នាំនោះ សហព័ទ្ធម្ខាងទៀតដែលនៅរងចាំអាចដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីលែងលះ ឬអាចស្នើសុំទៅតុលាការដើម្បីរំលាយចំណងអាពាហ៍ពិពាហ៍ចោលដោយបញ្ជាក់អោយច្បាស់ពីអំឡុងពេលដែលសហព័ទ្ធចេញទៅដោយមិនដឹងថាសហព័ទ្ធស្លាប់ ឬរស់។ បើមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ឬរស់អស់រយៈពេលជាង ១ឆ្នាំ ប្រសិនបើសហព័ទ្ធណាមួយបានចាកចេញ ឬចុះចោលសហព័ទ្ធម្ខាងទៀតដោយបាត់ដំណឹងសូន្យឈឹងគ្មានបានផ្តល់ដំណឹងអ្វីឱ្យសហព័ទ្ធម្ខាងទៀតឱ្យបានដឹងហើយបានចុះចោលជិតមួយឆ្នាំសហព័ទ្ធណាមួយអាចដាក់ពាក្យសុំលែងលះឬជូនដំណឹងទៅឃុំ/សង្កាត់ឱ្យបានដឹងពីរឿងនេះបាន។[17] ប្រការនេះគឺ ដើម្បីឲ្យសហព័ទ្ធម្ខាងមានសេរីភាពដើម្បីជ្រើសរើស និងរៀបអាពាហ៍ពិពាហ៍ថ្មីទៀត។ រយៈពេលជាងមួយឆ្នាំគឺ កំណត់ចាប់ពីពេលសហព័ទ្ធចាកចេញហើយមិនបានផ្តល់ដំណឹងថារស់នៅទីណា ឬស្លាប់។ ចំពោះករណីបុគ្គលដែលចូលទៅតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាដែល បានលិច ឬ បុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឱ្យទទួល មរណភាព ហើយពុំមានដំណឹងច្បាស់លាស់ថាអ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាព ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក្រោយពីចប់សង្គ្រាម ក្រោយពីនាវាបានលិច ឬ ក្រោយ ពីគ្រោះថ្នាក់ផ្សេងទៀតនោះ បានកន្លងផុតទៅ ។[18]

**ឧទាហរណ៍៖** លោក ជំនោរ និងលោកស្រី លីហ្សា ជាប្តីប្រពន្ធនឹងគ្នា។ ក្រោយពីបានរស់នៅជាមួយគ្នាសុខៗស្រាប់តែលោក ជំនោរ បានសម្រេចចិត្តចាកចេញពីស្រុកកំណើតដើម្បីទៅធ្វើការនៅក្រៅប្រទេស។ បន្ទាប់ពីថ្ងៃដែលលោក ជំនោរ បានចាកចេញទៅ គឺលោកស្រី លីហ្សា ទាក់ទងទៅលោកមិនបានសោះឡើយហើយក៏ពុំមានដំណឹងអ្វីពីលោកថានៅរស់ ឬ ក៏ស្លាប់ដោយសារមូលហេតុអ្វីនោះឡើយ។ ក្នុងករណីនេះបើលោក ជំនោរ

[17] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា៩៧៨ (១)(គ)។

[18] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា៤១ (២)។

បាត់ដំណឹងបែបនេះលើសពី ១ (មួយ) ឆ្នាំ នោះលោកស្រី លីហ្សា អាចដាក់ពាក្យបណ្ដឹងសុំលែងលះពីលោក ជំនោរ ទៅតុលាការបាន។

### ១.៣.៤. ការរស់នៅបែកបាក់គ្នារបស់សហព័ទ្ធអស់រយៈពេលមួយឆ្នាំ

ចំពោះការរស់នៅបែកគ្នារបស់សហព័ទ្ធក្នុងរយៈពេលលើសពីមួយឆ្នាំគឺជារយៈពេលមួយវែងទោះបីសហព័ទ្ធដឹងថាប្ដី ឬប្រពន្ធកំពុងរស់នៅទីកន្លែងណា។ ជាទូទៅពេលវេលាដែលបែកគ្នានោះត្រូវបន្តជាប់គ្នារហូត។ សហព័ទ្ធមិនមែនបានន័យថាត្រូវទៅណា ឬធ្វើអ្វីជាមួយគ្នា ឬក៏មិនអាចបែកគ្នានោះទេប៉ុន្តែត្រូវតែស្ថិតក្នុងអំឡុងពេល ឬរយៈពេលសមរម្យដែលសហព័ទ្ធអាចទទួលយកបាន និងមិនផ្ទុយពីគោលបំណង ឬឆន្ទៈរបស់អាពាហ៍ពិពាហ៍។ ប៉ុន្តែប្រសិនបើសហព័ទ្ធណាម្នាក់ត្រូវទៅរស់នៅឆ្ងាយដោយសារការប្រកបរករបររកស៊ីឬការងារណាមួយមិនចាត់ចូលចំណុចនេះទេ។[19]

គួរបញ្ជាក់ផងដែរថា មិនមែនរាល់ការរស់នៅឃ្លាតពីគ្នាលើសពីមួយឆ្នាំ សុទ្ធតែជាមូលហេតុនៃការលែងលះនោះទេ ព្រោះថាបើគ្រាន់តែប្ដី និងប្រពន្ធរស់នៅឃ្លាតពីគ្នាដោយមូលហេតុផ្សេងទៀតក្រៅពីទំនាស់មិនចុះសម្រុងគ្នា ជាពិសេសភាគីក៏គ្មានឆន្ទៈក្នុងការលែងលះ នោះមិនមែនអាចលើកជាមូលហេតុបានទេ។ ជាក់ស្ដែងនៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃមានប្ដី ឬ ប្រពន្ធខ្លះត្រូវរស់នៅទីទៃផ្សេងពីគ្នាដោយសារតែជាប់កាតព្វកិច្ចក្នុងការបំពេញការងារ, ជាប់បេសកកម្ម, ឬការបន្តការសិក្សានៅក្រៅប្រទេសជាដើម។ ការ រស់នៅបែកពីគ្នាទាំងនេះ ភាគីក៏មិនមានឆន្ទៈក្នុងការកាត់ផ្ដាច់ចំណងអាពាហ៍ពិពាហ៍ឡើយ គឺគ្រាន់តែឃ្លាត ដោយសារ តែកាលៈទេសៈតម្រូវមកបែបនោះ ហើយស្ថានភាពទាំងអស់នេះ នឹងមិនមែនជាមូលហេតុក្នុងការប្ដឹង ទាមទារលែងលះនោះទេ។

**ឧទាហរណ៍៖** ក្រោយពីលោក រុន និងលោកស្រី ឡៃន បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាអស់រយៈពេល ៤ (បួន) ឆ្នាំរួចមក លោក រុន និងលោកស្រី ឡៃន បានសម្រេចចិត្តរស់នៅបែកបាក់គ្នាដោយសារតែមានការអាក់អន់ស្រពន់ចិត្តនឹងគ្នាពីរឿងបន្តិចបន្តួច។ ហេតុនេះ ក្នុងករណីដែលអ្នកទាំងពីររស់នៅបែកគ្នាលើសពី ១ (មួយ) ឆ្នាំនោះភាគីណាម្ខាងអាចដាក់ពាក្យបណ្ដឹងសុំលែងលះទៅតុលាការបាន។

### ១.៣.៥. ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់

ក្នុងករណីផ្សេងទៀតដែលអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ហើយមិនមានសង្ឃឹមថានិងអាចស្រោចស្រង់មកវិញបាន។[20] ជាមួយគ្នានេះដែរចំពោះកំហុសដែលអាចចាត់ទុកថាមានលក្ខណៈធ្ងន់ធ្ងរដែលមិនអាចឱ្យភាគីទាំងពីរស្ដារអោយដូចដើមឡើងវិញបាននោះមានដូចជា ការជេរប្រមាថ ការប្រើប្រាស់អំពើហិង្សា ការចំណាយប្រាក់ខ្ជះខ្ជាយដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួន ការជំពាក់បំណុលគេដោយគ្មានមូលហេតុត្រឹមត្រូវ

---

[19] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា៩៧៨ (១)(ឃ)។

[20] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា៩៧៨ (១)(ង)។

ការចុះចោលលំនៅសង្វាសដោយឥតមូលហេតុត្រឹមត្រូវ ហើយឥតមានផ្គត់ផ្គង់ស្បៀងអាហារ និងទំនុកបំរុងកូន ធ្វើទុក្ខបុកម្នេញ ប្រមាថមើលងាយធ្ងន់ធ្ងរ ចំពោះសហព័ទ្ធឬបុព្វញាត្តិរបស់សហព័ទ្ធ ចរិយាផ្ទុយពីសីលធម៌ ការប្រព្រឹត្តអានាចារ អពលានុភាពនៃលិង្គនិងបែកគ្នាអស់រយៈពេលជាង ១ឆ្នាំដែលទាំងអស់នេះជាមូលហេតុ ដែលបណ្តាលឱ្យមានការបែកបាក់ និងមិនអាចស្តារឡើងវិញបានទេ។ មូលហេតុនៃការធ្វើឲ្យអាពាហ៍ពិពាហ៍ត្រូវ បានបែកបាក់ ការចុះចោលលំនៅសង្វាសដោយឥតមូលហេតុត្រឹមត្រូវ ហើយឥតមានផ្គត់ផ្គង់ស្បៀងអាហារ និង ទំនុកបំរុងកូនសោះ វាយដំ ឃោរឃៅ ធ្វើទុក្ខបុកម្នេញ ប្រមាថមើលងាយធ្ងន់ធ្ងរចំពោះសហព័ទ្ធ ឬ ចំពោះ បុព្វញាតិរបស់ សហព័ទ្ធ មានចរិយាផ្ទុយពីសីលធម៌ ឬ ប្រព្រឹត្តអនាចារ អពលានុភាពនៃលិង្គ បែកគ្នាអស់រយៈ ពេលជាង ១ ឆ្នាំ។[21]

នៅក្នុងសង្គមនៃប្រទេសកម្ពុជាសព្វថ្ងៃ មូលហេតុកើតចេញពីឆន្ទៈរបស់ភាគីដោយ ព្រមព្រៀងទាំងពីរ ច្រើនតែពួកគាត់បាត់បង់នូវមនោសញ្ចេតនារវាងគ្នា នៅក្នុងចំណងអាពាហ៍ពិពាហ៍ ដោយមាន មូលហេតុផ្ទាល់ខ្លួន ហើយភាគីបានដឹងយ៉ាងច្បាស់ថា ចំណងអាពាហ៍ពិពាហ៍នោះគ្មានសង្ឃឹម ក្នុងការផ្សះផ្សា ឬ ធ្វើបដិទានឲ្យត្រូវគ្នាវិញ ហើយជះឥទ្ធិពលធ្ងន់ធ្ងរឲ្យភាគីមិនអាចបន្តរួមរស់ជាមួយគ្នាទៀតបាន រហូតឈានដល់ ការព្រមព្រៀងគ្នាដាក់ពាក្យស្នើសុំលែងលះ។ សរុបមកបង្ហាញថាចំណុចចុងក្រោយនៃមូលហេតុទាមទារលែងលះ ច្បាប់រដ្ឋប្បវេណី បានចែងក្នុងន័យទូលាយ សម្រាប់ឲ្យពលរដ្ឋមានសិទ្ធិលើកឡើងនូវមូលហេតុផ្សេងៗ ជាច្រើន ដែលសមហេតុផល មកកំណត់ជាមូលហេតុក្នុងការប្តឹងទាមទារលែងលះពីតុលាការ។

ក្រោយពីបានយល់ដឹងពីកត្តាផ្សេងៗដែលនាំឲ្យមានការលែងលះជាបន្តយើងនឹងបន្តបកស្រាយពី នីតិវិធីនៃការលែងលះដោយមានការព្រមព្រៀងបន្ថែមទៀត។

[21] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៣៩។

# ជំពូកទី២
# នីតិវិធីនៃការលែងលះ

## ២.១. នីតិវិធីនៃការលែងលះដោយមានការព្រមព្រៀង

នីតិវិធីលែងលះចាប់ផ្ដើម នៅពេលដែលពាក្យសុំលែងលះបានដាក់ទៅតុលាការ បន្ទាប់មកពាក្យសុំលែងលះនោះត្រូវបានពិនិត្យដោយក្រឡាបញ្ជីថាពិតជាត្រឹមត្រូវទៅតាមទម្រង់ដែលច្បាប់បានកំណត់ហើយ ឬនៅ។

ការលែងលះអាចធ្វើឡើងដោយដាក់ពាក្យបណ្ដឹងទៅតុលាការដែលមានសមត្ថកិច្ចដោយផ្ទាល់ក៏បាន ឬ អាចដាក់ពាក្យសុំលែងលះទៅក្រុមប្រឹក្សាឃុំសង្កាត់ខាងលំនៅឋាន ឬ ទីសំណាក់របស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធនឹងបណ្ដឹងនោះក៏បាន។[22] ក្នុងករណីនេះក្រុមប្រឹក្សាឃុំសង្កាត់អាចធ្វើការបញ្ចុះបញ្ចូលឱ្យសះជាគ្នាបានក្នុងអំឡុងពេល ១៥ថ្ងៃបន្ទាប់ពីទទួលបានពាក្យសុំនោះ។ បើមិនអាចបញ្ចុះបញ្ចូលឱ្យសះជាគ្នាបានទេត្រូវចាត់ទុកថាមានពាក្យបណ្ដឹងលែងលះគ្នាហើយក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបញ្ជូនពាក្យបណ្ដឹងនេះទៅតុលាការជាបន្ទាន់។[23] មានន័យថាបើសិនជាអាពាហ៍ពិពាហ៍នោះធ្វើឡើងដោយស្របច្បាប់ការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍នោះចាំបាច់ត្រូវទទួលបានសេចក្ដីសម្រេចពីតុលាការទោះបីជាមានការព្រមព្រៀងពីការលែងលះរវាងភាគីទាំងសងខាងក៏ដោយ។ ម្យ៉ាងទៀតទោះបីជាទៅដល់តុលាការក៏ដោយក៏តុលាការអាចធ្វើការសាកល្បងផ្សះផ្សាបានដែរ។[24]

### ២.១.១. ការសម្ដែងឆន្ទៈក្នុងការលែងលះ

ការសម្ដែងឆន្ទៈចុះកិច្ចសន្យាអាចធ្វើឡើងក្រោមទម្រង់ចំនួនពីរ គឺជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់។

- ទម្រង់ជាលាយលក្ខណ៍អក្សរៈ ភាគីប្ដីប្រពន្ធអាចរៀបចំកិច្ចព្រមព្រៀងលែងលះគ្នាជាមុនហើយភ្ជាប់ទៅជាមួយពេលយកពាក្យសុំទៅដាក់នៅតុលាការ។ ជាទូទៅកិច្ចព្រមព្រៀងនេះភាគច្រើនសរសេរខ្លឹមជាសារធាតុចម្បងគឺឆន្ទៈនៃការព្រមព្រៀងលែងលះ និងជាយថាហេតុការបែងចែកសិទ្ធិអំណាចមេបាលើកូន ការចូលជួបប្រាស្រ័យទាក់ទងជាមួយកូន បន្ទុកសោហ៊ុយ ចំណាយដើម្បីចិញ្ចឹមបីបាច់ ថែរក្សាកូន ការបែងចែកទ្រព្យសម្បត្តិរួម និងការនាំយកពាក្យសុំទៅដាក់នៅតុលាការមានសមត្ថកិច្ចដើម្បីទទួលបានដីកាសម្រេចជាអាទិ៍ ។
- ទម្រង់ដោយផ្ទាល់មាត់ៈ ទម្រង់នេះភាគច្រើនត្រូវបានប្រើប្រាស់ដោយប្រជាជនដែលមិនសូវយល់ដឹងពីច្បាប់ និងមិនមានលទ្ធភាពពឹងពាក់មេធាវី។ តាមរយៈទម្រង់នេះនៅពេលដែលប្ដីប្រពន្ធសម្រេចថាលែងលះគ្នា ពួកគាត់បណ្ដើរគ្នាទៅតុលាការហើយថ្លែងការណ៍អំពីឆន្ទៈនៃការព្រមព្រៀងលែងលះរបស់ខ្លួននៅចំពោះមុខក្រឡាបញ្ជីដែលទទួលពាក្យសុំនោះតំណាលគ្នានឹងពេលដាក់ពាក្យសុំ។

---

[22] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា៩៨២ (១)។

[23] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា៩៨២ (២)។

[24] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា៩៨៥។

នៅក្នុងលិខិតនៃពាក្យសុំត្រូវសរសេរបញ្ជាក់នូវចំណុចដូចជា ៖ **ក.** ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំហើយនិងឈ្មោះនិងអាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។ ព្រមទាំង **ខ.** ខ្លឹមសារនៃដីកាសម្រេច ឬ សកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំទាមទារ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ។ ដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំ ត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុចនីមួយៗដែលកំណត់ក្នុងកថាខណ្ឌទី២ ខាងលើនេះនៅចំពោះមុខក្រឡាបញ្ជី។ ក្នុងករណីនេះក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និងចុះហត្ថលេខា។ កំណត់ហេតុនេះត្រូវចាត់ទុកជាលិខិតពាក្យសុំ។ ក្នុងករណីដែលមានឯកសារជាភស្តុតាងអ្នកដាក់ពាក្យសុំត្រូវភ្ជាប់មកជាមួយនូវឯកសារដើម ឬ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ជាមួយនឹងលិខិតនៃពាក្យសុំ ឬ ត្រូវដាក់ជូនឯកសារទាំងនោះទៅតុលាការនៅពេលដាក់ពាក្យសុំ។[25]

### ២.១.២. ពាក្យសុំលែងលះ

ការដាក់ពាក្យសុំលែងលះអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បានលើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះឬ ច្បាប់ផ្សេងទៀត។[26] ដោយក្នុងពាក្យសុំលែងលះនោះមានលក្ខណៈគតិយុត្តដែលត្រូវមានគោលបំណងនិងមូលហេតុនៃបណ្តឹងច្បាស់លាស់និងស្របតាមនីតិវិធី។ ហើយពាក្យសុំលែងលះអាចធ្វើឡើងដោយភាគីផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលអាណត្តិរបស់ខ្លួន។ នៅក្នុងពាក្យសុំលែងលះដោយការព្រមព្រៀងរបស់សហព័ទ្ធដែលមានគោលបំណងចង់ដាក់ពាក្យសុំលែងលះអាចដាក់ពាក្យទៅតុលាការប៉ុន្តែត្រូវបំពេញទម្រង់បែបបទនៃការដាក់ពាក្យសុំទៅតាមបញ្ញត្តិច្បាប់ដែលបានកំណត់។

#### ក. ពាក្យសុំជាលាយលក្ខណ៍អក្សរ

ចំពោះការដាក់ពាក្យសុំលែងលះត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរទៅតុលាការ។ ម្យ៉ាងវិញទៀតអ្នកដាក់ពាក្យសុំ ឬ អ្នកតំណាងដោយអាណត្តិត្រូវរៀបចំលិខិតនៃពាក្យបណ្តឹងមុននឹងដាក់ទៅតុលាការដោយត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោម៖[27]

- ឈ្មោះឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគីដែលដាក់ពាក្យសុំះហើយប្តីឬប្រពន្ធដែលយកពាក្យសុំមកដាក់ត្រូវសរសេរឈ្មោះ ភេទ អាយុ សញ្ជាតិ និងត្រូវសរសេរ (ផ្ទះលេខ....ផ្លូវ......ក្រុម.....ភូមិ... ឃុំ/ សង្កាត់...ស្រុក/ខណ្ឌ...ខេត្ត/រាជធានី...អាសយដ្ឋាន) នៅក្នុងពាក្យសុំលែងលះ។ ប៉ុន្តែបើមានអ្នកតំណាងដោយអាណត្តិដែលច្បាប់បានកំណត់ត្រូវសរសេរឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដោយអាណត្តិនោះក្នុងពាក្យសុំផងដែរ។

[25] ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០,មាត្រា២៦។

[26] ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០,មាត្រា២៦ (១)។

[27] ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០,មាត្រា២៦ (២)។

- ខ្លឹមសារនៃសាលក្រមឬដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារៈ ជាការសរសេរឡើងនូវអ្វីដែលអ្នកដាក់ពាក្យសុំលែងលះបានទាមទារជាមួយគ្នានេះដែរក៏បញ្ជាក់អំពីទំហំនៃរឿងក្ដីដែលត្រូវអោយតុលាការលើកយកមកវិនិច្ឆ័យនិងសម្រេចសេចក្ដីផងដែរ។ ទាក់ទិននឹងខ្លឹមសារនៃការសរសេរពាក្យសុំលែងលះនេះដើមបណ្ដឹងត្រូវសរសេរអោយបានច្បាស់លាស់នូវអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារផ្សេងៗទៅកាន់តុលាការដូចជាការបែកចែកទ្រព្យសម្បត្តិ ឬការបែកចែកសិទ្ធិអំណាចមេបា ការទទួលបន្ទុកអាហារកិច្ច ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនជាអាទិ៍
- អង្គហេតុដែលជាមូលហេតុនៃការទាមទារៈ គឺសរសេរពីមូលដ្ឋានគតិយុត្តនៃការទាមទាររបស់ភាគី។ នៅក្នុងរឿងក្ដីលែងលះដោយការព្រមព្រៀងមូលដ្ឋានគតិយុត្តនៃការទាមទារដើម្បីលែងលះបានគឺអង្គហេតុនៃការកើតឡើងនៃចំណងអាពាហ៍ពិពាហ៍ ដែលបានបញ្ជាក់តាមសំបុត្រអាពាហ៍ពិពាហ៍ និងអង្គហេតុនៃការសម្ដែងឆន្ទៈនៃការព្រមព្រៀងលែងលះគ្នាដែលបញ្ជាក់ដោយកិច្ចព្រមព្រៀង ឬការអះអាងរបស់ភាគី។ ម៉្យាងទៀតការចាត់ចែងអំណាចមេបាលើកូនក៏ជាអង្គហេតុដែលអាចទាមទារឲ្យតុលាការសម្រេចចាត់ចែងចំពោះកូនផងដែរ។ លើសពីនេះទៀត គឺជាអង្គហេតុដែលអាចទាមទារឲ្យមានការចាត់ចែងទ្រព្យសម្បត្តិសំដៅលើអង្គហេតុដែលបញ្ជាក់ពីការមានទ្រព្យសម្បត្តិរួមគ្នា(ទ្រព្យសកម្ម និងទ្រព្យអកម្ម) ដែលអង្គហេតុបញ្ជាក់ដោយឯកសារនានាដូចជាប័ណ្ណសម្គាល់សិទ្ធិម្ចាស់អចលនវត្ថុ ឬលិខិតសម្គាល់ម្ចាស់យានយន្តជាអាទិ៍។[28]

បណ្ដឹងលែងលះត្រូវភ្ជាប់មកជាមួយសំបុត្រអាពាហ៍ពិពាហ៍និងឯកសារពាក់ព័ន្ធផ្សេងៗរវាងសហព័ទ្ធទាំងពីរ។

### ខ. ពាក្យសុំដោយផ្ទាល់មាត់

សហព័ទ្ធដែលមានបំណងចង់ដាក់ពាក្យសុំលែងលះតែមានកិច្ចការចាំបាច់ណាមួយដែលមិនបានបំពេញទៅតាមលក្ខខណ្ឌទម្រង់ខាងលើដូចនេះពួកគាត់អាចធ្វើការដាក់ពាក្យសុំដោយផ្ទាល់មាត់ដោយគ្រាន់តែអ្នកដាក់ពាក្យសុំត្រូវធ្វើតាមសេចក្ដីថ្លែងការណ៍នូវចំណុចដែលបានរៀបរាប់ខាងលើនេះនៅចំពោះមុខក្រឡាបញ្ជីដែលទទួលពាក្យសុំ។ ហើយក្រឡាបញ្ជីត្រូវធ្វើការកត់ត្រាទុកនៅក្នុងកំណត់ហេតុ និងចុះហត្ថលេខា។ កំណត់ហេតុនោះត្រូវចាត់ទុកជាលិខិតនៃពាក្យសុំ។[29] កាតព្វកិច្ចដែលសហព័ទ្ធត្រូវធ្វើនោះគឺធ្វើនៅសេចក្ដីថ្លែងការណ៍អំពីឈ្មោះរបស់ភាគីប្ដី និងប្រពន្ធ រួមទាំងអាសយដ្ឋាន ឬ អ្នកតំណាង(ប្រសិនបើមានអ្នកតំណាង) និងឯកសារដូចជាសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍សំបុត្របញ្ជាក់កំណើតកូន ឬឯកសារនានាដែលបញ្ជាក់ពីទ្រព្យសម្បត្តិជាដើម។ បន្ថែមពីនេះទៅទៀតការដាក់ពាក្យសុំដោយផ្ទាល់មាត់នេះភាគីនៅតែចាំបាច់ធ្វើសេចក្ដីថ្លែងការណ៍អំពីខ្លឹមសារនៃការទាមទារដែលចង់ឲ្យតុលាការចេញសេចក្ដីសម្រេច គួបផ្សំជាមួយនឹងអង្គហេតុផ្សេងៗដែលមូលហេតុនាំឲ្យមានការស្នើសុំលែងលះ។ គាត់ត្រូវដាក់ជូនតុលាការនូវឯកសារច្បាប់ដើម ឬឯកសារដែលមានសេចក្ដីបញ្ជាក់ដើម្បីឱ្យតុលាការងាយស្រួលក្នុងការត្រួតពិនិត្យ និងឆាប់ទទួលបានសេចក្ដីសម្រេច។

[28] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា៧៥។

[29] ច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង,លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០,មាត្រា២៦ (៣)។

### ២.១.៣. សមត្ថកិច្ចដោះស្រាយតាមរយៈក្រុមប្រឹក្សាឃុំ-សង្កាត់

ភាគីអាចដាក់ពាក្យសុំលែងលះទៅកាន់ក្រុមប្រឹក្សាឃុំ-សង្កាត់ខាងលំនៅដ្ឋានរបស់សហព័ទ្ធទាំងពីរ ឬទីសំណាក់ដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ និង ទី៣ នៃមាត្រា១០ (សមត្ថកិច្ចសាលាជម្រះក្តីពិសេសលើរឿងក្តីលែងលះគ្នា និងរឿងក្តីអំពីបុត្តភាព) នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន។[30] ក្នុងដំណាក់កាលនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់ ដើរតួជាអ្នកផ្សះផ្សា បញ្ចុះបញ្ចូលគូភាគីជាមុនសិន។ ដូចនេះក្រុមប្រឹក្សា ឃុំ-សង្កាត់ត្រូវខិតខំក្នុងការសម្របសម្រួលធ្វើយ៉ាងណាអោយភាគីទាំងសងខាងស្រុះស្រួលគ្នាក្នុងអំឡុងពេល ១៥ថ្ងៃតាមការកំណត់របស់ច្បាប់បន្ទាប់ពីទទួលពាក្យសុំនោះ។ បើមិនអាចបញ្ចុះបញ្ចូលអោយសះជាគ្នាបានទេត្រូវចាត់ទុកថាមានពាក្យបណ្តឹងលែងលះគ្នាហើយក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបញ្ជូនពាក្យបណ្តឹងនោះទៅតុលាការជាបន្ទាន់។[31]

នៅក្នុងដំណាក់កាលនេះក្រុមប្រឹក្សាឃុំ-សង្កាត់ពុំមានសមត្ថកិច្ចក្នុងការធ្វើសេចក្តីសម្រេចឱ្យគូភាគីលែងលះគ្នា ការបែងចែកទ្រព្យសម្បត្តិ ការកំណត់អ្នកមានអំណាចមេបាលើកូន និងការបង់អាហារកាតព្វកិច្ចឡើយ។ គោលបំណងនៃការផ្សះផ្សា គឺដើម្បីឱ្យបុគ្គលទាំងពីរត្រូវគ្នា ឬសះជាគ្នាវិញដើម្បីបន្តការរស់នៅជាប្តីប្រពន្ធសារជាថ្មី។ នៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារក៏បានចែងអំពីការផ្សះផ្សារបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ផងដែរ។ គណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ត្រូវធ្វើការផ្សះផ្សារយៈពេល ១៥ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្តឹង។ បើផ្សះផ្សាពុំបានសម្រេចត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅតុលាការប្រជាជនខេត្ត-ក្រុង។[32] នៅពេលដែលផ្សះផ្សាគូភាគីត្រូវគ្នាវិញហើយក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវធ្វើកំណត់ហេតុអំពីអ្វីដែលគូភាគីបានសះជានឹងគ្នា និងធ្វើលិខិតកិច្ចសន្យាឱ្យគូភាគីទាំងពីរទទួលយកពីការផ្សះផ្សានេះ។ ប៉ុន្តែប្រសិនបើការខិតខំផ្សះផ្សា របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ពុំបានសម្រេចទេហើយគូភាគីនៅតែទាមទារចង់ធ្វើការលែងលះនិងគ្មានសង្ឃឹមថាអាចសះជាគ្នាទេដូច្នេះក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបញ្ជូនពាក្យសុំទៅតុលាការដើម្បីឱ្យតុលាការធ្វើចំណាត់ការបន្ត។

ចំពោះដំណាក់កាលនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់មិនមានសមត្ថកិច្ចអ្វីសម្រេចអោយ គូភាគីលែងលះគ្នា បែកចែកទ្រព្យសម្បត្តិ កំណត់អំណាចមេបា និងការបង់អាហារកិច្ចនោះឡើង។ ការដាក់ពាក្យសុំទៅក្រុមប្រឹក្សាឃុំ-សង្កាត់គ្រាន់តែជាជម្រើសរបស់ភាគីប៉ុណ្ណោះ ពោលគឺសហព័ទ្ធអាចដាក់ពាក្យសុំដោយផ្ទាល់ទៅកាន់តុលាការមានសមត្ថកិច្ចតែម្តង។

[30] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា៩៨២។

[31] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា៩៨២ (២)។

[32] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៤២។

## ២.១.៤. សមត្ថកិច្ចដោះស្រាយតាមរយៈតុលាការ

បន្ទាប់ពីក្រុមប្រឹក្សាឃុំ-សង្កាត់ខិតខំធ្វើការផ្សះផ្សាតែមិនបានសម្រេចនោះពាក្យសុំនឹងត្រូវបញ្ជូនបន្តទៅកាន់តុលាការ នៃលំនៅដ្ឋានរបស់សហព័ទ្ធ។ យោងទៅតាមមាត្រា៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ សមត្ថកិច្ចសាលាជម្រះក្ដីដែលបានកំណត់ទៅតាមលំនៅដ្ឋានជាអាទិ៍បណ្ដឹងចំពោះចុងចម្លើយដែលបានកំណត់អំពីលំនៅដ្ឋានរបស់ចុងចម្លើយទីសំណាក់បើពុំមានលំនៅដ្ឋាន ឬមានលំនៅដ្ឋានមិនពិតប្រាកដនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងលំនៅដ្ឋានចុងក្រោយបើពុំមានទីសំណាក់ឬ មានទីសំណាក់មិនពិតប្រាកដ។[33] បន្ទាប់មកតុលាការនឹងបន្តចំណាត់ការនេះព្រោះមានតែតុលាការប៉ុណ្ណោះដែលមានសិទ្ធិគ្រប់គ្រាន់ក្នុងការសម្រេចអោយគូភាគីលែងលះគ្នា ឬមិនអាចលែងលះគ្នាបានដោយចេញដីកាសម្រេចតាមពាក្យសុំ។ តុលាការប្រជាជនខេត្ត-ក្រុងត្រូវអញ្ជើញអ្នកប្ដឹងអោយចូលមកហើយសម្រួលយ៉ាងណាតាមដែលខ្លួនយល់ឃើញដើម្បីបញ្ចូលចិត្តអ្នកនោះអោយឈប់ប្ដឹងលើកលែងតែតុលាការប្រជាជនខេត្ត-ក្រុងយល់ឃើញថាពាក្យសុំលែងលះគ្នានេះមានអង្គហេតុធ្ងន់ធ្ងរណាស់។[34] តុលាការអាចសាកល្បងធ្វើការផ្សះផ្សា ទោះបីជាបណ្ដឹងស្ថិតក្នុងដំណាក់កាលណាមួយក៏ដោយ។[35] ទោះបីជាភាគីម្ខាងទាមទារយ៉ាងខ្លាំងចំពោះការលែងលះគ្នាក៏ដោយ តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន។[36]

### ក. ការទទួលពាក្យបណ្ដឹង

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងបានផ្ដល់សមត្ថកិច្ចឱ្យការិយាល័យកិច្ចការតុលាការទទួលបន្ទុកលើការទទួលចាត់ចែងឯកសារចេញចូលរបស់សាលាដំបូង និង ចុះបញ្ជីពាក្យបណ្ដឹង និងចាត់ចែងបន្តតាមនីតិវិធី។[37] ហេតុដូចនេះនៅពេលភាគីដាក់ពាក្យបណ្ដឹងលែងលះអាច ដាក់ពាក្យបណ្ដឹងនៅលេខាធិការដ្ឋានរដ្ឋបាលរបស់សាលាដំបូងដែលមានសមត្ថកិច្ចនោះបាន។

នៅពេលដែលដាក់ពាក្យបណ្ដឹងត្រូវបង់ពន្ធលើពាក្យបណ្ដឹងដែលដើមចោទត្រូវបង់ពន្ធលើពាក្យបណ្ដឹងនោះចំនួន ៥៥០០០ (ប្រាំម៉ឺនប្រាំពាន់) រៀល។[38] ចំណែកឯការបង់ពន្ធលើប្រាក់ប្រដាប់ក្ដីត្រូវបង់ដែលមានចំនួនប្រែប្រួលទៅតាមការកំណត់របស់តុលាការ និងធ្វើការបង់ជាមុនសម្រាប់ការចំណាយរបស់តុលាការដែលធ្វើសកម្មភាពតាមនីតិវិធីបណ្ដឹងដើម្បីឱ្យតុលាការៈ

- ធ្វើការពិនិត្យភស្ដុតាងការបញ្ជូនឯកសារ ឬសកម្មភាពផ្សេងទៀតតាមនីតិវិធីបណ្ដឹង។

[33] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៨។
[34] ច្បាប់ស្ដីអាព៌ាពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៤៨។
[35] នីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៩៧។
[36] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា៩៨៤។
[37] អនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង,ចំណុចទី១។
[38] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦០។

- សោហ៊ុយធ្វើដំណើរ និងសោហ៊ុយស្នាក់នៅដែលចាំបាច់សម្រាប់ចៅក្រម និងក្រឡាបញ្ជីក្នុងករណីដែល ធ្វើការពិនិត្យភស្តុតាងការស្រាវជ្រាវអង្គហេតុ ឬសកម្មភាពផ្សេងទៀតដែលប្រព្រឹត្តទៅនៅក្រៅតុលាការ។ ក្នុងករណីដែលភាគីបានដាក់ពាក្យបណ្តឹងមិនបានបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធទេនោះតុលាការនិងលើកពាក្យបណ្តឹងចោលដោយដីកាសម្រេច។[39]

នៅពេលដែលសហព័ន្ធដើមចោទបានដាក់ពាក្យបណ្តឹងទៅតុលាការហើយក្រឡាបញ្ជីជាអ្នកមានភារៈក្នុងការទទួលពាក្យបណ្តឹងបន្ទាប់មកក្រឡាបញ្ជីត្រូវតែអនុវត្តតាមជំហានដូចខាងក្រោម៖

- ការវាយត្រាលើពាក្យបណ្តឹងដែលបានទទួលនោះរួចធ្វើការចុះថ្ងៃ ខែ ឆ្នាំដែលបានទទួលពាក្យបណ្តឹង
- បន្ទាប់មកចុះលេខរៀងនៅក្នុងសៀវភៅបណ្តឹងផងដែរ
- បន្ទាប់មកក្រឡាបញ្ជីត្រូវយកក្របសំបុត្រសំណុំរឿងមកគៀបសំណុំរឿងនោះរួចហើយបញ្ជូនសំណុំរឿងតុលាការ។

ដើម្បីចៀសវាងពាក្យបណ្តឹងមានលក្ខណៈខ្វះខាតនូវចំណុចដែលបានកំណត់តាមបញ្ញត្តិច្បាប់ដែលតម្រូវអោយសរសេរពាក្យបណ្តឹងនោះគេអនុញ្ញាតអោយក្រឡាបញ្ជីមានយោបល់ចំពោះបញ្ហានៃការខ្វះខាតបានក្នុងការពន្យល់ដល់អ្នកដែលបានដាក់ពាក្យបណ្តឹងដែលបានប្រព្រឹត្តនូវចំណុចខ្វះខាតដូចជាឈ្មោះ ឬនាមករណ៍និងអាសយដ្ឋានរបស់ភាគីហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។[40]

ក្រឡាបញ្ជីមិនមានសិទ្ធិខាងផ្លូវច្បាប់ក្នុងការពិនិត្យពាក្យបណ្តឹងទេតែដោយក្រឡាបញ្ជីជាបុគ្គលដែលមានវិជ្ជាជីវៈខាងផ្លូវច្បាប់ផងដែរ ដូចនេះគាត់អាចសម្រួលដល់អ្នកដាក់ពាក្យបណ្តឹងដោយផ្តល់យោបល់ខ្លះៗហើយបង្ហាញនូវហេតុផលសមរម្យដូចជាប្រាប់នូវកង្វះខាតត្រង់ចំណុចណាខ្លះដើម្បីចៀសវាងការយឺតយ៉ាវ។ ដូចនេះហើយទោះបីជាបណ្តឹងរបស់សហព័ន្ធមានលក្ខណៈខ្វះខាត ឬ មិនត្រឹមត្រូវត្រង់ចំណុចណាក៏ដោយក៏ក្រឡាបញ្ជីត្រូវទទួលពាក្យបណ្តឹងដោយអនុវត្តតាមជំហាននៃកិច្ចការរបស់ខ្លួន ដោយមិនអាចធ្វើការបដិសេដមិនទទួលពាក្យបណ្តឹងរបស់សហព័ន្ធបានទេ ដោយហេតុថាបណ្តឹងនោះមិនមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ទេ។

### ខ. ការពិនិត្យពាក្យបណ្តឹង

ចំពោះការពិនិត្យពាក្យបណ្តឹងគឺ ការពិនិត្យទៅលើភាពស្រប ឬ មិនស្របទៅនឹងលក្ខខណ្ឌនៃទម្រង់តែប៉ុណ្ណោះ។ បើចៅក្រមពិនិត្យឃើញថាពាក្យបណ្តឹងបានគោរពតាមលក្ខខណ្ឌត្រឹមត្រូវអង្គហេតុច្បាស់លាស់មានបញ្ជាក់ពីចំណុចសំខាន់ៗដែលត្រូវសរសេរនៅក្នុងពាក្យបណ្តឹងរួចរាល់ហើយចៅក្រមទទួលពាក្យបណ្តឹងលែងលះមិនចាំបាច់បង្គាប់អោយភាគីដែលជាសហព័ន្ធដើមចោទធ្វើការកែតម្រូវនៅក្នុងបណ្តឹងទៀតឡើយ។ ប្រសិនបើក្នុងករណីដែលពាក្យបណ្តឹងផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៧៥ (របៀបដាក់ពាក្យបណ្តឹង និង

[39] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦២។

[40] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៥។

ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង)ខាងលើនេះតុលាការត្រូវកំណត់អំឡុងពេលសមរម្យ និងបង្គាប់ឱ្យកែតម្រូវចំណុចខ្វះចំពោះពាក្យបណ្តឹងនោះក្នុងអំឡុងពេលនោះបញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរចំពោះករណីដែលពន្ធសម្រាប់ដាក់ពាក្យបណ្តឹងមិនត្រូវបានបង់តាមបញ្ញត្តិនៃមាត្រា៦១(ពន្ធដាក់ពាក្យសុំ)នៃក្រមនេះផ្ទុយទៅវិញក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះប្រសិនបើដើមចោទមិនបានកែតម្រូវចំណុចខ្វះទេតុលាការត្រូវលើកពាក្យបណ្តឹងចោលដោយដីកាសម្រេច។[41]

### គ. ការបញ្ជូនពាក្យបណ្តឹង

ក្នុងដំណាក់កាលនេះតុលាការបានធ្វើការពិនិត្យពាក្យបណ្តឹងនៃការលែងលះរួចហើយតែប្រសិនបើតុលាការយល់ឃើញថាបណ្តឹងនោះបានបំពេញតាមលក្ខណៈគ្រប់គ្រាន់ហើយនោះតុលាការត្រូវធ្វើការបញ្ជូនពាក្យបណ្តឹងទៅសហព័ទ្ធចុងចម្លើយជាចាំបាច់។[42] ព្រោះថាការបញ្ជូនពាក្យបណ្តឹងនេះជាការផ្តល់ឱកាសអោយសហព័ទ្ធម្ខាងទៀតបានដឹងអំពីបណ្តឹងថាតើបុគ្គលណាជាអ្នកប្តឹង កម្មវត្ថុនៃបណ្តឹងគឺជាអ្វី និងមធ្យោបាយតទល់របស់ដើមចោទជាដើមហើយក៏ជាការផ្តល់ឱកាសអោយសហព័ទ្ធចុងចម្លើយតបដោះសារនិងរៀបចំមធ្យោបាយសម្រាប់ការពារខ្លួនផងដែរ។ ហើយកិច្ចការបញ្ជូននេះត្រូវបានប្រតិបត្តិដោយបុគ្គលិកប្រៃសណីយ៍ ឬអាជ្ញាសាលា ឬក្រឡាបញ្ជី។[43]

### ២.១.៥. ការចេញដីការសម្រេច

តុលាការត្រូវចេញដីកាសម្រេចដោយពុំចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ឡើយព្រោះរឿងក្តីបែបនេះជារឿងក្តីមិនស្មុគស្មាញគ្មានចំណុចវិវាទដោយសារភាគីបានព្រមព្រៀងគ្នាហើយការលែងលះវាជាការសម្ងាត់របស់ភាគី ដូចនេះដើម្បីចេញដីកាសម្រេចឱ្យលែងលះតាមការព្រមព្រៀងគឺមិនចាំបាច់ត្រូវទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈឡើយ។ ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី២ នៃមាត្រា៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ត្រូវសរសេរសំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់ ហើយចៅក្រមត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចនេះ។[44]

ក្នុងសេចក្តីសម្រេចចៅក្រមត្រូវយោងទៅលើមូលដ្ឋានជាច្រើនក្នុងការសម្រេចចំណុចដំបូង ចៅក្រមត្រូវពិចារណាទៅលើស្ថានភាពគតិយុត្តនៃទំនាក់ទំនងរវាងប្តី និងប្រពន្ធនៃការលែងលះថាតើចំណងអាពាហ៍ពិពាហ៍របស់គាត់ត្រឹមត្រូវស្របតាមច្បាប់មានការទទួលស្គាល់ដោយច្បាប់ដែរ ឬអត់។ បុគ្គលទទួលឥទ្ធិពលដែលខូចប្រយោជន៍ដល់សិទ្ធិ ឬ ឋានៈគតិយុត្តរបស់ខ្លួនដោយសារដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះអំពីរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា៣ (វិសាលភាពនៃ

[41] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៨។

[42] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៩។

[43] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៤៦។

[44] ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា៣៥។

ច្បាប់នេះ) នៃច្បាប់នេះអាចប្ដឹងជំទាស់ចំពោះដីកាសម្រេចនោះបានលើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះក្នុងករណីដែលត្រូវចេញដីកាសម្រេចតាមតែពាក្យសុំប៉ុណ្ណោះមានតែជនដែលបានដាក់ពាក្យសុំទេដែលអាចប្ដឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំបាន។[45] មានន័យថាបន្ទាប់ពីចៅក្រមពិចារណាលើឆន្ទៈពិតក្នុងការលែងលះ ប្រសិនបើចៅក្រមស្វែងរកឃើញថាភាគីណាម្ខាងមិនមានឆន្ទៈព្រមព្រៀងពិតប្រាកដក្នុងការលែងលះទេ ចៅក្រមនឹងចេញដីកាសម្រេចលើកពាក្យសុំចោលដើម្បីបញ្ចប់នីតិវិធីលែងលះ។

ដីកាសម្រេចលើពាក្យសុំលែងលះដោយមានការព្រមព្រៀងរបស់ភាគីជាដីកាសម្រេចលើអង្គសេចក្ដីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី២ នៃមាត្រា៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះត្រូវជូនដំណឹងទៅជនដែលត្រូវទទួលដីកាសម្រេចនេះ។ ការជូនដំណឹងអំពីដីកាសម្រេចនេះត្រូវធ្វើឡើងតាមរយៈការបញ្ជូន ឬការផ្ញើជូនឯកសារចម្លងយថាភូតនៃដីកាសម្រេចនោះ។[46] ការជូនដំណឹងមិនចាំបាច់ត្រូវធ្វើដោយក្រឡាបញ្ជីជាអ្នកបញ្ជូនដោយផ្ទាល់ទេ គឺអាចធ្វើឡើងតាមរយៈការផ្ញើតាមប្រៃសណីយ៍ក៏បាន។ ប្រសិនបើជនដែលអាចប្ដឹងជំទាស់បានទទួលការជូនដំណឹងអំពីដីកាសម្រេចបណ្ដឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល២ (ពីរ) សប្ដាហ៍ដោយគិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ មួយវិញទៀតប្រសិនបើជនដែលអាចប្ដឹងជំទាស់ មិនមែនជាជនដែលត្រូវទទួលការជូនដំណឹងអំពីដីកាសម្រេចដោយយោងតាមបញ្ញត្តិនៃមាត្រា៣៦ (ការជូនដំណឹងអំពីដីកាសម្រេច) នៃច្បាប់នេះទេ បណ្ដឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ដោយគិតចាប់ពីថ្ងៃដែលជនដាក់ពាក្យសុំបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ។[47] មានន័យថាដីកាសម្រេចលើពាក្យសុំលែងលះតាមការព្រមព្រៀងក៏ដូចជាដីកាសម្រេចលើអង្គសេចក្ដីដែលមិនមែនជាបណ្ដឹងមានលក្ខណៈខុសគ្នានឹងដីកាសម្រេចនៅក្នុងបណ្ដឹងរដ្ឋប្បវេណីត្រង់ថាដីកាសម្រេច លើអង្គសេចក្ដីនៃរឿងក្ដីដែលមិនមែនជាបណ្ដឹងមានអានុភាពចូលជាស្ថាពរមិនមែនដោយការជូនដំណឹងទេគឺថាដីកាសម្រេចលើពាក្យសុំលែងលះតាមការព្រមព្រៀងក៏ដូចជាដីកាសម្រេចលើអង្គសេចក្ដីនៃរឿងក្ដីដែលមិនមែនជាបណ្ដឹងត្រូវបានចូលជាស្ថាពរមានអានុភាពអនុវត្តនៅពេលផុតរយៈពេលប្ដឹងជំទាស់មានរយៈពេល២សប្ដាហ៍គិតចាប់ពីបានទទួលការជូនដំណឹងអំពីដីការសម្រេចនោះ។

បន្ទាប់ពីបានយល់ដឹងពីនីតិវិធីនៃការលែងលះដោយមានការព្រមព្រៀងរួចមក ជាបន្តយើងនឹងបន្តបកស្រាយពីនីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀងតាមផ្លូវតុលាការបន្ថែមទៀត។

[45] ច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា៣៩។
[46] ច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា៣៦។
[47] ច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា៤០។

## ២.២. នីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀងតាមផ្លូវតុលាការ

ការលែងលះដោយគ្មានការព្រមព្រៀង ឬដោយមានបណ្តឹងត្រូវធ្វើឡើងនៅពេលដែលភាគីនៃចំណងអាពាហ៍ពិពាហ៍មិនបានព្រមព្រៀងគ្នាក្នុងការបញ្ចប់នូវចំណងអាពាហ៍ពិពាហ៍ ឬភាគីមានទំនាស់លើការបែងចែកសិទ្ធិ និងកាតព្វកិច្ចផ្សេងៗក្រោយការលែងលះ។ បណ្តឹងទាមទារលែងលះគ្នាតាមបញ្ញត្តិនៃមាត្រា៩៧៨ (មូលហេតុនៃការលែងលះគ្នា) នៃក្រមរដ្ឋប្បវេណី។[48] ការលែងលះដោយគ្មានការព្រមព្រៀង ឬដោយមានបណ្តឹងគឺស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។ ការលែងលះដោយគ្មានការព្រមព្រៀងនេះត្រូវឆ្លងកាត់ដំណាក់កាលនីតិវិធីរដ្ឋប្បវេណីជាច្រើនមុននឹងឈានដល់ការសម្រេចសេចក្តីដោយសាលក្រមរបស់តុលាការ។

ហេតុដូច្នេះការលែងលះ ឬការរំលាយចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ដែលប្តី ប្រពន្ធបានចុះសំបុត្រអាពាហ៍ពិពាហ៍ ត្រូវតែធ្វើឡើងតាមផ្លូវតុលាការ។ ភាគីប្តី ឬប្រពន្ធ មិនអាចបង្កើតកិច្ចព្រមព្រៀងលែងលះក្រៅប្រព័ន្ធតុលាការ ឬគ្រាន់តែដាក់លិខិតជូនដំណឹងទៅក្រុមប្រឹក្សាឃុំ-សង្កាត់បានទេ។ ប្រសិនបើមិនបានឆ្លងកាត់ការសម្រេចសេចក្តីតាមរយៈសេចក្តីសម្រេចរបស់តុលាការនោះទេ ចំណងអាពាហ៍ពិពាហ៍របស់ពួកគេត្រូវទុកជាបានការដដែល។

### ២.២.១. តុលាការមានសមត្ថកិច្ច

នៅក្នុងនីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀង ឬដោយមានបណ្តឹងភាគីនៃបណ្តឹងលែងលះត្រូវទៅដាក់ពាក្យបណ្តឹងនៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីបន្តចំណាត់ការទៅលើរឿងក្តីលែងលះ។ ការកំណត់ពីតុលាការដែលមានសមត្ថកិច្ចនៅក្នុងរឿងក្តីលែងលះត្រូវអនុលោមយកតាមក្រមនីតិវិធីរដ្ឋប្បវេណីដែលបានចែងថា៖ បណ្តឹងលែងលះគ្នា និងបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាព (ភាពមាន) ឬនត្ថិភាព (ភាពគ្មាន)នៃបុត្តភាពត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធនឹងបណ្តឹងនោះ ឬលំនៅដ្ឋាននាពេលដែលភាគីនោះទទួលមរណៈភាព។[49] បើយោងតាមមាត្រា៥ ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលក៏បានចែងដូចគ្នាទាក់ទងទៅនឹងក្រមនីតិវិធីរដ្ឋប្បវេណី២០០៦ គឺបណ្តឹងទាក់ទងនឹងឋានៈបុគ្គលត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងនឹងឋានៈបុគ្គលពាក់ព័ន្ធនឹងបណ្តឹងនោះ ឬលំនៅឋាន នៅពេលដែលភាគីនោះទទួលមរណភាព។[50] ហេតុនេះតុលាការមានសមត្ថកិច្ចក្នុងរឿងក្តីលែងលះអាចជាតុលាការខាងលំនៅឋានរបស់ដើមចោទក៏បាន ឬជាតុលាការខាងលំនៅឋានរបស់ចុងចម្លើយក៏បានដែរ ។

[48] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា៣៥។(គ) ។

[49] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១០។

[50] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា៥។

### ២.២.២. បណ្តឹងលែងលះ

ការលែងលះដោយគ្មានការព្រមព្រៀងតាមផ្លូវតុលាការ ចាប់ផ្តើមដំណើរការនីតិវិធីនៅពេលដែលសហព័ទ្ធម្ខាងបានដាក់ពាក្យបណ្តឹងទាមទារលែងលះ។ បុគ្គលដែលមិនមែនជាសហព័ទ្ធ គឺមិនអាចក្លាយទៅជាភាគីនៃបណ្តឹងបានឡើយ ទោះបីជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។ ភាគីនៃបណ្តឹង គឺជាជនដែលទាមទារឱ្យតុលាការដោះស្រាយវិវាទរបស់ខ្លួនដោយការសម្រេចចេញនូវសាលក្រម ឬសាលដីកា។ ដោយសារតែភាគី គឺជាប្រធាននៃនីតិវិធីបណ្តឹងរដ្ឋប្បវេណី ដូចនេះភាគីទាំងសងខាងតម្រូវឱ្យចូលរួមក្នុងនីតិវិធី ដើម្បីស្តាប់ធ្វើការអះអាងពិនិត្យ និងដាក់ភស្តុតាងធ្វើការតទល់រួចចេញសាលក្រម។ ពាក្យបណ្តឹងលែងលះគ្នាអាចដាក់ទៅតុលាការដែលមានសមត្ថកិច្ចដោយយោងតាមបញ្ញត្តិមាត្រា១០ (សមត្ថកិច្ចសាលាជម្រះក្តីពិសេសលើរឿងក្តីលែងលះគ្នា និងរឿងក្តីអំពីបុគ្គភាព) នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន។[51] បណ្តឹងលែងលះគ្នា និងបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃបុគ្គភាពត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធនឹងបណ្តឹងនោះបើលំនៅឋានដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះពុំស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ លំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនពិតប្រាកដទេសមត្ថកិច្ចសាលាជម្រះក្តីត្រូវកំណត់តាមទីសំណាក់បើពុំមានទីសំណាក់ ឬទីសំណាក់មិនពិតប្រាកដទេ សមត្ថកិច្ចនោះត្រូវកំណត់តាមលំនៅឋានចុងក្រោយ។[52] នៅក្នុងលិខិតនៃពាក្យបណ្តឹងត្រូវសរសេរបញ្ជាក់ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគីហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ និងខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ។[53]

ដូចនេះសហព័ទ្ធដែលជាភាគីត្រូវទទួលស្គាល់សិទ្ធិមូលដ្ឋាននៃនីតិវិធី ដែលមានសិទ្ធិទាមទារឱ្យ សាកសួរជាដើម។ ហើយភាគីនោះ គឺជាចំណុចដែលត្រូវសរសេរបញ្ជាក់នៅក្នុងពាក្យបណ្តឹងផងដែរ។ ប្រសិនបើក្នុងករណីដែលសហព័ទ្ធចង់សុំប្តឹងធ្វើការលែងលះ តែការលែងលះគ្នានោះនឹងបណ្តាលឱ្យការទ្រទ្រង់ជីវភាព របស់សហព័ទ្ធ ឬកូនក្រលំបាកយ៉ាងខ្លាំង ឬមានការឈឺចាប់ ដែលពុំអាចទ្រាំទ្របាន តុលាការអាចច្រានចោលទាមទារការលែងលះនោះ ដោយពិចារណាទៅលើស្ថានភាពទាំងឡាយដែលកើតមាន។ ដូច្នេះក្នុងស្ថានភាពបែបនេះ សហព័ទ្ធពុំមានសិទ្ធិក្នុងការសុំប្តឹងលែងលះគ្នាបានឡើយ។

---

[51] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨២។

[52] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១០។

[53] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៥។

### ២.២.៣. ការផ្សះផ្សារដោយតុលាការ

ចំពោះនីតិវិធីនៅក្នុងតុលាការមានលក្ខណៈដូចគ្នាមិនថាតុលាការទទួលពាក្យបណ្តឹងដោយផ្ទាល់ពីភាគីដើមចោទ ឬតុលាការទទួលពាក្យបណ្តឹងពីមេឃុំ ចៅសង្កាត់ក្រោយទទួលពាក្យបណ្តឹងតុលាការត្រូវចាត់តាំងចៅក្រមមួយរូបដើម្បីធ្វើការផ្សះផ្សា។ ទោះបីជាសហព័ទ្ធម្ខាងណាទាមទារលែងលះខ្លាំងយ៉ាងណាក៏តុលាការអាចធ្វើការផ្សះផ្សាដោយឆន្ទានុសិទ្ធិ។[54] ការផ្សះផ្សាគឺមិនមែនធ្វើឱ្យភាគីសះជាគ្នាដោយលះបង់ការទាមទារ ឬទទួលស្គាល់ការទាមទារនោះទេ គឺផ្សះផ្សាដើម្បីឱ្យមានការដកពាក្យបណ្តឹងលែងលះវិញហើយរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធដូចដើម។

ក្រោយពេលដែលតុលាការចេញដីកាកោះ ឲ្យចូលមកផ្សះផ្សាជាលើកទី១ ដើមចោទ ឬចុង ចម្លើយដែលបានទទួលដីកាកោះរបស់តុលាការដោយត្រឹមត្រូវ ហើយមិនមកបង្ហាញខ្លួនទេនោះ តុលាការត្រូវកោះអញ្ជើញគូភាគីមកធ្វើការផ្សះផ្សាជាលើកទី២។ មួយវិញទៀតប្រសិនបើដើមចោទ បានទទួលដីកាកោះអញ្ជើញរបស់តុលាការ ប៉ុន្តែដើមចោទមិនបានចូលមកទាំងលើកទី១ និង លើក ទី២ ដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការចាត់ទុកថាមិនព្រមសះជានឹងគ្នា។

បើសិនភាគីទាំងសងខាងស្រុះស្រួលគ្នាហើយ កំណត់ហេតុត្រូវបានចុះអំពីការសន្យារបស់ ភាគីនីមួយៗដោយគោរពតាមការស្រុះស្រួលគ្នានោះ សម្រាប់យកមកធ្វើជាមូលដ្ឋាន ឬអំណះ អំណាងការពារកុំឲ្យភាគីកែប្រែគំនិតទៅថ្ងៃក្រោយទៀត។ បន្ទាប់មក ដោយសំអាងលើកិច្ចសន្យា នេះចៅក្រមចេញសេចក្តីសម្រេចមួយដែលមានឈ្មោះថា "ដីកាសម្រេចតាមលទ្ធផលសះជា" ។

### ២.២.៤. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវរៀបចំសេចក្តីអះអាងរបស់ភាគីដើម្បីបំភ្លឺចំណុចវិវាទនៃរឿងក្តីដែលគូភាគីមិនយល់ស្របគ្នា និងរៀបចំភស្តុតាងដែលទាក់ទង នឹងចំណុចវិវាទនៃរឿងក្តីនោះដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់។[55] លើសពីនេះ ទៅទៀតចំពោះនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីមួយដែលតុលាការធ្វើឡើង ដើម្បីលើកកម្ពស់ និងសម្រួលដល់ការជម្រះក្តីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់។ តុលាការ ត្រូវដឹកនាំនីតិវិធីត្រៀមសម្រាប់ ការទាញហេតុផលនេះឡើង គឺដើម្បីជាឱកាសមួយដល់ភាគីទាំងសងខាង បានមកជួបជុំគ្នានៅតុលាការ ដើម្បីនិយាយនៅចំពោះមុខគ្នា ពីចំណុចវិវាទ ការអះអាង និងការបំភ្លឺទាំងឡាយទាក់ទងនឹងការលែងលះ។

[54] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨៤។

[55] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១០៣។

ជាគោលការណ៍គូភាគីជាអ្នកស្នើសុំឱ្យតុលាការពិនិត្យភស្តុតាង និយាយបានម៉្យាងទៀតថាគូភាគីជាអ្នកស្វះស្វែងរកភស្តុតាងផ្សេងៗមកដាក់ជូនតុលាការពិនិត្យដើម្បីជាផលប្រយោជន៍របស់ខ្លួន។ នៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយភាគីមកធ្វើជាមូលដ្ឋាននៃសាលក្រមបានក្នុងករណីនេះតុលាការត្រូវសួរមតិពីភាគីអំពីអង្គហេតុនោះ ។[56] មានន័យថាស្របគ្នានេះដែរតុលាការអាចធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិហើយជាពិសេសតុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយគូភាគីមកធ្វើជាមូលដ្ឋាននៃសាលក្រមបាន។ នៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់ហើយតុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលយ៉ាងរហ័ស និងកោះហៅគូភាគីរីឯកាលបរិច្ឆេទដែលបានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើនេះត្រូវកំណត់ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីថ្ងៃដែលពាក្យបណ្តឹងត្រូវបានដាក់ លើកលែងតែក្នុងករណីដែលមានមូលហេតុពិសេស។[57] នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចចូលរួមបានមិនតែប៉ុណ្ណោះកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមិនចាំបាច់បើកជាសាធារណៈទេប៉ុន្តែតុលាការអាចអនុញ្ញាតឱ្យអ្នកដែលតុលាការយល់ឃើញថាសមរម្យចូលស្តាប់ជាអ្នកសង្កេតការណ៍បាន។[58] តុលាការត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅគ្រប់កាលបរិច្ឆេទនីមួយៗ។[59]

### ២.២.៥. ការទាញហេតុផលដោយផ្ទាល់មាត់

ការទាញហេតុផលដោយផ្ទាល់មាត់ គឺជាទម្រង់មួយនៃការជម្រះក្តីដែលក្នុងនោះសកម្មភាពរបស់តុលាការ និងសកម្មភាពរបស់ភាគីចំពោះការជម្រះក្តីនោះត្រូវធ្វើឡើងតាមរយៈការធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ ការស្តាប់សេចក្តីថ្លែងការណ៍នោះនូវសាលសវនាការជាអសាធារណៈនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចមានវត្តមានបាន។ នៅមុនពេលដែលតុលាការសម្រេចសេចក្តី តុលាការត្រូវស្វែងរកភស្តុតាងនានាដើម្បីធ្វើជាមូលដ្ឋាន សម្រាប់ការកាត់ក្តី។ ជាទូទៅភស្តុតាងត្រូវបានពិនិត្យតាមឆន្ទានុសិទ្ធិរបស់តុលាការ ឬតាមការស្នើសុំរបស់ភាគី ដូចជា តុលាការទទួលបានការបំភ្លឺបន្ថែម ទៅលើរឿងក្តីលែងលះ តាមរយៈការសាកសួរសាក្សី។ ដើម្បីចេញសាលក្រមទៅលើបណ្តឹងតុលាការចាំបាច់ត្រូវតែឆ្លងកាត់នូវការទាញហេតុផលដោយផ្ទាល់មាត់ ប៉ុន្តែចំពោះរឿងក្តី ឬ ចំណុចណាដែលត្រូវសម្រេចដោយដីកាសម្រេចតុលាការត្រូវកំណត់ថាត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬមិនត្រូវធ្វើ ។[60] នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ហើយត្រូវកោះហៅ

---

[56] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា១៤។

[57] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៨០។

[58] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១០៥។

[59] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១០៩។

[60] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១១៤។

គូភាគីមកចូលរួម។[61] នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នេះដែរ ភាគីទាំងសងខាងត្រូវធ្វើសេចក្តីថ្លែងការណ៍អំពី លទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីចង្អុលបង្ហាញឱ្យបានច្បាស់នៅអង្គហេតុដែលត្រូវ នឹងបញ្ជាក់ដោយការពិនិត្យភស្តុតាង ដែលនឹងត្រូវធ្វើនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់។ ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចមានវត្តមានបានម៉្យាងវិញទៀតការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើឡើងនៅ សាលសវនាការជាសាធារណៈប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលភាពជាសាធារណៈនេះបណ្តាលឱ្យខូចសណ្តាប់ធ្នាប់សាធារណៈ ឬ ករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់។[62] លើសពីនេះ ក្នុងនីតិវិធីទាញហេតុផលនេះ ជាទូទៅធ្វើឡើងនៅសាលសវនាការជាសាធារណៈ ប៉ុន្តែសម្រាប់បណ្តឹងលែងលះវិញ មិនត្រូវធ្វើជាសាធារណៈឡើយ ពោលគឺតុលាការអាចរៀបចំនៅក្នុងសាលសវនាការ ក៏ប៉ុន្តែត្រូវ មានលក្ខណៈអសាធារណៈ មានតែបុគ្គលដែលពាក់ព័ន្ធនឹងរឿងក្តីលែងលះប៉ុណ្ណោះដែលអាចចូលរួមបាន។ ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលមិនត្រូវធ្វើជាសាធារណៈឡើយ។[63] មានន័យថាដើម្បីធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់សម្រាប់ បណ្តឹងលែងលះគឺមានជាប់ពាក់ព័ន្ធទៅនឹងឋានៈបុគ្គលឯកជនភាព និងសេចក្តីថ្លៃថ្នូររបស់ភាគីដូចនេះហើយច្បាប់មិនបានតម្រូវឲ្យធ្វើនីតិវិធីទាញហេតុផលផ្ទាល់មាត់នេះនៅសាលសវនាការជាសាធារណៈនោះទេពោលគឺអាចរៀបចំបាននៅក្នុងសាលសវនាការ ក៏ប៉ុន្តែត្រូវតែមានលក្ខណៈអសាធារណៈដែលមានតែបុគ្គលពាក់ព័ន្ធក្នុងរឿងក្តីលែងលះនោះប៉ុណ្ណោះដែលអាចចូលរួមបាន។

### ២.២.៦. សេចក្តីសម្រេចក្នុងរឿងលែងលះ

រឿងក្តីលែងលះដោយគ្មានការព្រមព្រៀង ឬដោយមានបណ្តឹងឈានមកដល់នីតិវិធីចុងក្រោយបង្អស់គឺការចេញនូវសាលក្រមសម្រេចលើបណ្តឹងទាមទារលែងលះ។ បន្ទាប់ពីឆ្លងកាត់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់រួចហើយ តុលាការនឹងធ្វើការសម្រេច សេចក្តីដោយការចេញសាលក្រម។ នៅក្នុងការសម្រេចសេចក្តី ទៅលើរឿងក្តីលែងលះដោយគ្មានការព្រមព្រៀង តុលាការមានឆន្ទានុសិទ្ធិសម្រេចចេញសាលក្រម ឬសម្រេចបដិសេដចោលនូវបណ្តឹងលែងលះនោះ។ អនុលោមតាមស្មារតីនៃច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណី និងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលបានបញ្ញត្តិថាការសម្រេចសេចក្តីលើបណ្តឹងលែងលះគឺត្រូវសម្រេចដោយការចេញសាលក្រមពីតុលាការ។ មួយវិញទៀតនៅក្នុងការធ្វើសេចក្តីសម្រេចទៅលើរឿងក្តីលែងលះដោយគ្មានការព្រមព្រៀង ឬដោយមានបណ្តឹងតុលាការមានឆន្ទានុសិទ្ធិសម្រេចចេញសាលក្រមលែងលះដល់ភាគី ឬតុលាការសម្រេចបដិសេធចោលនូវបណ្តឹងលែងលះ។ ក្រោយពីធ្វើការវិនិច្ឆ័យរួចហើយតុលាការនឹងធ្វើការសម្រេចសេចក្តីដោយចេញជាសាលក្រម។ លិខិតសាលក្រមត្រូវបញ្ជូនទៅឱ្យគូភាគីក្នុងអំឡុងពេល ២ (ពីរ)

[61] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១១៣។

[62] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១១៥។

[63] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា១៦។

សប្តាហ៍ដោយគិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រមនោះ។[64] បណ្តឹងឧទ្ធរណ៍ត្រូវធ្វើនៅក្នុងអំឡុងពេល ១ (មួយ)ខែដោយគិតចាប់តាំងពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម ឬថ្ងៃដែលបានជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬលើកចោលបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខប៉ុន្តែករណីនេះ មិនមែនជាការរារាំងលើអានុភាពនៃបណ្តឹងឧទ្ធរណ៍ដែលបានដាក់នៅមុនអំឡុងពេលនេះឡើយ។[65]

### ២.២.៧. ការចាត់ចែងរក្សាការពារ

ដំណើរនីតិវិធីលែងលះដោយគ្មានការព្រមព្រៀងមានលក្ខណៈស្មុគស្មាញ និងត្រូវចំណាយពេលវេលាវែងនៅក្នុងការដោះស្រាយហេតុនេះភាគីទាំងសងខាងអាចនិងមានការព្រួយបារម្ភ ឬក៏ជួបប្រទះនឹងបញ្ហាទាក់ទងនឹងស្ថានភាពរស់នៅ ឬក៏ជួបប្រទះនឹងបញ្ហាពាក់ព័ន្ធការចាត់ចែងផ្សេងៗដែលអាចកើតមាននៅអំឡុងពេលនីតិវិធីលែងលះ។ ដំណោះស្រាយនៅលើសេចក្តីព្រួយបារម្ភទាំងនោះគឺភាគីលែងលះមានសិទ្ធិក្នុងការស្នើសុំនូវដីកាសម្រេចចាត់ចែងការពារពីតុលាការបាន។ ក្នុងករណីដែលមានពាក្យបណ្តឹងទាក់ទងនឹងឋានៈបុគ្គល តុលាការអាចបង្គាប់ឱ្យធ្វើការរឹបអូសជាបណ្តោះអាសន្នការចាត់ចែងជាបណ្តោះអាសន្ន ឬការរក្សាការពារផ្សេងទៀតដែលចាំបាច់ដែលកំណត់ ក្នុងគន្ថីទី ៧ (ការចាត់ចែងរក្សាការពារ) នៃក្រមនីតិវិធីរដ្ឋប្បវេណីដោយឆន្ទានុសិទ្ធិបានទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា៥៣២ (ស្ថាប័នចាត់ចែងរក្សាការពារជាបណ្តោះអាសន្ន) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ។[66] ចំពោះការចាត់ចែងរក្សាការពារនេះផងដែរ មានលក្ខណៈជាបណ្តោះអាសន្ន ព្រោះវាមានប្រសិទ្ធិភាព តែអំឡុងពេលដែលដំណើរការនៃរឿងក្តីប៉ុណ្ណោះ ពោលគឺនៅពេលដែលតុលាការចេញសាលក្រមស្ថាពររួច សាលក្រមនោះនឹងមកជំនួសឱ្យវិធានការបណ្តោះអាសន្នហើយ រាល់វិធានការទាំងអស់នោះនឹងត្រូវអស់សុពលភាព។ តុលាការដែលបានទទួលពាក្យបណ្តឹងលែងលះគ្នាក្នុងករណីចាំបាច់អាចចេញដីកាសម្រេចបង្គាប់ឱ្យធ្វើការចាត់ចែងរក្សាការពារចំពោះការបំបែកលំនៅឋានការគ្រប់គ្រងថែរក្សាកូនការគ្រប់គ្រងទ្រព្យសម្បត្តិអាហារកាតព្វកិច្ចរបស់សហព័ទ្ធបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ និងសោហ៊ុយចិញ្ចឹមបីបាច់កូនជាអាទិ៍តាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិបាន។[67] ក្នុងករណីដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារអ្នកដែលដាក់ពាក្យសុំត្រូវបង់ពន្ធចំនួន ៥០០០ (ប្រាំពាន់) រៀលទៅតុលាការ។[68]

ផ្អែកតាមអត្ថន័យខាងលើនេះឃើញថាការចាត់ចែងរក្សាការពារគឺជាវិធានការដើម្បីធានាឱ្យជីវភាពរស់នៅក្នុងគ្រួសារអាចបន្តទៅទៀតបានដោយសមរម្យបើទោះបីជាសហព័ទ្ធទាំងសងខាងកំពុងតែប្តឹងទាមទារលែង

[64] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៩០។
[65] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៦៥។
[66] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា២១។
[67] ក្រមរដ្ឋប្បវេណី,លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨៣។
[68] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣៧។

លះគ្នាក់ដោយ។ ជាបន្តបន្ទាប់ពីបានយល់ដឹងពីនីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀងតាមផ្លូវតុលាការ រួចមក យើងនឹងបន្តបកស្រាយពីអានុភាពនៃការលែងលះជាបន្តទៀត។

# ជំពូកទី៣
# អនុភាពនៃការលែងលះ

# ជំពូកទី៣

# អានុភាពនៃការលែងលះ

អានុភាពនៃការលែងលះគឺជាការផ្តាច់ទំនាក់ទំនងនៃចំណងអាពាហ៍ពិពាហ៍រវាងសហព័ទ្ធនៅពេលដែលតុលាការចេញសេចក្តីសម្រេចអំពីការលែងលះចូលជាស្ថាពររួច។ ហើយសេចក្តីសម្រេចអំពីការលែងលះនិងចូលជាស្ថាពរនៅអំឡុងពេលនៃបណ្តឹងឧបាស្រ័យបានកន្លងផុត។ ក្នុងនោះផងដែរអានុភាពនៃការលែងលះគឺមានចំពោះសាលក្រមនិងសេចក្តីសម្រេច។ ករណីសេចក្តីសម្រេចនេះជាសាលក្រម អំឡុងពេលប្តឹងឧទ្ធរណ៍ ១(មួយ)ខែ ដោយគិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិត សាលក្រម។[69] ប៉ុន្តែនៅពេលដែលសេចក្តីសម្រេចនោះជាដីការសម្រេចរយះពេលប្តឹងជំទាស់មាន ២(ពីរ)សប្តាហ៍គិតចាប់ពីថ្ងៃដែលទទួលដំណឹងពីដីការសម្រេចមក។ [70] ដូច្នេះនៅពេលដែលផុតអំឡុងពេលខាងលើនេះសេចក្តីសម្រេចអំពីការលែងនឹងចូលជាស្ថាពរ។

ហើយអានុភាពនៃការលែងលះត្រូវបានកាត់ផ្តាច់សិទ្ធិ និងករណីយកិច្ចរវាងសហព័ទ្ធទាំងសងខាងព្រមទាំងមានអានុភាពចំពោះទំនាក់ទំនងផ្ទាល់ខ្លួនរបស់សហព័ទ្ធចំពោះទ្រព្យសម្បត្តិ និងអានុភាពចំពោះកូន។

## ៣.១. អានុភាពចំពោះទំនាក់ទំនងផ្ទាល់ខ្លួនរបស់សហព័ទ្ធ

នៅពេលដែលពួកគេលែងលះគ្នានោះអានុភាពនៃការលែងលះបានកាត់ផ្តាច់ទំនាក់ទំនងគតិយុត្តរវាងសហព័ទ្ធចាប់ពីសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរ។ ការលែងលះនាំឲ្យសហព័ទ្ធរួចផុតពីកាតព្វកិច្ចទាំងឡាយដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍។ មួយវិញទៀតសហព័ទ្ធដែលត្រូវផ្តល់អាហារកាតព្វកិច្ចនោះត្រូវមានលទ្ធភាពក្នុងការចំណាយនូវអាហារកិច្ចទៅអតីតសហព័ទ្ធម្ខាងទៀតបាន។ ចៅក្រមនិងត្រូវត្រួតពិនិត្យទៅលើប្រាក់បៀវត្សលទ្ធភាពក្នុងការស្វែងរកប្រាក់ចំណូល សុខភាព អាយុរបស់បុគ្គលនោះដើម្បីកំណត់អំពីអាហារកាតព្វកិច្ចដែលត្រូវបង់ក្នុងករណីដែលអតីតសហព័ទ្ធម្ខាងនោះមិនទាន់រៀបអាពាហ៍ពិពាហ៍ថ្មី។ ប៉ុន្តែបើអតីតសហព័ទ្ធម្ខាងទៀតនោះបានរៀបអាពាហ៍ពីពាហ៍ថ្មីនោះលែងមានសិទ្ធិទទួលអាហារកាតព្វកិច្ចទៀតឡើយ។

### ៣.១.១. ចំពោះភាគីទាំងសងខាង

នៅពេលដែលសាលក្រមរបស់តុលាការចូលជាស្ថាពររួចគូភាគីនៃបណ្តឹងលែងលះប្តីប្រពន្ធដែលធ្លាប់រស់ជាមួយដែលស្របច្បាប់ក៏ប្រែក្លាយទៅជាភាពនៅលីវរៀងៗខ្លួនសារជាថ្មីម្តងទៀត។ នៅពេលដែលសាលក្រមបានចូលជាស្ថាពរនោះគូភាគីទាំងសងខាងមានសេរីភាពឡើងវិញក្នុងការរៀបអាពាហ៍ពិពាហ៍ថ្មីបានទៀតដោយស្របទៅតាមច្បាប់កំណត់។ ចំពោះបុរសនៅពេលដែលបានបញ្ចប់នូវចំណងអាពាហ៍ពិពាហ៍រួចហើយគឺអាច

[69] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៦៤។

[70] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា៤០ (១)។

រៀបអាពាហ៍ពិពាហ៍ថ្មីម្តងទៀតបានដោយមិនត្រូវចាំនោះទេបន្ទាប់ពីសាលក្រមចូលជាស្ថាពរ។ ចំណែកឯចំពោះភាគីខាងស្ត្រីវិញគឺផ្ទុយនិងភាគីខាងបុរសដោយសារស្ត្រីត្រូវបានច្បាប់កំណត់រយៈពេលនៃការរៀបអាពាហ៍ពិពាហ៍ថ្មី គឺពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានទៀតទេប្រសិនបើអំឡុងពេល ១២០ថ្ងៃពុំទាន់បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល។ ទោះបីជាយ៉ាងណាក៏ដោយក៏ស្ត្រីអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានក្នុងករណីដែលស្ត្រីមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោលហើយបានសម្រាលកូន ឬចំពោះករណីមានលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះ។[71]ដូច្នេះស្ត្រីត្រូវប្រាកដឲ្យបានច្បាស់ថាខ្លួនមានផ្ទៃពោះ ឬមិនមានផ្ទៃពោះអោយបានច្បាស់ដើម្បីនៅពេលដែលបញ្ជាក់អំពីបញ្ហាខាងលើនេះនោះស្ត្រីអាចរៀបអាពាហ៍ពិពាហ៍បាន។

### ៣.១.២. ចំពោះឈ្មោះរបស់សហព័ទ្ធ និង ញាតិ

#### ក . ចំពោះឈ្មោះរបស់សហព័ទ្ធ

នៅពេលរៀបអាពាហ៍ពិពាហ៍ប្តីប្រពន្ធអាចប្រើនាមត្រកូលរបស់ប្តី ឬប្រពន្ធអាចបប្រើនាមត្រកូលដើមរៀងៗខ្លួន ដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍។[72] ដោយសហព័ទ្ធមួយចំនួនជាពិសេសចំពោះស្ត្រីភាគច្រើននៅពេលដែលបានរៀបអាពាហ៍ពិពាហ៍រួចហើយគឺត្រូវប្រើនាមត្រកូលខាងប្តី។ ក្នុងករណីបើប្តី ឬប្រពន្ធដែលបានប្តូរនាមត្រកូលថ្មីដោយចំណងអាពាហ៍ពិពាហ៍អាចប្រើនាមត្រកូលដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍វិញបាន ឬអាចប្រើនាមត្រកូលដែលបានប្រើនៅពេលលែងលះគ្នាក៏បាន។[73] ដូច្នេះនៅពេលមានការលែងលះមិនថាសហព័ទ្ធភាគីប្តីក្តី ឬ ភាគីខាងប្រពន្ធក្តីមានសិទ្ធិក្នុងការប្រើប្រាស់នាមត្រកូលតាមឆន្ទៈរបស់ខ្លួនដោយគ្មានការបង្ខិតបង្ខំពីនរណាម្នាក់ឡើយ។

**ឧទាហរណ៍៖** លោក សុខ សួនពិសិដ្ឋិ បានរៀបអាពាហ៍ពិពាហ៍ជាមួយនារីម្នាក់ឈ្មោះ គន្ធី ចិន្តា។ ក្នុងករណីនេះលោកស្រី គន្ធី ចិន្តា អាចប្រើនាមត្រកូលរបស់ប្តីលោកស្រីបាន ដោយប្តូរទៅជា លោកស្រី សុខ ចិន្តាវិញ។ប៉ុន្តែប្រសិនបើអ្នកទាំងពីរបានលែងលះគ្នាវិញ លោកស្រី គន្ធី ចិន្តា អាចនៅប្រើប្រាស់ឈ្មោះ សុខ ចិន្តាដដែលក៏បាន ឬក៏ប្តូរទៅប្រើប្រាស់ឈ្មោះដើម គន្ធី ចិន្តា វិញក៏បាន។

#### ខ. ចំពោះញាតិ

ការលែងលះមិនត្រឹមតែមានអានុភាពកាត់ផ្តាច់ទំនាក់ទំនងរវាងសហព័ទ្ធនោះទេថែមទាំងនាំឲមានការកាត់ផ្តាច់នូវទំនាក់ទំនងរវាងញាតិពន្ធផងដែរ។ ដោយយោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានកំណត់ទំហំ

[71] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥០ (១)។

[72] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៥។

[73] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨១។

របស់ញាតិដែលមានញាតិលោហិតក្នុង ៦ (ប្រាំមួយ) ថ្នាក់សហព័ទ្ធ និងញាតិពន្ធក្នុង៣ (បី)ថ្នាក់។[74] នៅពេលដែលភាគីទាំងសងខាងបានលែងលះគ្នារួចហើយនោះទំនាក់ទំនងញាតិទាំងសងខាងនឹងត្រូវបានបញ្ចប់នោះទំនាក់ទំនងញាតិពន្ធត្រូវបានបញ្ចប់ដោយការលែងលះគ្នា។[75] ញាតិពន្ធកើតឡើងនៅពេលដែលមានចំណងអាពាហ៍ពិពាហ៍ជាមួយគ្នាដូចជាឪពុកម្តាយក្មេក និងកូនប្រសា បងថ្លៃ ប្អូនថ្លៃខាងប្តី ឬខាងប្រពន្ធដែលនាំអោយមានការភ្ជាប់ជាសាច់ញាតិទាំងសងខាង។ចំណែកឯញាតិលោហិត គឺសំដៅដល់ញាតិដែលមានឈាមជ័រជាមួយគ្នា ដូចជា ឪពុក និងកូន ឬម្តាយ និងកូនជាដើម។[76]ដូច្នេះនៅពេលដែលចំណងអាពាហ៍ពិពាហ៍នោះត្រូវបានបញ្ចប់ដោយសហព័ទ្ធទាំងសងខាងមានការលែងលះដោយមិនទុកនូវញាតិពន្ធបន្តទៀតនោះទេ នោះទំនាក់ទំនងញាតិពន្ធត្រូវបញ្ចប់ចាប់ពីសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរ។[77] ប្រសិនបើក្នុងករណីស្ត្រីដែលមានកូនវិញទំនាក់ទំនងរវាងញាតិនិងកូននៅតែមានដដែល ទោះបីសហព័ទ្ធទាំងសងខាងមានការលែងលះគ្នាក៏ដោយ។

### ៣.១.៣. ចំពោះអត្តាធិនភាព

អត្តាធិភាពជាស្ថានភាពមួយដែលផ្តល់ឲ្យអនីតិជនបានរួចផុតពីរបបអាណាព្យាបាលសម្រាប់អនីតិជន ឬរួចផុតពីអំណាចមេបាហើយមានសមត្ថភាពដូចនីតិជនដែរ។[78] ថ្វីត្បិតតែនីតិភាពគឺត្រូវបានកំណត់ចាប់ពីអាយុ ១៨ ឆ្នាំឡើងទៅក៏ដោយក៏ប៉ុន្តែមានករណីមួយដែលអាចទទួលស្គាល់អំពីការដល់នីតិភាពមុនអាយុកំណត់បានដោយនៅក្នុងករណីដែលអនីតិជនមានលក្ខណសម្បត្តិគ្រប់គ្រាន់ហើយត្រូវបានតុលាការប្រកាសផ្តល់ឲ្យរួចផុតពីឋានៈជាអនីតិជន។ លក្ខខណ្ឌនៃការទទួលបាននូវអត្តាធិនភាពក្នុងករណីដែលអនីតិជនដែលបានដល់អាយុចាប់ពី ១៦(ដប់ប្រាំមួយ)ឆ្នាំឡើងទៅហើយអាចទ្រទ្រង់ជីវភាពខ្លួនឯងបានដោយឯករាជ្យមិនចាំបាច់ពឹងពាក់នរណា តុលាការអាចប្រកាសយល់ឃើញថាអត្តាធិនភាពស្របនឹងផលប្រយោជន៍របស់អនីតិជន។[79] ក្នុងករណីនេះតុលាការក៏ត្រូវសួរយោបល់ពីអ្នកមានអំណាចមេបាផងដែរ។ ផ្សេងពីលក្ខខណ្ឌខាងលើប្រសិនបើអនីតិជននោះបានរៀបអាពាហ៍ពិពាហ៍ហើយអនីតិជនក៏អាចទទួលបាននូវអត្តាធិនភាពដោយមិនចាំបាច់មានការប្រកាសពីតុលាការឡើយ (ក្នុងករណីនេះទោះបីភាគីនៃចំណងអាពាហ៍ពិពាហ៍បានលែងលះគ្នាក៏ដោយក៏អានុភាពនៃអត្តាធិនភាពមិនត្រូវបានរលត់ឡើយ)។ ចំណែកឯលក្ខខណ្ឌនៃការរួចផុតពីអាណាព្យាបាលអនីតិជននៅក្រោមអាណាព្យាបាលដែលបានរៀបអាពាហ៍ពិពាហ៍ត្រូវរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជនដោយគ្មានការប្រកាសពីតុលាការ។ ក្នុងករណីនេះដែរទោះបីភាគីបានលែងលះនៅពេលក្រោយក៏ដោយក៏

[74] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៣៨។

[75] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៤១ (១)។

[76] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សទ្ទានុក្រមលេខ៤៣។

[77] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៤១។

[78] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សទ្ទានុក្រមលេខ១៨៣។

[79] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា២១។

អានុភាពនៃការរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជនមិនត្រូវរលត់ឡើយ។[80] ក្នុងករណីដែលភាគីម្ខាងក្នុងចំណោមភាគីដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាមួយអនីតិជននោះត្រូវមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបាឬអាណាព្យាបាលសម្រាប់អនីតិជននោះ។ បើអ្នកដែលមានអំណាចមេបាណាម្ខាងមិនយល់ព្រមទេគ្រាន់តែមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបាម្ខាងជាការគ្រប់គ្រាន់ហើយ ប៉ុន្តែប្រសិនបើអ្នកមានអំណាចមេបាបដិសេធ ការយល់ព្រមដោយគ្មានមូលហេតុសមរម្យអនីតិជនដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍អាចទាមទារទៅតុលាការឲ្យសម្រេចសេចក្តីជំនួសការយល់ព្រមនោះបាន។[81]

**ឧទាហរណ៍៖** លោក វិសាល មាន អាយុ ២០ឆ្នាំ បានរៀបអាពាហ៍ពិពាហ៍ ជាមួយ នារីម្នាក់ឈ្មោះ កញ្ញា អាយុ ទើបតែ ១៥ឆ្នាំប៉ុណ្ណោះ។ អាណាព្យាបាលខាងស្រីបានអនុញ្ញាត និងយល់ព្រមអោយ កញ្ញា បានរៀបអាពាហ៍ពិពាហ៍ជាមួយលោក វិសាល ដូចដែលពួកគេចង់បាន។ នៅពេលដែររៀបអាពាហ៍ពិពាហ៍ហើយ កញ្ញាក៏មាននូវអត្តាធីនភាព ពោលគឺ លោកស្រី កញ្ញា បានក្លាយជានីតិជនបន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍រួច។ ផ្ទុយទៅវិញ ប្រសិនបើអ្នកទាំងពីលែងលះគ្នាវិញនៅកំឡុងពេលដែលកញ្ញាមានអាយុត្រឹម១៦ឆ្នាំ ក៏អត្តាធីនភាពរបស់កញ្ញានៅតែមានដដែល។

សរុបមកអត្តាធីនភាព គឺពិតជាមានសារសំខាន់ខ្លាំងណាស់ចំពោះអនីតិជនដែលមានបំណងចង់មានសមត្ថភាពតាមផ្លូវច្បាប់ក្នុងការធ្វើសកម្មភាពបានដូចនីតិជនដោយអត្តាធិនភាពនោះមានអានុភាពអាចធ្វើឱ្យអនីតិជនបានដល់នីតិភាពដែលអាចធ្វើសកម្មភាពពាណិជ្ជកម្ម ធ្វើសកម្មភាពដែលទាក់ទងទៅនឹងការទទួលយកនូវសិទ្ធិ និងកាតព្វកិច្ចអាចមានជីវិតដែលឯករាជ្យហើយអាចរស់នៅដោយពឹងពាក់លើខ្លួនឯងទាំងស្រុង និងអាចរួចផុតពីអំណាចមេបា ឬអ្នកអាណាព្យាបាលទៀតផង។ ប៉ុន្តែមុននឹងតុលាការសម្រេចប្រកាសនូវអត្តាធិនភាពដល់អនីតិជនណាម្នាក់នោះតុលាការគប្បីធ្វើការវិនិច្ឆ័យ និងពិចារណាយ៉ាងលម្អិតហើយត្រូវឆ្លងកាត់ការសួរយោបល់អ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលជាមុនសិនដើម្បីចៀសវាងការខូចខាតប្រយោជន៍របស់អនីតិជននោះ ឬប្រយោជន៍របស់ភាគីនៃចំណងគតិយុត្តម្ខាងទៀតនៃទំនាក់ទំនងសកម្មភាពរបស់អនីតិជននោះ។

### ៣.១.៤. ភាតព្វកិច្ចសងសំណងជម្ងឺចិត្តអាចកើតមាន

បន្ទាប់ពី សាលក្រមចូលជាស្ថាពរនៅក្នុងករណីដែលភាគីដែលគ្មានកំហុស ហើយត្រូវបានភាគីម្ខាងទៀតបំពាន ភាគីដែលទទួលរងនូវការបំពាន អាចទាមទារសំណងជម្ងឺចិត្ត ឬសំណងនៃការខូចខាតបានតាមអំពើអនីត្យានុកូល ដោយផ្អែកតាមមាត្រា ៧៤៣ និង ៧៤៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បាន។

---

[80] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៩៥ (២) (៣)។

[81] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៣។

**ឧទាហរណ៍៖** លោក ឌី (ប្តី) បានប្រព្រឹត្តិអំពើជិតក្បត់ ដេរប្រមាថ និងប្រើអំពើហិង្សាមកលើលោកស្រី បុប្ផា (ប្រពន្ធ) បណ្តាលឱ្យលោកស្រី បុប្ផា រងរបួសធ្ងន់ ដោយត្រូវចំណាយថ្លៃព្យាបាលជម្ងឺអស់ចំនួន USD ២០០០(ពីរពាន់) ដុល្លារអាមេរិក ហើយលោកស្រី បុប្ផា ទទួលរងសម្ពាធផ្លូវចិត្តយ៉ាងខ្លាំង។ ក្នុងករណីនេះ លោកស្រី បុប្ផា អាចទាមទារសំណងនៃការខូចខាតពីលោក ឌី ដែលជាប្តីបានទាំងសំណងខូចខាតផ្នែកសម្ភារៈ និងផ្លូវចិត្ត។

## ៣.២. អានុភាពលែងលះចំពោះទ្រព្យសម្បត្តិ

ការលែងលះនឹងកើតឡើងដែលធ្វើឲ្យមានការបែងចែកទ្រព្យសម្បត្តិរបស់សហព័ទ្ធ។ ចំពោះការបែងចែកទ្រព្យសម្បត្តិក្រោយពេលលែងលះត្រូវមានការព្រមព្រៀងពីភាគីទាំងសងខាងផងដែរ។ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវបែងចែកដោយយុត្តិធម៌ផ្អែកតាមការពិភាក្សារបស់ភាគី។[82] ក្នុងករណីដែលគូភាគីទាំងសងខាងមានការព្រមព្រៀងគ្នាដោយមិនគិតទៅលើថាភាគីណាមួយមានតិចនោះទេ និងមានការព្រមព្រៀងគ្នាដោយគ្មានការបង្ខិតបង្ខំឲ្យនោះទេ តុលាការនិងកាត់សេចក្តីទៅតាមការព្រមព្រៀងនោះជានិច្ច។

ប៉ុន្តែចំពោះការគ្មានការព្រមព្រៀងវិញសហព័ទ្ធនីមួយៗត្រូវទទួលបានទ្រព្យសម្បត្តិដែលសាមីខ្លួនមាននៅពេលមុនរៀបអាពាហ៍ពិពាហ៍ ដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម ឬ អច្ច័យទាននៅក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍តែប៉ុណ្ណោះ។ មួយទៀតសហព័ទ្ធទាំងសងខាងមានសិទ្ធិទទួលយកនូវទ្រព្យសម្បត្តិរួមពាក់កណ្តាលម្នាក់ប៉ុន្តែក្នុងករណីពិសេស និងមានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួមដោយពិចារណាទៅលើស្ថានភាពផ្សេងៗនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិការថែរក្សាការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍និងគិតទៅដល់ផលប្រយោជន៍របស់កូនជាអាទិ៍។[83]

### ៣.២.១. ទ្រព្យសម្បត្តិអកម្ម

ការលែងលះនឹងកើតមានឡើងដែលធ្វើឲ្យមានការបែងចែកទ្រព្យសម្បត្តិរបស់សហព័ទ្ធ។

ទ្រព្យសម្បត្តិអកម្ម សំដៅទៅលើបំណុលគ្រួសារទាំងឡាយណាដែលសហព័ទ្ធទាំងពីរបានបង្កើតឡើងក្នុងគោលបំណងដើម្បីជីវភាពក្នុងគ្រួសារ និងការសិក្សាអប់រំកូនចៅរបស់ពួកគេ។ មួយវិញទៀតប្រសិនបើបំណុលនោះបង្កើតឡើងដោយសហព័ទ្ធតែម្ខាងក្នុងគោលបំណងនៃផលប្រយោជន៍គ្រួសារក៏នឹងបង្កើតជាបំណុលគ្រួសារផងដែរ។ ដូចនេះនៅពេលលែងលះសហព័ទ្ធត្រូវធ្វើការសងបំណុលរួមគ្នាដោយវាជាការទទួលខុសត្រូវដោយសាមគ្គីភាពរវាងប្តីប្រពន្ធចំពោះម្ចាស់បំណុល។

[82] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨០ (២)។

[83] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨០(១) (២)។

មួយវិញទៀតចំពោះបំណុលដែលកើតឡើងដោយសហព័ទ្ធតែម្ខាងក្នុងគោលបំណងដើម្បីបម្រើផលប្រយោជន៍ដោយខ្លួនឯងដូចជា ការផឹកស្រា ការលេងល្បែងស៊ីសងជាអាទិ៍ទោះបីបំណុលនោះមុន ឬក្រោយអាពាហ៍ពិពាហ៍ក៏ដោយ បំណុលនោះមិនចាត់ចូលជាបំណុលគ្រួសារឡើយ វាជាបំណុលដោយឡែកនោះភាគីម្ខាងៗត្រូវទទួលខុសត្រូវលើបំណុលនោះរៀងៗខ្លួន។

### ៣.២.២. ទ្រព្យសម្បត្តិសកម្ម

យោងតាមក្រមរដ្ឋប្បវេណី,លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧ តុលាការត្រូវធ្វើការបែងចែកទ្រព្យសម្បត្តិសកម្មជាពីរ មានដូចជា៖ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា និង ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់។

### ៣.២.៣. ទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមកិច្ចសន្យា

កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវធ្វើឡើងដើម្បីទប់ស្កាត់វិវាទលើទំនាក់ទំនងទ្រព្យសម្បត្តិ និងដើម្បីបញ្ជាក់ឲ្យបានច្បាស់អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្តីឬប្រពន្ធ។ មួយវិញទៀតទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមកិច្ចសន្យាគឺជាកិច្ចសន្យាមួយដែលជួយសម្រួល និងបង្កើតនូវអានុភាពជាក់លាក់របស់ប្តីប្រពន្ធដែលចុះកិច្ចសន្យានោះដូចជាការចាត់ចែងនូវទ្រព្យសម្បត្តិ កាតព្វកិច្ច និងករណីយកិច្ចដែលតម្រូវអោយសហព័ទ្ធគោរពតាម និងអនុវត្តតាមច្បាប់បានកំណត់។ ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាទ្រព្យសម្បត្តិនៅមុន ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍បាន។[84] ហើយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរព្រមទាំងមានការចុះបញ្ជីនៅក្រសួងយុត្តិធម៌ផងដែរ។ ក្នុងករណីដែលប្តីប្រពន្ធបានធ្វើកិច្ចសន្យាផ្សេងពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បើមិនមានការចុះបញ្ជីទេកិច្ចសន្យានោះមិនអាចយកមកតតាំងជាមួយតតិយជនបានឡើយ។[85] ដូច្នេះនៅពេលដែលភាគីទាំងសងខាងសម្រេចចិត្តលែងលះនោះហើយប្រសិនបើប្តីប្រពន្ធបានធ្វើកិច្ចសន្យាស្តីអំពីទំនាក់ទំនងទ្រព្យសម្បត្តិនេះតុលាការនិងធ្វើការបែងចែកទ្រព្យសម្បត្តិដោយយោងទៅតាមកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនោះ។ មួយវិញទៀតប្រសិនបើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និងប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បើប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេទំនាក់ទំនងទ្រព្យសម្បត្តិនោះត្រូវអនុលោមតាមបញ្ញត្តិនៃកថាខណ្ឌភាគទី២ (ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់)។[86]

---

[84] ក្រមរដ្ឋប្បវេណីលេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៩ (១)។

[85] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧០។

[86] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៩ (២) ។

### ៣.២.៤. ទ្រព្យសម្បត្តិរបស់សហព័ទ្ធដែលកំណត់ដោយច្បាប់

នៅក្នុងប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធដែលកំណត់ដោយច្បាប់នេះក្នុងករណីដែលសហព័ទ្ធទាំងសងខាងមានការលែងលះគ្នាដោយមានការពិភាក្សាមិនអាចចុះសម្រុងលើការព្រមព្រៀងនៃការបែងចែកទ្រព្យសម្បត្តិ និងមិនបានបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិជាមួយគ្នានោះទេនោះតុលាការការមានសិទ្ធិបែងចែកទ្រព្យសម្បត្តិទាំងនោះទៅតាមបណ្ដឹងនៃការទាមទារដោយអនុលោមតាមការកំណត់នៅក្នុងច្បាប់។

ដូចនេះដោយផ្អែកទៅតាមច្បាប់ត្រូវបែងចែកទ្រព្យសម្បត្តិដែលបានចែងអំពីទ្រព្យសម្បត្តិប្ដីប្រពន្ធ ជាពីរប្រភេទគឺ ទ្រព្យសម្បត្តិដោយឡែក និង ទ្រព្យសម្បត្តិរួម។ ហើយតុលាការអាចសម្រេចចែកទ្រព្យសម្បត្តិដោយសហព័ទ្ធនីមួយៗត្រូវទទួលបានទ្រព្យសម្បត្តិដោយឡែក និងមានសិទ្ធិទទួលយក១ ភាគ២ នៃទ្រព្យសម្បត្តិរួមព្រមទាំងការបែងចែកទ្រព្យសម្បត្តិរួម ប៉ុន្តែបើមានករណីពិសេស និងមានការទាមទាររបស់ប្ដីប្រពន្ធណាម្ខាងតុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណា ទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគ របស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ អំឡុង ពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគី នីមួយៗ និង ផលប្រយោជន៍របស់កូនជាអាទិ៍។[87]

### ៣.២.៥. ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដោយឡែក គឺជាទ្រព្យសម្បត្តិដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្ខាងណាមួយ ដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍។ ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយប្រទានកម្មសន្តតិកម្ម អច្ច័យទាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍។[88] នៅពេលលែងលះគ្នាសហព័ទ្ធនីមួយៗត្រូវទទួលបានទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនវិញ។[89]

**ឧទាហរណ៍៖** សហព័ទ្ធមួយគូរបានស្រឡាញ់គ្នាជាច្រើនឆ្នាំ និងរហូតឈានទៅដល់ការបង្កើតចំណងអាពាហ៍ពិពាហ៍។ ដោយមុនពេលរៀបអាពាហ៍ពិពាហ៍ភាគីខាងប្ដីមានផ្ទះ ២ល្វែង និងរថយន្ត ១គ្រឿង ដែលជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងភាគីខាងប្រពន្ធមាន រថយន្ត ១គ្រឿង និង ដីចំនួន ២កន្លែង។ នេះជាទ្រព្យសម្បត្តិដែលអ្នកទាំងពីរមានមុននៅពេលរៀបអាពាហ៍ពិពាហ៍ ពោលគឺទ្រព្យសម្បត្តិរៀងខ្លួន។ ប៉ុន្តែនៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ភាគីខាងប្រពន្ធត្រូវបានឪពុកម្ដាយបានផ្ដល់ផ្ទះ ១កន្លែង និង ដីចម្ការ ៥ហិចតា ទៅភាគីខាងប្រពន្ធដែលភាគីខាងប្រពន្ធទទួលបានតាមរយៈការប្រទានកម្មពោលគឺជាទ្រព្យសម្បត្តិដោយឡែករបស់ប្រពន្ធ។

---

[87] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨០ (២)។

[88] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧២។

[89] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨០ (២)។

ដូច្នេះស្របតាមមាត្រា៩៧២ នៃក្រមរដ្ឋប្បវេណី ទ្រព្យដែលបានរៀបរាប់ខាងលើនេះត្រូវបានសន្មត់ថាជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

### ៣.២.៦. ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍លើកលែងតែទ្រព្យសម្បត្តិដែលច្បាប់បានកំណត់ថាជាទ្រព្យសម្បត្តិដោយឡែក។[90] ក្នុងករណីដែលគ្មានការព្រមព្រៀងរវាងភាគីលែងលះទេនោះ តុលាការនិងធ្វើការចែកទ្រព្យសម្បត្តិរួមជា ២ ទៅកាន់ប្តី និងប្រពន្ធដែលបានលែងលះ។[91] ជាក់ស្តែងនៅក្នុងសង្គមយើងបច្ចុប្បន្ន ប្តីតែងតែជាអ្នកប្រកបការងារនៅខាងក្រៅ ចំណែកឯប្រពន្ធគឺជាអ្នករ៉ាប់រងការងារផ្ទះ។ ដែលការងារនៅក្នុងផ្ទះនេះ ក៏មានតម្លៃស្មើគ្នា នឹងកម្រៃដែលបានមកពីការងារធ្វើនៅខាងក្រៅដែរ។[92] ប៉ុន្តែបើមានករណីពិសេស និងមានការទាមទាររបស់ប្តីប្រពន្ធណាម្ខាងតុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួមដោយពិចារណាទៅលើស្ថានភាពផ្សេងៗ ដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សាការបង្កើនទ្រព្យក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍អាយុស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗនិងផលប្រយោជន៍របស់កូនជាអាទិ៍។[93]

**ឧទាហរណ៍៖** នៅក្រោយពេលដែលសហព័ទ្ធទាំងពីរបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាហើយនោះហើយភាគីខាងប្តីបានយកលុយដែលខ្លួនរកបានទៅទិញផ្ទះមួយកន្លែងក្នុងតម្លៃ ៨០០០០ ដុល្លារ។ ដូចនេះផ្ទះមួយកន្លែងដែលភាគីខាងប្តីបានទិញនោះក៏ត្រូវក្លាយជាទ្រព្យរួមរបស់ប្តីប្រពន្ធផងដែរ។

## ៣.៣. អានុភាពនៃការផ្តល់អាហារកោតព្វកិច្ច

នៅពេលដែលមានករណីលែងលះ តុលាការត្រូវកំណត់អ្នកមានអំណាចមេបាដោយឆន្ទានុសិទ្ធិ ទោះបីមិនមានពាក្យសុំពីភាគីក៏ដោយ។[94] ការប្រគល់អំណាចមេបាជាការប្រគល់សិទ្ធិគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សាអប់រំកូនទៅភាគីណាមួយក្រោយពីគូរភាគីបានលែងលះគ្នា។ ជាទូទៅនៅពេលលែងលះ គូភាគីអាចធ្វើការពិភាក្សាអំពីការផ្តល់អាហារកិច្ចបាន ប៉ុន្តែក្នុងករណីដែលពិភាក្សាគ្នាមិនត្រូវទេ ភាគីអាចដាក់ពាក្យសុំទាមទារហើយតុលាការអាចសម្រេចឲ្យបានផងដែរ។

[90] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៣។

[91] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨០ (២)។

[92] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣, មាត្រា៣៦។

[93] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨០។

[94] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា២២ (១)។

### ៣.៣.១. ការកំណត់អំណាចមេបា

អំណាចមេបាជាសិទ្ធិ និងករណីយកិច្ចបីបាច់រក្សារូបកាយកូនដែលជាអនីតិជន និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ។[95] ការបីបាច់រក្សារូបកាយរបស់កូន គឺជាសកម្មភាព ទាំងឡាយណាដែលចាំបាច់សម្រាប់ការលូតលាស់ដូចជា ការផ្តល់ចំណីអាហារ សម្លៀកបំពាក់ កន្លែងស្នាក់នៅ ការថែទាំវេជ្ជសាស្ត្រ ការព្យាបាល ការសិក្សា ជាអាទិ៍ និងការការពារកូន (ការទទួលខុសត្រូវក្នុងការគ្រប់គ្រង ដើម្បីការពារកូនមិនឱ្យប្រព្រឹត្តបទល្មើស និងអំពើមិន ត្រឹមត្រូវ) រួមទាំងទទួលខុសត្រូវចំពោះទង្វើរបស់កូនដែលនាំឱ្យមានការខូចខាតដល់អ្នកដទៃ។

នៅពេលដែលឪពុកម្តាយបានលែងលះគ្នាត្រូវកំណត់យកឪពុក ឬម្តាយណាម្ខាងជាអ្នកមានអំណាចមេបាតាមកាពិភាក្សារបស់ឪពុកម្តាយ។[96] មួយវិញទៀតឪពុកម្តាយដែលបានលែងលះគ្នានៅមុនកំណើតរបស់កូន ម្តាយគឺជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតមកនោះ។[97] ប៉ុន្តែនៅក្រោយពេលកំណើតរបស់កូន គេអាចកំណត់យកឪពុកជាអ្នកមានអំណាចមេបាទៅតាមការពិភាក្សារបស់ឪពុកម្តាយបាន។ ប្រសិនបើពិភាក្សាពុំបានសម្រេចទេ តុលាការត្រូវកំណត់យកអ្នកដែលមានអំណាចមេបាដោយពិចារណាទៅលើផលប្រយោជន៍របស់កូននោះ។[98]

អ្នកមានអំណាចមេបា មានសិទ្ធិ គ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនដែលជាអនីតិជន និងតំណាង (អ្នកតំណាងដែលច្បាប់ បានកំណត់) ឱ្យកូនចំពោះសកម្មភាពទាក់ទងនឹងទ្រព្យសម្បត្តិនោះ ដូចជាការចុះ កិច្ចសន្យា ការអនុវត្តសិទ្ធិលុបចោល ការអនុញ្ញាតឱ្យប្រកបអាជីវកម្ម ជាអាទិ៍។[99]

ក្នុងករណីពុំមានអ្នកអនុវត្តអំណាចមេបាចំពោះកូនជាអនីតិជន របបអាណាព្យាបាលសម្រាប់អនីតិជនត្រូវចាប់ផ្តើម ហើយអ្នកអាណាព្យាបាលសម្រាប់អនីតិជន ជាអ្នកមានសិទ្ធិអំណាចមេបា។[100] អ្នកអាណាព្យាបាលសម្រាប់អនីតិជនមិនមែនជាឪពុកម្តាយរបស់អនីតិជននោះទេ ពោលគឺជាបុគ្គលដែលត្រូវបានជ្រើសតាំងដោយតុលាការ ឬ តាមការកំណត់នៅក្នុងមតកសាសន៍។[101]

មួយវិញទៀតដើម្បីជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន តុលាការត្រូវគិត ពិចារណាអំពីស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត និង ស្ថានភាពជីវភាព និង ទ្រព្យសម្បត្តិ របស់អនីតិជន វិជ្ជាជីវៈ និង ប្រវត្តិរូប

[95] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៣៤។
[96] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៣៧ (១)។
[97] ក្រមរដ្ឋប្បវេណីលេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៣៧ (២)។
[98] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៣៧។
[99] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៥៣។
[100] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៦៧។
[101] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៦៨។

របស់អ្នកដែលត្រូវធ្វើជាអ្នកអាណាព្យាបាលសម្រាប់ អនីតិជន និង អត្ថិភាព ឬ នត្ថិភាព នៃទំនាក់ទំនងទៅនឹង ផលប្រយោជន៍ រវាងអ្នកធ្វើជា អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជន យោបល់របស់អនីតិជន និង ស្ថានភាព ផ្សេងទៀតទាំងស្រុង។[102]

ចំពោះភាគីដែលមិនមានអំណាចមេបាលើកូនគាត់មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងកូន និង ករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថៃរក្សាកូន។[103] ម៉្យាងទៀតពាក់ព័ន្ធនឹងការសម្រេច សេចក្ដីពីការចូលជួប និងប្រាស្រ័យទាក់ទង ក្រមរដ្ឋប្បវេណីតម្រូវឱ្យតុលាការធ្វើការពិចារណាទៅលើផល ប្រយោជន៍របស់កូនជាអាទិភាព។ ក្នុងន័យនេះតុលាការអាចពិនិត្យពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំនាក់ទំនងរវាងកូន និងឪពុកម្ដាយនៅពេលដែលរស់នៅជាមួយគ្នា អាយុ ស្ថានភាព សុខភាព របស់កូន បំណងរបស់កូន បំណងរបស់ភាគីទាំងសងខាង ព្រមទាំងស្ថានភាពផ្លូវចិត្តរបស់ភាគីទាំងសងខាងជាដើម។ មួយវិញទៀតតុលាការត្រូវពិចារណាទៅលើស្ថានភាពនៃជីវភាពសេដ្ឋកិច្ចរបស់ឪពុកម្ដាយទាំងសងខាងផងដែរ។ ទាក់ទងនឹងការសម្រេចសេចក្ដីពីការកំណត់អ្នកមានអំណាចមេបា តុលាការត្រូវពិចារណាថ្លឹងថ្លែងទៅលើ យោបល់របស់កូនសមស្របទៅតាមអាយុនិងសភាពចាស់ទុំរបស់កូន។[104] ហើយតុលាការក៏អាចនិងផ្លាស់ប្ដូរ អ្នកមានអំណាចមេបាតាមការទាមទាររបស់ញាតិនៅក្នុង៤ថ្នាក់របស់កូនបានប្រសិនបើទទួលស្គាល់ថាចាំបាច់ ដើម្បីគ្រប់គ្រងថៃរក្សាកូន។[105]

### ៣.៣.២. អាហារកាតព្វកិច្ចចំពោះកូន

អាហារកាតព្វកិច្ច គឺសំដៅទៅលើកិច្ចដែលត្រូវតែបំពេញតាមផ្លូវច្បាប់ ឬតាមសេចក្ដីសម្រេចរបស់ តុលាការដែលតម្រូវឲ្យបុគ្គលម្នាក់ ឬច្រើននាក់ផ្ដល់ប្រាក់ ឬទ្រព្យដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅដល់បុគ្គលផ្សេង ទៀតដែលមានទំនាក់ទំនងញាតិនឹងគ្នា។[106] ជាទូទៅនៅពេលលែងលះ គូភាគីអាចធ្វើការពិភាក្សាអំពីការផ្ដល់ អាហារកាតព្វកិច្ចបាន ប៉ុន្តែក្នុងករណីដែលពិភាក្សាគ្នាមិនបានសម្រេចទេ ភាគីអាចដាក់ពាក្យសុំទាមទារ ហើយ តុលាការអាចសម្រេចឱ្យបានផងដែរ។

នៅក្នុងករណីលែងលះ ឪពុក ឬ ម្ដាយដែលមានអំណាចមេបាមានសិទ្ធិ និងករណីកិច្ចត្រូវបីបាច់រក្សា កូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ។[107] ភាគីដែលមិនបានថៃក្សាកូនមានកាតព្វកិច្ច ផ្ដល់អាហារកិច្ចដល់កូនតាមលទ្ធភាពរបស់ខ្លួន ឬអាហារកាតព្វកិច្ចអាចជាប្រាក់ និងជារបស់អ្វីមួយ។ ដូចនេះ ក្រោយពីការលែងលះ ឪពុក ឬ ម្ដាយត្រូវមានអាហារកិច្ចដល់កូនរបស់ខ្លួនដដែលពីព្រោះឪពុកម្ដាយដែលបាន

[102] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៦៨ (៣)។

[103] ក្រមរដ្ឋប្បវេណី. លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៤០ (១)។

[104] ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា២២ (៤)។

[105] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៤០ (៤)។

[106] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សន្ទានុក្រម លេខ២០២ ។

[107] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៣៤។

លែងលះគ្នារួចមកហើយនោះគឺនៅតែជាញាតិខ្សែផ្ទាល់របស់កូនជានិច្ច។[108] បន្ទុកសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន គិតចាប់ពីពេលសេចក្តីសម្រេចលែងលះចូលជាស្ថាពររហូតកូនដល់នីតិភាព។

មួយវិញទៀត ឪពុក ឬម្តាយដែលពុំមានអំណាចមេបាលើកូនអាចទាមទារឲ្យអ្នកដែលមានអំណាចមេបារាយការណ៍អំពីស្ថានភាពរបស់កូនដែល ត្រូវបានកំណត់តាមការពិភាក្សរវាងឪពុកម្តាយ ប៉ុន្តែបើការពិភាក្សាពុំបានសម្រេច ឬបើពុំអាចធ្វើការពិភាក្សាបានទេ តុលាការអាចសម្រេចសេចក្តីជំនួសការពិភាក្សាតាមការទាមទាររបស់ឪពុកម្តាយបានព្រមទាំងញាតិក្នុង៤ (បួន) ថ្នាក់របស់កូន ក៏អាចទាមទារឲ្យរាយការណ៍អំពីស្ថានភាពរបស់កូនចំពោះអ្នកមានអំណាចមេបាបានផងដែរ។[109]

### ៣.៣.៣. អាហារកាតព្វកិច្ចចំពោះសហព័ទ្ធ

ប្រសិនបើករណីលែងលះភាគីដែលគ្មានកំហុស ឬ មានការខ្វះខាតមានន័យថាភាគីដែលគ្មានកំហុសពុំមានទ្រព្យសម្បត្តិ ឬមុខរបរជាក់លាក់សម្រាប់ចិញ្ចឹមជីវិតខ្លួនឯងបានអាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតបានហើយភាគីនោះត្រូវតែជួយឧបត្ថម្ភទៅតាមលទ្ធភាពរបស់ខ្លួនទៅតាមការយល់ព្រមរបស់គូរភាគីទាំងសងខាង។ ក្នុងករណីដែលគូរភាគីទាំងសងខាងមិនឯកភាពគ្នា តុលាការ នឹងជាអ្នកសម្រេចអំពីអាហារកិច្ចនោះ។[110]

តុលាការអាចកែប្រែដោយបង្កើន ឬត្រូវបន្ថយកម្រិតអាហារកិច្ចបានតាមការសំណូមពរពីភាគីម្ខាងដោយត្រូវពិនិត្យពិចារណាទៅលើប្រាក់បៀវត្សលទ្ធភាពនៃការរកប្រាក់ចំណូល អាយុ សុខភាពរបស់ជននោះដើម្បីកំណត់ពីកម្រិតនៃអាហារកិច្ចដែលត្រូវបង់នោះ។[111] ប្រសិនបើភាគីម្ខាងនោះមិនព្រមបង់អាហារកាតព្វកិច្ចទេភាគីនោះនិងត្រូវផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន បើកាលណាមានភស្តុតាងបញ្ជាក់ថាជននោះដែលត្រូវផ្តល់អាហារកិច្ចមិនស្មោះត្រង់។[112] បើភាគីដែលទទួលអាហារកិច្ចបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀតភាគីនោះលែងមានសិទ្ធិទទួលអាហារកិច្ចទៀតហើយ។[113]

---

[108] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៤០។

[109] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៤១។

[110] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៧៦។

[111] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៧៧។

[112] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៧៨។

[113] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៧៦។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយប្រធានបទ " **ការលែងលះរវាងសហព័ទ្ធខ្មែរ** " ខាងលើរួចមក យើងខ្ញុំយល់ឃើញថាការលែងលះ គឺជាកត្តាមួយដែលមនុស្សនៅក្នុងសង្គមបានជួបប្រទះ ហើយវាក៏ជាបញ្ហានៅក្នុងគ្រួសារដែលធ្វើឲ្យសហព័ទ្ធទាំងសងខាងត្រូវប្រឈមមុខ នឹងភាពស្មុគស្មាញ និងបញ្ហាជាច្រើនទៀតផងដែរ។ ផ្ទុយទៅវិញចំណងអាពាហ៍ពិពាហ៍មួយអាចកើតឡើងបានលុះត្រាតែគូភាគីគោរពទៅតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់ព្រមទាំងលក្ខខណ្ឌផ្សេងៗទៀតដែលច្បាប់បានតម្រូវឲ្យសហព័ទ្ធនីមួយៗត្រូវអនុវត្តតាម។ មួយវិញទៀតសហព័ទ្ធទាំងសងខាងត្រូវតែទៅចុះសំបុត្រអាពាហ៍ពិពាហ៍ បើពុំនោះទេចំណងអាពាហ៍ពិពាហ៍របស់ពួកគាត់ទាំងពីរពុំត្រឹមត្រូវតាមច្បាប់ឡើយ។ ប្រសិនបើចំណងអាពាហ៍ពិពាហ៍ដែលស្របច្បាប់នោះជួបបញ្ហាមួយចំនួនដែលឈានដល់ដំណាក់កាលមួយមិនអាចរួមរស់ជាមួយគ្នាបានទៀតទេនោះធ្វើឲ្យចំណងអាពាហ៍ពិពាហ៍របស់សហព័ទ្ធទាំងពីរត្រូវបែកបាក់រហូតឈានដល់ការលែងលះ។ ក្នុងករណីដែលសហព័ទ្ធទាំងពីរចង់លែងលះត្រូវតែដាក់ពាក្យសុំទៅតុលាការដើម្បីត្រូវឆ្លងកាត់ដំណាក់កាលនៃនីតិវិធីរបស់តុលាការជាច្រើនទៀតទើបពួកគេទាំងពីរអ្នកលែងលះគ្នាដាច់។ ការលែងលះធ្វើឲ្យសហព័ទ្ធទាំងពីរមានការខាតបង់ថវិកា និងត្រូវចំណាយពេលវេលាជាច្រើនដែលធ្វើឲ្យប៉ះពាល់ទៅដល់ការប្រកបការងារគ្រួសារ និង សង្គមជាតិ។

តាមរយៈការស្រាវជ្រាវនិងប្រធានបទនេះ ការលែងលះនៅប្រទេសកម្ពុជាចែកចេញជាពីរប្រភេទគឺការលែងលះដោយការព្រមព្រៀង និងការលែងលះដោយគ្មានការព្រមព្រៀង។ ការលែងលះដោយការព្រមព្រៀង គឺជាការលែងលះដែលសហព័ទ្ធទាំងពីរមានឆន្ទៈស្របគ្នាក្នុងការព្រមព្រៀងលែងលះ និងកំណត់អំពីការបែងចែកសិទ្ធិ និងកាតព្វកិច្ចផ្សេងៗទៀតក្រោយការលែងលះ។ ចំពោះការលែងលះដោយគ្មានការព្រមព្រៀងវិញ គឺជាការប្តឹងទាមទារលែងលះដោយភាគីមានការខ្វែងគំនិតគ្នានៅផ្នែកណាមួយ ឬទាំងស្រុងនៃការបែងចែក និងការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្តហើយទាមទារឲ្យមានការសម្រេចដោះស្រាយពីតុលាការ។ ហើយនីតិវិធីនៃការដោះស្រាយចំពោះការលែងលះនេះគឺត្រូវអនុលោមតាមច្បាប់នីតិវិធីមួយចំនួនអាស្រ័យទៅលើលក្ខខណ្ឌនៃការលែងលះ។

បន្ទាប់ពីតុលាការបានបញ្ចប់នីតិវិធីនៅក្នុងការលែងលះដោយចេញនូវសេចក្តីសម្រេច ឬ សាលក្រមនោះបង្កើតឲ្យមានអានុភាពនៃការលែងលះ។ ដោយសហព័ទ្ធទាំងពីរត្រូវតែធ្វើការព្រមព្រៀងគ្នានូវការបែងចែកទ្រព្យសម្បត្តិ ការផ្តល់អាហារកាតព្វកិច្ចដល់កូន និងអតីតសហព័ទ្ធណាមួយដែលមានការខ្វះខាតជីវភាពក្រោយការលែងលះ ការប្រគល់អំណាចមេបាដោយឲ្យកូនទៅនៅជាមួយសហព័ទ្ធណាមួយ និងសហព័ទ្ធដែលមានអំណាចមេបាត្រូវផ្តល់ពេលវេលាណាមួយច្បាស់លាស់ដើម្បីឲ្យសហព័ទ្ធដែលមិនមានអំណាចមេបាបានជួបប្រាស្រ័យទាក់ទងជាមួយកូនផងដែរ។

ជាចុងក្រោយការបង្ហាញអំពីនីតិវិធីនៃការលែងលះរវាងសហព័ន្ធខ្មែរនៅកម្ពុជាចាប់តាំងពីពេលដែលមានចំណងអាពាហ៍ពិពាហ៍នោះរហូតដល់ការបង្កឲ្យមានមូលហេតុនៃការលែងលះ និងដល់ការអនុវត្តលំហូរនីតិវិធីនៃការលែងលះ ព្រមទាំងការសម្រេចសេចក្ដីដោយតុលាការចំពោះការលែងលះនៅកម្ពុជារួចមក។ យើងគួរគប្បីសិក្សាស្វែងយល់ពិនិត្យគិតពិចារណាពីគ្នាឲ្យបានច្បាស់លាស់ស៊ីជម្រៅនៅក្នុងការរើសដៃគូរជីវិតមួយដែលស្មោះត្រង់ និងការឲ្យតម្លៃគ្នាទៅវិញទៅមកពីព្រោះនៅពេលដែលយើងមានការជ្រើសរើសដៃគូរជីវិតខុសនោះគឺបង្កឲ្យមានការរស់នៅជាមួយគ្នាមិនចុះសម្រុងមានតែបញ្ហាជាមួយគ្នារហូតនោះនឹងឈានដល់ការលែងលះគ្នាជាពុំខានឡើយ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានសិក្សាស្រាវជ្រាវអំពីប្រធានបទ " **ការលែងលះរវាងសហព័ន្ធខ្មែរ** " រួចមក យើងខ្ញុំយល់ឃើញថាការលែងលះពិតជាមានភាពលំបាកជាខ្លាំង ក៏ដូចជាផ្តល់គុណវិបត្តិជាច្រើនដល់ភាគីបណ្តឹង និងកូនៗថែមទៀតផង។ ការខាតបង់ដែលបង្កមកពីការលែងលះមានច្រើនយ៉ាងដូចជា៖ ការខាតបង់ទ្រព្យសម្បត្តិ ការខាតពេលវេលា ការបាត់បង់សុភមង្គលពិសេសគឺការប៉ះពាល់ទៅដល់កិត្តិយសក្រុមគ្រួសារ។ នេះហើយដែលជាមូលហេតុដែលនាំឲ្យយើងខ្ញុំមានសំណូមពរចំនួនបីចំណុចទាក់ទងនឹងការលែងលះរវាងពលរដ្ឋខ្មែរនៅកម្ពុជា។

**ចំណុចទីមួយ៖** សហព័ន្ធទាំងអស់គួរមេត្តាចេះយោគយល់អត់ឱនឱ្យគ្នាក៏ដូចជាអធ្យាស្រ័យគ្នាឱ្យបានច្រើនព្រោះថានៅពេលដែលសហព័ន្ធនីមួយៗធ្វើការលែងលះគ្នា នឹងផ្តល់គុណវិបត្តិផ្សេងៗជាពិសេសសុភមង្គលក្នុងគ្រួសារ។ ពោលគឺដើម្បីអោយគ្រួសារមួយមានសុភមង្គលទៅមុខតទៅទៀតបាននោះគឺភាគីដែលត្រូវជាប្តីប្រពន្ធត្រូវមានការយល់ពីគ្នា និងចេះគិតពិចារណាអោយត្រឹមត្រូវ ដោយត្រូវបំពេញនូវតួនាទីភារកិច្ចកាតព្វកិច្ចរបស់ខ្លួនដូចជាការធ្វើជាគំរូដល់កូនក្នុងការធ្វើជាប្តីល្អ ប្រពន្ធល្អដែលត្រូវចេះសហការជួយគ្នាក្នុងពេលមានអាសន្នជាដើម។

**ចំណុចទីពីរ៖** សូមរាជរដ្ឋាភិបាលធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឱ្យបានយល់ដឹងគ្រប់ៗគ្នា ជាពិសេសដាក់ទណ្ឌកម្មដល់អ្នករំលោភបំពានច្បាប់នេះ និងអ្នកប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារឲ្យមានលក្ខណៈធ្ងន់ធ្ងរ និងសូមឲ្យមានការការពារផ្លូវច្បាប់ដោយតុលាការនៅក្នុងករណីមានការលែងលះគ្នា។ មួយវិញទៀតសូមរាជរដ្ឋាភិបាលមេត្តាទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងឲ្យមានប្រសិទ្ធភាពនិងស្របតាមពេលវេលាជាក់ស្តែង។ ព្រោះទង្វើទាំងអស់នេះវាជាមូលហេតុដែលនាំឲ្យមានការលែងលះកើតមានឡើង។

**ចំណុចទីបី៖** ចំពោះមន្ត្រីអនុវត្តច្បាប់សូមឲ្យមន្ត្រីនៅថ្នាក់មូលដ្ឋានដែលពាក់ព័ន្ធទៅនឹងសំណុំរឿងនៃការលែងលះគួរតែជួយផ្សះផ្សាសហព័ន្ធនោះឲ្យអស់លទ្ធភាពជាមុនសិនមុនពេលសម្រេចចិត្តឲ្យពួកគាត់លែងលះគ្នាតាមផ្លូវតុលាការ ព្រមទាំងផ្តល់ជំនួយផ្លូវច្បាប់ណាមួយដែលសមស្របតាមរយៈកាលៈទេសៈជាក់ស្តែង និងធានាសុវត្ថិភាពដល់គូភាគីនៅពេលមានបណ្តឹងលែងលះកើតឡើង និងសូមឲ្យអាជ្ញាធរដែនដីធ្វើអន្តរាគមន៍ជាបន្ទាន់រាល់ពេលមានអំពើហិង្សាកើតឡើងដើម្បីទប់ស្កាត់កុំឲ្យមានអំពើហិង្សាធ្ងន់ធ្ងររហូតឈានទៅដល់ការលែងលះគ្នា។

# ឯកសារយោង

# ឯកសារយោង

## ក. ច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណី នៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី នៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- ច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦
- ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០
- ច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០
- ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩
- ច្បាប់ស្តីពីអត្រានុកូលស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣

## ខ. បទបញ្ជា

- អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង

## គ. សៀវភៅ និង ឯកសារផ្សេងៗ

- សៀវភៅនីតិរដ្ឋប្បវេណី, ប៊ុយ ធីតា,ឆ្នាំ២០២៤
- សទ្ទានុក្រមផ្នែករដ្ឋប្បវេណី នៃ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
- https://www.youtube.com/channel/UCoinOp_eDdBBj7w7pvJ6cQ?view_as=subscriber
- https://youtu.be/-FcXyqu1I7Y

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី ១ ៖ គម្រូឯកសារផ្ទៀងផ្ទាត់តាមផ្នែក**

១. ប្រកាសលេខ ២៨ កយប្រក/០៧ នៃទីស្ដីការក្រសួងយុត្តិធម៌, ឆ្នាំ២០០៧។

២. ប្រកាស ស្ដីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ, ឆ្នាំ២០១៣។

**ឧបសម្ព័ន្ធទី ២ ៖ទម្រង់លិខិតរដ្ឋបាលពាក់ព័ន្ធនឹងការលែងលះដោយព្រមព្រៀង**

១. កិច្ចព្រមព្រៀងលែងលះ

២. លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

៣. ពាក្យសុំតំណាងដោយអាណត្តិ

៤. ពាក្យសុំពិនិត្យ និងថតចម្លងសំណុំរឿង

៥. ពាក្យសុំលែងលះ

៦. បង្កាន់ដៃបង់ប្រាក់ថ្លៃដាក់ពាក្យសុំ

៧. ដីកាសម្រេចឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

៨. បង្កាន់ដៃបង់ពន្ធ

៩. លិខិតអញ្ជើញមេធាវី

១០. ដីកាកោះ (នីតិវិធីសាកសួរ)

១១. ដីកាសម្រេចរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

១២. លិខិតបញ្ជាក់ការចូលជាស្ថាពរនៃដីកាសម្រេច

១៣. បង្កាន់ដៃបង់ប្រាក់ថ្លៃដាក់លិខិតបញ្ជាក់ការចូលជាស្ថាពរនៃដីកាសម្រេច

## ឧបសម្ព័ន្ធទី៣៖ ទម្រង់លិខិតរដ្ឋបាលពាក់ព័ន្ធនឹងការលែងលះដោយគ្មានការព្រមព្រៀង

១. ពាក្យបណ្ដឹងលែងលះ

២. បង្កាន់ដៃបង់ប្រាក់ថ្លៃដាក់ពាក្យបណ្ដឹង

៣. លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

៤. លិខិតតំណាងដោយអាណត្តិ

៥. ពាក្យសុំពិនិត្យ និងថតចម្លងសំណុំរឿង

៦. ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ

៧. លិខិតអញ្ជើញមេធាវី (នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល)

៨. ដីកាកោះ (នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល)

៩. របាយការណ៍បញ្ជូន

១០. កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

១១. សេចក្ដីថ្លែងការណ៍

១២. ពាក្យសុំបញ្ជូលភស្តុតាង

១៣. ពាក្យសុំឱ្យកោះហៅសាក្សី

១៤. លិខិតអញ្ជើញមេធាវី (នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់)

១៥. ដីកាកោះ (នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់)

១៦. សាលក្រមលែងលះ

១៧. លិខិតចូលជាស្ថាពរនៃសាលក្រម

១៨. ពាក្យបណ្ដឹងឧទ្ធរណ៍

# ឧបសម្ព័ន្ធទី១ ៖

# កម្រងបទដ្ឋានគតិយុត្ត

# ឧបសម្ព័ន្ធទី២ ៖
# ទម្រង់លិខិតរដ្ឋបាលពាក់ព័ន្ធនឹងការលែងលះដោយព្រមព្រៀង

# កិច្ចព្រមព្រៀងលែងលះ

រវាង

លោកស្រី

(ភាគី "ក")

និង

លោក

(ភាគី "ខ")

កាលបរិច្ឆេទៈ ថ្ងៃទី ខែ ឆ្នាំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងលែងលះ

កិច្ចព្រមព្រៀងលែងលះនេះ (“**កិច្ចព្រមព្រៀង**”) ត្រូវបានធ្វើឡើងនៅថ្ងៃទី ខែ ឆ្នាំ ដោយ និងរវាង៖

១. **លោកស្រី** សញ្ជាតិខ្មែរ កើតថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ (តទៅនេះហៅថា **ភាគី “ក”**) និង

២. **លោក** សញ្ជាតិខ្មែរ កើតថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ផ្សារកណ្ដាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ (តទៅនេះហៅថា **ភាគី “ខ”**)។

ភាគីនីមួយៗហៅដោយឡែកពីគ្នាថា “**ភាគី**” និងហៅជារួមថា “**ភាគីទាំងអស់**” ឬ “**ភាគីទាំងពីរ**”។

## <u>បុព្វកថា</u>

**ដោយហេតុថា៖**

**ក.** ភាគីទាំងពីរបានរៀបអាពាហ៍ពិពាហ៍នឹងគ្នា ហើយទទួលបានសំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី ខែ ឆ្នាំ ។ *ច្បាប់ថតចម្លងនៃសំបុត្រអាពាហ៍ពិពាហ៍ខាងលើ មានភ្ជាប់ជាឧបសម្ព័ន្ធ ១ នៃកិច្ចព្រមព្រៀងនេះ។*

**ខ.** ភាគីទាំងពីរបានបាត់បង់អស់នូវមនោសញ្ចេតនាចំពោះគ្នា និងមិនអាចរស់នៅចុះសម្រុងជាមួយគ្នាក្នុងនាមជាប្ដីប្រពន្ធតទៅទៀត។

## ហេតុដូចនេះ ភាគីទាំងពីរបានព្រមព្រៀងគ្នា ដូចខាងក្រោម៖

### ប្រការ ១ ៖ អំពីការលែងលះ

ភាគីទាំងពីរបានព្រមព្រៀងលែងលះគ្នាដោយគោលការណ៍ស្ម័គ្រចិត្តទាំងសងខាង និងដោយគ្មានការបង្ខិតបង្ខំអ្វីទាំងអស់ពីភាគីណាមួយនោះឡើយ។

### ប្រការ ២ ៖ អំពីកូន

**២.១** ភាគីទាំងពីរអះអាងថា ភាគីទាំងពីរ មានកូន ០២ នាក់ ដែលមានអត្តសញ្ញាណដូចខាងក្រោម៖

- កុមារី ភេទស្រី សញ្ជាតិខ្មែរ កើតនៅថ្ងៃទី ខែ ឆ្នាំ នៅសង្កាត់ផ្សារកណ្ដាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា ដែលបញ្ជាក់ដោយសេចក្ដីចម្លងសំបុត្រកំណើត ចុះថ្ងៃទី ខែ ឆ្នាំ ។

- កុមារា ភេទប្រុស សញ្ជាតិខ្មែរ កើតនៅថ្ងៃទី ខែ ឆ្នាំ នៅសង្កាត់ផ្សារកណ្តាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា ដែលបញ្ជាក់ដោយសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី ខែ ឆ្នាំ ។

  *ច្បាប់ថតចម្លងនៃសេចក្តីចម្លងសំបុត្រកំណើត និង សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតខាងលើមានភ្ជាប់ជាឧបសម្ព័ន្ធ ២ នៃកិច្ចព្រមព្រៀងនេះ។*

**២.២** ភាគីទាំងពីរព្រមព្រៀងកំណត់អំពី សិទ្ធិអំណាចមេបា ដូចខាងក្រោម៖

- **ភាគី "ក"** ទទួលបាននូវសិទ្ធិអំណាចមេបាលើកូនប្រុសឈ្មោះ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី ខែ ឆ្នាំ ។
- **ភាគី "ខ"** ទទួលបាននូវសិទ្ធិអំណាចមេបាលើកូនស្រីឈ្មោះ ភេទ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី ខែ ឆ្នាំ ។

**២.៣** ភាគីទាំងពីរព្រមព្រៀងគ្នាថា **ភាគី "ខ"** ត្រូវផ្តល់អាហារកាតព្វកិច្ច និងទំនុកបម្រុងសព្វគ្រប់បែបយ៉ាងដល់កូនទាំងពីរខាងលើ ចំណែកឯ **ភាគី "ក"** ត្រូវផ្តល់អាហារកាតព្វកិច្ច ដល់កូនទាំងពីរខាងលើ តាមលទ្ធភាពរហូតដល់កូនទាំងពីរនេះដល់នីតិភាព។

**២.៤** ភាគីទាំងពីរព្រមព្រៀងគ្នាថា ភាគីនីមួយៗត្រូវបង្កលក្ខណៈងាយស្រួលដល់គ្នាទៅវិញទៅមក ក្នុងការចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនទាំងពីរខាងលើបាន ដោយមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ទំនាក់ទំនងរវាងកូនទាំងពីរឡើយ។

## ប្រការ ៣ ៖ អំពីការបែងចែកទ្រព្យសម្បត្តិ និងការទទួលបំណុល

ភាគីទាំងពីរព្រមព្រៀងបែងចែកទ្រព្យសម្បត្តិ និងទទួលបំណុល ដូចខាងក្រោម៖

**៣.១ ភាគី "ក"** ត្រូវទទួលបាននូវទ្រព្យសម្បត្តិ និងទទួលបំណុល ដូចតទៅ៖

**ក. ភាគី "ក"** ត្រូវទទួលបាននូវទ្រព្យសម្បត្តិ ដូចខាងក្រោម៖

- ដីទំហំ **ម២** ( ម៉ែត្រការ៉េ) មានទីតាំងស្ថិតនៅភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ សម្គាល់ដោយវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ ។

  *ច្បាប់ថតចម្លងនៃវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុខាងលើ មានភ្ជាប់ជាឧបសម្ព័ន្ធ ៣ នៃកិច្ចព្រមព្រៀងនេះ។*

- ភាគហ៊ុននៅក្នុងហាងកាហ្វេ សាខា ចំនួន % ( ភាគរយ) ត្រូវនឹងទឹកប្រាក់ចំនួន USD ( ដុល្លារអាមេរិក) មានទីតាំងស្ថិតនៅភូមិ មហាវិថី ខណ្ឌ រាជធានីភ្នំពេញ ដែលសម្គាល់ដោយលិខិតបញ្ជាក់ភាគហ៊ុនធ្វើឡើងកាលពីថ្ងៃទី ខែ ឆ្នាំ ។

*ច្បាប់ថតចម្លងនៃលិខិតបញ្ជាក់ភាគហ៊ុនខាងលើ មានភ្ជាប់ជាឧបសម្ព័ន្ធ ៤ នៃកិច្ចព្រមព្រៀងនេះ។*

**ខ.** **ភាគី "ក"** ត្រូវទទួលបំណុល ដូចខាងក្រោម៖

- បំណុលធនាគារ ចំនួន USD ( ដុល្លារអាមេរិក) ដែលបានខ្ចីយកមកទិញ ដី និង ផ្ទះ ទំហំ ម² ( ម៉ែត្រការ៉េ) មានទីតាំងស្ថិតនៅភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ដែលសម្គាល់ដោយវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ ។
- បំណុលចំនួន USD ( ដុល្លារអាមេរិក) ដែលបានខ្ចីពីតតិយជន យកមកទិញភាគហ៊ុននៅក្នុងហាងកាហ្វេ មានទីតាំងស្ថិតនៅភូមិ មហាវិថី ខណ្ឌ រាជធានីភ្នំពេញ។

**៣.២** **ភាគី "ខ"** ត្រូវទទួលបាននូវទ្រព្យសម្បត្តិ ដូចខាងក្រោម៖

- សិទ្ធិលើបំណុលជាប្រាក់ចំនួន USD ( ដុល្លារអាមេរិក) ដែល **ភាគី "ខ"** បានយកឱ្យតតិយជនខ្ចី។

## ប្រការ ៤ ៖ សិទ្ធិលើបំណុលរវាងសហព័ទ្ធ

ភាគីទាំងពីរអះអាងថា ពួកគេទាំងពីរពុំមានសិទ្ធិលើបំណុលចំពោះគ្នាទៅវិញទៅមកនោះទេ។

## ប្រការ ៥ ៖ ការរក្សាទុកកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះធ្វើឡើងចំនួន ០៣ (បី) ច្បាប់ ដែលមួយច្បាប់រក្សាទុកនៅ **ភាគី "ក"** មួយច្បាប់រក្សាទុកនៅ **ភាគី "ខ"** និងមួយច្បាប់ទៀតរក្សាទុកនៅ ក្រុមមេធាវី ។

*(ផ្នែកដែលនៅសល់នៃទំព័រនេះត្រូវបានទុកឱ្យនៅទំនេរដោយចេតនា)*



**ដើម្បីជាសក្ខីភាព** ភាគីនីមួយៗចុះហត្ថលេខា និងផ្តិតស្នាមមេដៃ នៅកាលបរិច្ឆេទដែលបានកំណត់ខាងលើ។

| **ភាគី "ក"** | | **ភាគី "ខ"** | |
|---|---|---|---|
| **ហត្ថលេខា** | **ស្នាមមេដៃ** | **ហត្ថលេខា** | **ស្នាមមេដៃ** |
| ........................ | | ........................ | |
| លោកស្រី | | លោក | |

**បានឃើញ និងបញ្ជាក់ថា**

ភាគីទាំងពីរពិតជាបានចុះហត្ថលេខា និងផ្តិតស្នាមមេដៃ

នៅចំពោះមុខមេធាវីពិតប្រាកដមែន។

ថ្ងៃទី ខែ ឆ្នាំ

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី.

**GG INTERNATIONAL**
**ក្រុមហ៊ុនមេធាវី ជីជី អន្តរជាតិ**
GG International Law Firm
លេខ: ................ក.ជ.ជ.អ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
ចូល លេខ ...... ថ្ងៃទី ...... ខែ ...... ឆ្នាំ ២០២៣ ម៉ោង ...... និង ...... នាទី

ថ្ងៃ ឆ្នាំ បញ្ចស័ក ព.ស២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី..... ខែ ឆ្នាំ២០២៣

## ពាក្យសុំពិនិត្យ និងថតចម្លងសំណុំរឿង

ខ្ញុំមេធាវី អត្តលេខ សមាជិកនៃ **ក្រុមហ៊ុនមេធាវី ជីជី អន្តរជាតិ** ដែលមានអាសយដ្ឋានស្ថិតនៅអាគារលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ក្នុងសំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹងលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

ទូរស័ព្ទទំនាក់ទំនងលេខ៖

**សូមគោរពចូលមក**

**ឯកឧត្តមប្រធាន សាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖ សំណើសុំពិនិត្យ និងថតចម្លងសំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹងលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង** ៖ -មាត្រា២៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។
-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ឈ្មោះ ចុះថ្ងៃទី ខែ ឆ្នាំ ។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ ឈ្មោះ បានប្រគល់សិទ្ធិឲ្យនាងខ្ញុំធ្វើជាមេធាវីតំណាងដោយអាណត្តិឲ្យរូបគាត់ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីដូចដែលមានចែងក្នុងកម្មវត្ថុខាងលើ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាឲ្យនាងខ្ញុំបានពិនិត្យ និងថតចម្លងសំណុំរឿង រដ្ឋប្បវេណីខាងលើទៅតាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

**ហត្ថលេខា និងត្រា**

AVOCAT ATTORNEY AT LAW
KINGDOM OF CAMBODIA

មេធាវី


GG International Law Firm
Registered under the Bar Association of the Kingdom of Cambodia
# 224D Street 20, Prek Talong Village, Sangkat Chak Angre Kroam, Khan Mean Chey, Phnom Penh, Cambodia
Phone: +855 93 337 626 , E-mail: official@ggi.law , web: www.ggi.law

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
៣៣៣ ✵ ១១១

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្ដឹងលេខ
ចុះថ្ងៃទី ខែ ឆ្នាំ

## <u>លិខិតអញ្ជើញមេធាវី</u>

យើង **ទីវ គីមពិសាល** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ លិខិតតំណាងដោយអាណត្តិ ចុះថ្ងៃទី ខែ ឆ្នាំ របស់មេធាវី អត្តលេខ ជាមេធាវីនៃ ក្រុមមេធាវី ស្ដីពីការធ្វើជាមេធាវីតំណាងដោយអាណត្តិឱ្យអ្នកដាក់ពាក្យសុំឈ្មោះ ។
- សូមអញ្ជើញលោកមេធាវី អត្តលេខ មានការិយាល័យនៅផ្ទះលេខ ផ្លូវ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។
- <u>ចូលខ្លួនមកកាន់សាលាដំបូងរាជធានីភ្នំពេញ នៃអគារសាលាយុត្តិធម៌ បន្ទប់</u> <u>ជាន់ទី</u> <u>នៅថ្ងៃទី</u> <u>ខែ</u> <u>ឆ្នាំ</u> <u>វេលាម៉ោង</u> <u>និង</u> <u>នាទីព្រឹក</u>។
- ដើម្បី៖ <u>ចូលរួមនីតិវិធីសាកសួរជាមួយកូនក្ដី</u>។
- ពីដំណើររឿង៖ <u>កូនក្ដីរបស់មេធាវីសុំលែងលះតាមការព្រមព្រៀង</u>។
- សូមមេធាវីអញ្ជើញចូលរួមឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើនេះមកជាមួយផង ប្រសិនបើមាន។

ថ្ងៃ ខែ ព.ស.

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**ចៅក្រម**

**ទីវ គីមពិសាល**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្ដឹងលេខ
ចុះថ្ងៃទី ខែ ឆ្នាំ

## <u>ដីកាកោះ</u>

យើង **ទីវ គឹមពិសាល** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

- កោះហៅឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ ជា<u>អ្នកដាក់ពាក្យសុំ</u>។
- មានទីលំនៅសព្វថ្ងៃ ភូមិ សង្កាត់ ក្រុង ខេត្ត ។
- <u>ឱ្យចូលខ្លួនមកកាន់សាលាដំបូងរាជធានីភ្នំពេញ នៃអគារសាលាយុត្តិធម៌ បន្ទប់</u> <u>ជាន់ទី</u> <u>នៅថ្ងៃទី</u> <u>ខែ</u> <u>ឆ្នាំ</u> <u>វេលាម៉ោង</u> <u>និង</u> <u>នាទីព្រឹក</u>។
- ដើម្បី៖ <u>សាកសួរ</u>។
- ពីដំណើររឿង៖ <u>សុំលែងលះតាមការព្រមព្រៀង</u>។
- សាមីខ្លួន ត្រូវអញ្ជើញតាមដីកាកោះនេះឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើនេះមកជាមួយផង ប្រសិនបើមាន។

ថ្ងៃ ខែ ឆ្នាំ ព.ស.

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ

**ចៅក្រម**

**ទីវ គឹមពិសាល**

---

អាសយដ្ឋាន អគារសាលាយុត្តិធម៌ ស្ថិតនៅដីឡូត៍លេខ B តំបន់អភិវឌ្ឍន៍ OCIC ផ្លូវលោកតាក្របាមក ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

-សំណុំរឿងរដ្ឋប្បវេណីមិនមែនជា
បណ្តឹងលេខ
ចុះថ្ងៃទី ខែ ឆ្នាំ
ដីកាសម្រេច
លេខ.
ចុះថ្ងៃទី ខែ ឆ្នាំ

## ដីកាសម្រេច
## រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

យើង **តាំង ស៊ុនឡាយ** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ មាត្រា៣ និងមាត្រាពាក់ព័ន្ធនិងច្បាប់ស្តីពីនីតិវិធី នៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០។

-បានឃើញ មាត្រា ៩៧៩ និងមាត្រាពាក់ព័ន្ធ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹងលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមាន៖

-ភាគីអ្នកដាក់ពាក្យសុំ ឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ កាន់ ចុះថ្ងៃទី ខែ ឆ្នាំ អាសយដ្ឋានស្ថិតនៅផ្ទះលេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

អ្នកតំណាងដោយអាណត្តិ លោក អត្តលេខ ជាមេធាវី មានការិយាល័យ ផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

-ភាគីម្ខាងទៀត ឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាប័ណ្ណសញ្ជាតិខ្មែរ លេខ អាសយដ្ឋានស្ថិតនៅផ្ទះលេខ ផ្លូវលំ ភូមិ សង្កាត់ រាជធានីភ្នំពេញ។

### អង្គហេតុ និងចំណុចវិវាទ

**១-ខ្លឹមសារនៃដីកាសម្រេចដែលភាគីអ្នកដាក់ពាក្យសុំទាមទារឱ្យតុលាការចេញ៖**

១.១.ឱ្យភាគីអ្នកដាក់ពាក្យសុំឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ និង ភាគីម្ខាងទៀតឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ លែងលះតាមការព្រមព្រៀង។

១.២.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីអ្នកដាក់ពាក្យសុំ។

**២-ដំណើររឿងក្តី**

កាលពីអំឡុងឆ្នាំ ភាគីអ្នកដាក់ពាក្យសុំឈ្មោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយ ភាគីម្ខាងទៀតឈ្មោះ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី ខែ ឆ្នាំ

នៅមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ ។ នៅក្នុងចំណងអាពាហ៍ពិពាហ៍ភាគីទាំងពីរពុំមានកូន ទ្រព្យសម្បត្តិរួម និងបំណុលឡើយ។ ដោយការរស់នៅជាមួយគ្នាកន្លងមកមិនចុះសម្រុងនឹងគ្នា រហូតដល់គូភាគីអស់មនោសញ្ចេតនាជាប្ដីប្រពន្ធតទៅទៀត ទើបភាគីទាំងពីរដាក់ពាក្យសុំលែងលះតាមការព្រមព្រៀងមកតុលាការ។

**៣-អង្គហេតុដែលអះអាងដោយភាគីអ្នកដាក់ពាក្យសុំ**

ភាគីអ្នកដាក់ពាក្យសុំឈ្មោះ បានអះអាងថា ខ្លួនស្នើរសុំឱ្យតុលាការចេញដីកាសម្រេច៖

-លែងលះតាមការព្រមព្រៀងរវាងអ្នកដាក់ពាក្យសុំឈ្មោះ និងភាគីម្ខាងទៀតឈ្មោះ ។

-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីអ្នកដាក់ពាក្យសុំ។

ចំពោះអង្គហេតុគឺ ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ កាលពីឆ្នាំ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី ខែ ឆ្នាំ ត្រឹមត្រូវតាមច្បាប់។ ក្នុងចំណងអាពាហ៍ពិពាហ៍រហូតមកដល់សព្វថ្ងៃពុំមានកូន ទ្រព្យសម្បត្តិរួម និងបំណុលរួមនោះទេ។ មូលហេតុនៃការលែងលះ គឺដោយហេតុថាខ្លួន និងភាគីម្ខាងទៀតរស់នៅមិនចុះសម្រុងនឹងគ្នា រហូតដល់បណ្ដាលឱ្យអស់មនោសញ្ចេតនាជាប្ដីប្រពន្ធតទៅទៀត ដែលធ្វើឱ្យចំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់មិនអាចធ្វើបដិទានវិញបាន។ ចំពោះកិច្ចព្រមព្រៀងលែងលះចុះថ្ងៃទី ខែ ឆ្នាំ គឺកើតចេញពីឆន្ទៈពិតប្រាកដរបស់ខ្លួន មិនមានការបង្ខិតបង្ខំឡើយ ហើយស្នាមម្រាមដៃលើកិច្ចព្រមព្រៀងគឺពិតជាស្នាមម្រាមដៃរបស់ខ្លួនប្រាកដមែន ដូច្នេះខ្លួនសុំឱ្យតុលាការសម្រេចតាមពាក្យសុំរបស់ខ្លួន។

**៤-អង្គហេតុដែលអះអាងដោយភាគីម្ខាងទៀត**

ភាគីម្ខាងទៀតឈ្មោះ បានអះអាងថាខ្លួនឯកភាពលែងលះជាមួយភាគីអ្នកដាក់ពាក្យសុំឈ្មោះ ។ ចំពោះអង្គហេតុ និងមូលហេតុ ដែលភាគីអ្នកដាក់ពាក្យសុំបានលើកឡើងគឺពិតជាត្រឹមត្រូវខ្លួនមិនមានការជំទាស់ឡើយ ចំណែកកិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី ខែ ឆ្នាំ គឺកើតចេញពីឆន្ទៈពិតប្រាកដរបស់ខ្លួនមិនមានការបង្ខិតបង្ខំឡើយ ហើយស្នាមម្រាមដៃលើកិច្ចព្រមព្រៀងគឺ ពិតជាស្នាមម្រាមដៃរបស់ខ្លួនប្រាកដមែន ដូច្នេះខ្លួនសុំឱ្យតុលាការសម្រេចតាមច្បាប់។

## ការពិនិត្យភស្តុតាង

**១-ភស្តុតាងជាឯកសាររបស់ភាគីអ្នកដាក់ពាក្យសុំ**

-កិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី ខែ ឆ្នាំ រវាងឈ្មោះ និងឈ្មោះ ។

-សំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី ខែ ឆ្នាំ ក្នុងសៀវភៅអាពាហ៍ពិពាហ៍ លេខ ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

- លេខ របស់ឈ្មោះ ។

**២-ភស្តុតាងជាឯកសាររបស់ភាគីម្ខាងទៀត**

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី របស់ឈ្មោះ ។

## សំអាងហេតុ

១-តាមសេចក្ដីថ្លែងការណ៍របស់ភាគីអ្នកដាក់ពាក្យសុំឈ្មោះ និងភាគីម្ខាងទៀតឈ្មោះ នាពេលសាកសួរ ព្រមទាំងសំបុត្រអាពាហ៍ពិពាហ៍ លេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់មន្ត្រី

គំរូលេខ ០១ សហវ/ចមព

260-1- 00203712

MEF20882604121

ក្រសួងយុត្តិធម៌

# បង្កាន់ដៃបង់ប្រាក់

(ប្រគល់ជូនអ្នកបង់ប្រាក់)

អង្គភាព.......................................

ទទួលពី ........................................................ អង្គភាព..........................................

ចំនួនទឹកប្រាក់ជាលេខ .........................................................................

ជាអក្សរ .........................................................................

អត្ថន័យចំណូល.......................................................... មាតិកាថវិកា ......................

ថ្ងៃទី. ខែ. ឆ្នាំ.

អ្នកប្រមូលចំណូល

...ISTRY OF ECONOMY AND FINANCE

បង្កាន់ដៃនេះត្រូវបានបោះពុម្ព និងគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្របតាមអនុក្រឹត្យលេខ ៨២អនក្រ. ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥

# ឧបសម្ព័ន្ធទី៣ ៖

# ទម្រង់លិខិតរដ្ឋបាលពាក់ព័ន្ធនឹងការលែងលះដោយគ្មានការព្រមព្រៀង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
ចូល ថ្ងៃទី ខែ ឆ្នាំ

## ពាក្យបណ្តឹងលែងលះ

**ដើមចោទ៖** ឈ្មោះ ភេទ ជនជាតិខ្មែរ កើតថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី ខែ ឆ្នាំ មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ទូរស័ព្ទលេខ៖ ។

**ចុងចម្លើយ៖** ឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី ខែ ឆ្នាំ មានអាសយដ្ឋានស្ថិតនៅ ភូមិ ឃុំ ស្រុក ខេត្ត ទូរស័ព្ទលេខ ។

សាលាដំបូងរាជធានីភ្នំពេញ

## សូមគោរពជូន
## ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

## ១. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖

១. ដើមចោទឈ្មោះ លែងលះពីចុងចម្លើយឈ្មោះ ។

២. កំណត់យកដើមចោទឈ្មោះ ដែលជាឪពុក ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ ភេទ អាយុ ឆ្នាំ កើតថ្ងៃទី ខែ ឆ្នាំ មានសំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី ខែ ឆ្នាំ ។

៣. បែងចែកទ្រព្យសម្បត្តិរួម ដូចមានរៀបរាប់ខាងក្រោមជា ០២ (ពីរ) ចំណែកស្មើៗគ្នា រវាងភាគីដើមចោទ និងភាគីចុងចម្លើយ៖

- រថយន្តម៉ាក TOYOTA HILUX ពណ៌ស ផលិតឆ្នាំ សម្គាល់ដោយផ្លាកលេខ ភ្នំពេញ ចុះថ្ងៃទី ខែ ឆ្នាំ ដែលមានឈ្មោះ ជាកម្មករលើប័ណ្ណសម្គាល់រថយន្ត។
- អចលនទ្រព្យ៖ ផ្ទះ និង ដី ទំហំ x ម$^2$ ( គុណនឹង ) ម៉ែត្រការ៉េ, លេខក្បាលដី សម្គាល់ដោយគំនូសបង្ហាញទីតាំងដីសាងសង់លំនៅឋាន ចុះថ្ងៃទី ខែ ឆ្នាំ មានទីតាំងស្ថិតនៅផ្លូវជាតិលេខ ភូមិ ឃុំ ស្រុក ខេត្ត ។

៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

## ២. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារ

កាលពីថ្ងៃទី ខែ ឆ្នាំ ខ្ញុំបាទបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ និង បានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់។ នៅក្នុងចំណងអាពាហ៍ពិពាហ៍ ខ្ញុំបាទ និង ចុងចម្លើយមានកូនមួយនាក់ឈ្មោះ

**ភេទ** អាយុ ឆ្នាំ កើតថ្ងៃទី ខែ ឆ្នាំ មានសំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី ខែ ឆ្នាំ និង មានទ្រព្យសម្បត្តិរួមដូចខាងក្រោម៖

- រថយន្តម៉ាក TOYOTA HILUX ពណ៌ស ផលិតឆ្នាំ សម្គាល់ដោយផ្លាកលេខ ភ្នំពេញ ចុះថ្ងៃទី ខែ ឆ្នាំ ដែលមានឈ្មោះខ្ញុំបាទ ជាកម្មករលើប័ណ្ណសម្គាល់រថយន្ត។
- អចលនទ្រព្យ៖ ផ្ទះ និង ដី ទំហំ x ម២ ( គុណនឹង ) ម៉ែត្រការ៉េ, លេខក្បាលដី សម្គាល់ដោយគំនូសបង្ហាញទីតាំងដីសាងសង់លំនៅឋាន ចុះថ្ងៃទី ខែ ឆ្នាំ មានទីតាំងស្ថិតនៅផ្លូវជាតិលេខ ភូមិ ឃុំ ស្រុក ខេត្ត (អចលនទ្រព្យនេះកំពុងដំណើរការនីតិវិធីចុះបញ្ជីដីធ្លី ដែលអាជ្ញាធរបានចុះទៅវាស់វែង កំណត់ព្រំរួចរាល់ហើយ និងពុំមានជម្លោះជាមួយបុគ្គលណាម្នាក់ឡើយ)។

ក្រោយពេលរៀបអាពាហ៍ពិពាហ៍ មួយរយៈពេលចុងក្រោយនេះ យើងខ្ញុំទាំងពីរនាក់រស់នៅពុំចុះសំរុងនឹងគ្នា និង មិនអាចបន្តរស់នៅជាមួយគ្នាបាន រហូតឈានដល់ការបែកលំនៅឋានពីគ្នាតាំងពីថ្ងៃទី ខែ ឆ្នាំ មកម្ល៉េះ ដែលបច្ចុប្បន្ននេះ ខ្ញុំបាទបានមករស់នៅផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។ យើងខ្ញុំទាំងពីរនាក់អស់មនោសញ្ចេតនាជាប្តីប្រពន្ធនឹងគ្នា តទៅទៀតហើយ ដែលធ្វើឱ្យទំនាក់ទំនងអាពាហ៍ពិពាហ៍នេះត្រូវបែកបាក់ទាំងស្រុង ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានឡើយ។ បន្ថែមពីនេះ ខ្ញុំបាទសុំសិទ្ធិធ្វើជាអ្នកមានអំណាចមេបាលើកូនប្រុសឈ្មោះ ខាងលើ ដោយសារតែខ្ញុំបាទមានប្រាក់ចំណូលជាក់លាក់គ្រាប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន និង អាចឱ្យកូនចូលរៀននៅសាលាល្អបាន។ ជាពិសេស ខ្ញុំបាទមានពេលវេលាគ្រប់គ្រាន់ក្នុងការមើលថែរក្សាកូនឱ្យបានជិតដល់ ដើម្បីឱ្យកូនរស់នៅប្រកបដោយភាពកក់ក្តៅ និង មានអនាគតល្អ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាចេញសាលក្រមលែងលះតាមការទាមទារខាងលើដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ៕

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ

**ស្នាមមេដៃស្តាំ**



**បានឃើញ**

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ

**មេធាវី**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី

**ជូនភ្ជាប់មកជាមួយនូវ៖**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ</u>

ខ្ញុំបាទឈ្មោះ ជនជាតិខ្មែរ កើតថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី ខែ ឆ្នាំ មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ទូរស័ព្ទលេខ៖ (**អាណត្តិទាយក**)។

## <u>សូមប្រគល់សិទ្ធិជូន</u>

លោកមេធាវី អត្តលេខ ជាមេធាវី នៃក្រុមមេធាវី ដែលមានការិយាល័យនៅផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើជាអ្នកតំណាងដោយអាណត្តិរបស់ខ្ញុំបាទ នៅក្នុងរឿងក្តីលែងលះ។ តាមរយៈលិខិតប្រគល់សិទ្ធិនេះ លោកមេធាវី មានសិទ្ធិបំពេញរាល់កិច្ចការដូចខាងក្រោម៖

- មានសិទ្ធិអំណាចពេញលេញនៅក្នុងការធ្វើសកម្មភាពតំណាងឱ្យខ្ញុំបាទ។
- ដាក់ពាក្យបណ្តឹង ដាក់ពាក្យសុំ ដកពាក្យបណ្តឹង ដកពាក្យសុំ ផ្សះផ្សា សម្រុះសម្រួល បោះបង់ ឬ ទទួលស្គាល់ការទាមទារ ឬ ដកខ្លួនចេញពីបណ្តឹងដែលខ្លួនចូលរួមអន្តរាគមន៍ ឬ ទទួលបណ្តឹងដើម្បីផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទ។
- ការតែងតាំងអនុតំណាង។
- ការប្តឹងតវ៉ា/ការប្តឹងឧទ្ធរណ៍/ការប្តឹងជំទាស់/ការប្តឹងសាទុក្ខ/ការប្តឹងសើរើ។

<u>**បញ្ជាក់៖**</u> រាល់សោហ៊ុយចំណាយលើការអនុវត្តភារកិច្ចនេះ និង បង់ពន្ធផ្សេងៗនៅក្នុងបណ្តឹង ឬ ពាក្យសុំនេះ ជាបន្ទុករបស់ខ្ញុំបាទ។ ក្នុងករណីមិនបានគោរពតាមកាតព្វកិច្ចនេះ ខ្ញុំបាទសុខចិត្តទទួលខុសត្រូវនូវរាល់ការបាត់បង់ផលប្រយោជន៍នានាដោយខ្លួនឯងផ្ទាល់។

លិខិតប្រគល់សិទ្ធិនេះ មានអានុភាពចាប់ពីថ្ងៃផ្តិតស្នាមមេដៃនេះតទៅ៕

ថ្ងៃទី ខែ ឆ្នាំ

**ស្នាមមេដៃស្តាំ**

បានឃើញ និងយល់ព្រម
ធ្វើជាមេធាវីតំណាងដោយអាណត្តិឱ្យ
លោក ណុប ណូរ៉ា តាមនីតិវិធីច្បាប់។
ថ្ងៃទី ខែ ឆ្នាំ

**មេធាវី**

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

INTERNATIONAL

**ក្រុមហ៊ុនមេធាវី ជីជី អន្តរជាតិ**

GG International Law Firm

លេខ: ជ.ជ.អ

ថ្ងៃអង្គារ ៥ រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៣

# ពាក្យសុំតំណាងដោយអាណត្តិ

យើងខ្ញុំមេធាវី , អត្តលេខ: និងលោកមេធាវី អត្តលេខ: ជាសមាជិកនៃ **ក្រុមហ៊ុនមេធាវី ជីជី អន្តរជាតិ** ដែលមានអាសយដ្ឋានស្ថិតនៅអាគារលេខ: ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ។

ទូរស័ព្ទទំនាក់ទំនងលេខ៖ /

**សូមគោរពចូលមក**

**ឯកឧត្តមប្រធាន សាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ**៖ ស្តីពីការសុំតំណាងដោយអាណត្តិក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង** ៖ -ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

-ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា

-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ឈ្មោះ ចុះថ្ងៃទី ខែ ឆ្នាំ ។

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ ឈ្មោះ បានប្រគល់សិទ្ធិឲ្យយើងខ្ញុំធ្វើជាមេធាវីតំណាងដោយអាណត្តិឲ្យរូបគាត់ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីដូចដែលមានចែងក្នុងកម្មវត្ថុខាងលើ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលស្គាល់យើងខ្ញុំ ជាមេធាវីតំណាងដោយអាណត្តិនៅក្នុងសំណុំរឿងរដ្ឋប្បវេណីខាងលើទៅតាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

មេធាវី មេធាវី

ATTORNEY AT LAW

KINGDOM OF CAMBODIA

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

GG INTERNATIONAL

ក្រុមហ៊ុនមេធាវី ជីជី អន្តរជាតិ

GG International Law Firm

លេខ: ១៨៣៥/២៣ ជ.ជ.អ

សាលាដំបូងរាជធានី... ចូល លេខ... ថ្ងៃទី... ខែ... ឆ្នាំ... ម៉ោង...

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៣

**ពាក្យសុំពិនិត្យ និងថតចម្លងសំណុំរឿង**

យើងខ្ញុំមេធាវី អត្តលេខ: និងលោកមេធាវី អត្តលេខ:

ជាសមាជិកនៃ **ក្រុមហ៊ុនមេធាវី ជីជី អន្តរជាតិ** ដែលមានអាសយដ្ឋានស្ថិតនៅអាគារលេខ: ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ។

ទូរស័ព្ទទំនាក់ទំនងលេខ:

ជូនទៅក្រុមបន្ទប់ ... ពិនិត្យ និងចាត់ការ

**សូមគោរពចូលមក**

**ឯកឧត្តមប្រធាន សាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ**៖ ស្តីពីការសុំតំណាងដោយអាណត្តិក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង**៖ -មាត្រា២៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ឈ្មោះ ចុះថ្ងៃទី ខែ ឆ្នាំ២០២៣។

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ ឈ្មោះ បានប្រគល់សិទ្ធិឲ្យយើងខ្ញុំធ្វើជាមេធាវីតំណាងដោយអាណត្តិឲ្យរូបគាត់ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីដូចដែលមានចែងក្នុងកម្មវត្ថុខាងលើ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាឲ្យយើងខ្ញុំបានពិនិត្យ និងថតចម្លងសំណុំរឿង រដ្ឋប្បវេណីខាងលើទៅតាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ហត្ថលេខា និងត្រា

មេធាវី មេធាវី

AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ:

# <u>ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្ដី</u>
# <u>តុលាការក្រៅពីពន្ធ</u>

យើង **ឃិច ឈាណាទី** ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ មាត្រា ៦២ និងមាត្រា ៨២** នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

**-បានឃើញ** សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

**<u>ដើមចោទ</u>**៖ ឈ្មោះ ភេទ កើតឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**<u>អ្នកតំណាងដោយអាណត្តិ</u>**៖ លោកមេធាវី អត្តលេខ មានការិយាល័យនៅផ្ទះលេខ ផ្លូវ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**<u>ចុងចម្លើយ</u>**៖ ឈ្មោះ ភេទ កើតឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិ ឃុំ ស្រុក ខេត្ត ។

**<u>ខ្លឹមសារនៃការទាមទាររបស់ដើមចោទ</u>**៖ សុំសាលក្រមលែងលះ។

## <u>សំអាងហេតុ</u>

ដើមចោទឈ្មោះ មិនទាន់បានបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធសម្រាប់បញ្ជូនឯកសារនៅឡើយ ដែលជាហេតុធ្វើឲ្យតុលាការមិនអាចចាត់ការសំណុំរឿងនេះតាមនីតិវិធីបាន។

## <u>ហេតុដូច្នេះសម្រេច</u>

១-បង្គាប់ឱ្យឈ្មោះ ភេទ ជនជាតិខ្មែរ បង់ប្រាក់សម្រាប់បញ្ជូនឯកសារ និងដីកាផ្សេងៗ ចំនួន **១០០.០០០** (ដប់ម៉ឺន) រៀល នៅសាលាដំបូងរាជធានីភ្នំពេញ (**ជាន់ទី បន្ទប់** “ ”) ក្នុង**អំឡុងពេល ១៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានដីកាសម្រេចនេះ**។

២-ក្នុងករណីដើមចោទមិនបង់ប្រាក់ប្រដាប់ក្ដីទៅតាមការកំណត់នៅក្នុងដីកាសម្រេចនេះទេ តុលាការនឹងលើកចោលពាក្យបណ្ដឹងនេះដោយដីកាសម្រេច។

ថ្ងៃ ខែ ឆ្នាំ ព.ស.

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ

**ចៅក្រម**

ឃិច ឈាណាទី

បានទទួលថ្ងៃទី.............................

ស្នាមមេដៃស្ដាំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណីលេខៈ
ចុះថ្ងៃទី ខែ ឆ្នាំ

# លិខិតអញ្ជើញមេធាវី

យើង **ឃិច ឈាណាទី** ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**អញ្ជើញ៖** លោកមេធាវី អត្តលេខ **ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ**។

**ការិយាល័យ៖** ផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**លេខទូរស័ព្ទ៖** ។

ឱ្យចូលមកកាន់សាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី ខែ ឆ្នាំ វេលាម៉ោង **និង នាទី** **(បន្ទប់ " " ជាន់ទី )**។

**ដើម្បីចូលរួម៖** នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

**ពីដំណើររឿង៖** សុំសាលក្រមលែងលះ។

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើមកជាមួយផងប្រសិនបើមាន ។

ថ្ងៃ ខែ ឆ្នាំ ព.ស.

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**ចៅក្រម**

ឃិច ឈាណាទី

---

ក្រឡាបញ្ជីទទួលបន្ទុកសំណុំរឿងលោក **ហ៊ិន សំភ្ជដារ**
ទូរស័ព្ទទំនាក់ទំនងលេខ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងរដ្ឋប្បវេណីលេខ:
ចុះថ្ងៃទី ខែ ឆ្នាំ

# **ដីកាកោះ**

យើង **ឃិច ឈាណាទី** ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**អញ្ជើញ៖** ឈ្មោះ ភេទ កើតឆ្នាំ សញ្ជាតិខ្មែរ **ជាដើមចោទ**។

**ទីលំនៅបច្ចុប្បន្ន៖** ផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**លេខទូរស័ព្ទ៖** ។

ឱ្យចូលមកកាន់សាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី ខែ ឆ្នាំ វេលាម៉ោង **និង នាទី (បន្ទប់ " " ជាន់ទី )** ។

**ដើម្បីចូលរួម៖** នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

**ពីដំណើររឿង៖** សុំសាលក្រមលែងលះ។

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើមកជាមួយផងប្រសិនបើមាន។

ថ្ងៃ ខែ ឆ្នាំ ព.ស.

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**ចៅក្រម**

**ឃិច ឈាណាទី**

ក្រឡាបញ្ជីទទួលបន្ទុកសំណុំរឿងលោក **ហ៊ីន ស័ក្តដា**
ទូរស័ព្ទទំនាក់ទំនងលេខ

15/2

សាលាដំបូងខេត្តកណ្ដាល
ចូល លេខ: 390
ថ្ងៃទី 27 ខែ 02 ឆ្នាំ
ម៉ោង 9 និង 50 នាទី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## សេចក្ដីថ្លែងការណ៍

ខ្ញុំបាទឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ជនជាតិខ្មែរ សញ្ញាតិខ្មែរ មានទីលំនៅ បច្ចុប្បន្ន ភូមិកជានុកូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

**សូមគោរពជូន**

**លោក គឹម វត្ថុណារិន ចៅក្រមសាលាដំបូងខេត្តកណ្ដាល**

**កម្មវត្ថុ** ៖ សំណើសុំផ្លាស់ប្ដូរសេចក្ដីថ្លែងការណ៍ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ របស់សាលាដំបូងខេត្តកណ្ដាល។

**យោង** ៖ -ដីកាកោះ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្ដាល។
-សេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ ។
-ពាក្យបណ្ដឹង ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ ។
-សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ របស់សាលាដំបូងខេត្តកណ្ដាល។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកចៅក្រម** មេត្តាជ្រាបថា៖ ខ្ញុំបាទឈ្មោះ និងឈ្មោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាប្ដីប្រពន្ធតាំងពីឆ្នាំ ១៩៩៣។ បន្ទាប់ពីខ្ញុំបាទ និងប្រពន្ធឈ្មោះ ចាប់ដៃគ្នាជាប្ដីប្រពន្ធមកគឺពួកយើងខ្ញុំមានកូនប្រុសចំនួន ០២នាក់ គឺឈ្មោះ អាយុ ឆ្នាំ និងឈ្មោះ អាយុ ១២ឆ្នាំ និងមានទ្រព្យសម្បត្តិរួមមួយចំនួនទៀត។ __ប៉ុន្តែដោយហេតុថា__ ការរួមរស់ជាមួយគ្នាមិនចុះសម្រុងគ្នា ណាមួយខ្ញុំបាទអស់មនោសញ្ចេតនាជាប្ដីប្រពន្ធតទៅទៀតហើយ ហេតុនេះខ្ញុំបាទឈ្មោះ សុខចិត្តដាក់ពាក្យបណ្ដឹងសុំលែងលះទៅសាលាដំបូងខេត្តកណ្ដាល។

តាមខ្លឹមសារនៃពាក្យបណ្ដឹង ទ្រព្យសម្បត្តិរួមទាំងអស់ដូចដែលបានរៀបរាប់បានប្រគល់ឱ្យម្ដាយ និងកូនពីរនាក់ តែតាមសេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ ទ្រព្យរួមទាំងនោះខ្ញុំបានសម្រេចប្រគល់ឱ្យម្ដាយ និងកូនស្រីឈ្មោះ តែពីរនាក់ ម្ដាយនិងកូនតែប៉ុណ្ណោះ ចំណែកឯកូនឈ្មោះ ជាបន្ទុករបស់ខ្ញុំបាទ មិនឱ្យទាមទារទ្រព្យសម្បត្តិទាំងនោះទេ។ ក្រោយពីតុលាការខេត្តកណ្ដាលមានចំណាត់ការលើរឿងក្ដីខ្ញុំបាទ និងក្រោយពីខ្ញុំបាទធ្វើសេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩ កន្លងមកឃើញថា ភាគីឈ្មោះ ចេះតែបង្កបញ្ហា ដែលធ្វើឱ្យរាំងស្ទះនីតិវិធីរបស់តុលាការ ផ្ទុយពីអ្វីដែលខ្ញុំបាទបានសន្យាខាងលើ ទើបខ្ញុំបាទសម្រេចចិត្តកែប្រែសេចក្ដីថ្លែង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តកណ្ដាល
លេខៈ 486
ថ្ងៃទី 14 ខែ 3 ឆ្នាំ
ម៉ោង 8 និង 10

**ពាក្យសុំបញ្ចូលភស្តុតាង**

នាងខ្ញុំឈ្មោះ ជាចុងចម្លើយនៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខៈ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ របស់សាលាដំបូងខេត្តកណ្ដាល។

**សូមគោរពជូនមក**

**លោក គីម រ័ត្នណារិន អនុប្រធានសាលាដំបូងខេត្តកណ្ដាល**

*សូមទានជ្រាប។*

**កម្មវត្ថុៈ** ស្នើសុំបញ្ចូលភស្តុតាងក្នុងសំណុំរឿងរដ្ឋប្បវេណីលេខៈ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ របស់សាលាខេត្តកណ្ដាល។

**យោងៈ** សំណុំរឿងរដ្ឋប្បវេណីលេខៈ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ របស់សាលាខេត្តកណ្ដាល។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមជម្រាបជូន **លោកចៅក្រម** មេត្តាជ្រាបថាៈ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ តុលាការបានបញ្ចប់នីតិវិធីត្រៀមទាញហេតុផលលើកទី២ ចំពោះសំណុំរឿងរដ្ឋប្បវេណីលេខៈ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកណ្ដាល ហើយតុលាការបានទុកពេលវេលាឲ្យចំនួន ០២សប្ដាហ៍ ដើម្បីភាគីដាក់បញ្ចូលភស្តុតាង។ ដូចនេះ ដើម្បី **លោកចៅក្រម** មានមូលដ្ឋានកាន់តែរឹងមាំក្នុងការពិចារណា និងសម្រេចសេចក្ដីក្នុងសំណុំរឿងខាងលើ នាងខ្ញុំសូមអនុញ្ញាតដាក់បញ្ចូលភស្តុតាងដូចខាងក្រោម៖

១. សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ លេខៈ ០៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៤ ចេញដោយមេឃុំរកាកោង២។

២. សំបុត្របញ្ជាក់កំណើត លេខៈ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៩ របស់កូនប្រុសច្បងឈ្មោះ ចេញដោយមេឃុំរកាកោង២។

៣. សំបុត្របញ្ជាក់កំណើត លេខៈ ៧៧ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៩ របស់កូនស្រីឈ្មោះ ចេញដោយមេឃុំរកាកោង២។

៤. សៀវភៅស្នាក់នៅ លេខៈ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០។

៥. ដី មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខៈ / រកII ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៨ បញ្ជាក់ដោយមេឃុំរកាកោង២។

៦. ដី មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខៈ / រកII ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨ បញ្ជាក់ដោយមេឃុំរកាកោង២។

៧. ដី មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខៈ មព ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ បញ្ជាក់ដោយអភិបាលរងស្រុកមុខកំពូល។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តបន្ទាយមានជ័យ
លេខ........
ថ្ងៃ....ខែ.....ឆ្នាំ......
ម៉ោង......

**<u>ពាក្យសុំឲ្យកោះហៅសាក្សី</u>**

- ខ្ញុំបាទឈ្មោះ អាយុ២៨ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជាចុងចំលើយ ( )

**សូមគោរពជូន**

**លោកប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ**

<u>កម្មវត្ថុ</u> សំណើសុំកោះហៅសាក្សីឲ្យចូលមកឆ្លើយបំភ្លឺក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ ម៉ោង៨ព្រឹក។

<u>យោង</u> .សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី០៦.១១.l របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

តាមកម្មវត្ថុ និង យោងខាងលើនេះ ខ្ញុំបាទ សូមគោរពជំរាបជូន **លោកប្រធាន**មេត្តាជ្រាបថា ៖ ខ្ញុំបាទត្រូវបានប្រពន្ធឈ្មោះ ប្តឹងសុំលែងលះពីខ្ញុំបាទ។ ព័ន្ធរឿងក្តីនេះ មានការវិវាទក្នុងរឿងទ្រព្យសម្បត្តិ ខ្ញុំសូមបញ្ជាក់ថា ចំពោះទ្រព្យសម្បត្តិមានដី និងផ្ទះនៅលើដី និងម៉ូតូមួយគ្រឿងដែលប្រពន្ធទាមទារថាជាទ្រព្យរួមនោះ គឺមិនត្រឹមត្រូវទេ។ ដី និងផ្ទះនៅលើដី និងម៉ូតូមួយគ្រឿងជាទ្រព្យសម្បត្តិដោយឡែករបស់ខ្ញុំបាទ គឺ៖

១.ដី និងផ្ទះនៅលើដី ជារបស់ឪពុកម្តាយខ្ញុំបាទ ចែកឲ្យក្រោយពេលរៀបការ។

២.ម៉ូតូ១គ្រឿង គឺជាម៉ូតូដែលប្អូនខ្ញុំបាទឈ្មោះ ឲ្យខ្ញុំបាទខ្ចីជិះទៅធ្វើការ មានសាក្សីដឹងលឺ ៖

.ឈ្មោះ ភេទស្រី អាយុ ឆ្នាំ នៅភូមិ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជាម្តាយខ្ញុំបាទ។

.ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ នៅភូមិសូភី សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

ខ្ញុំបាទមានសំណូមពរ សុំឲ្យតុលាការកោះអញ្ជើញសាក្សី ដើម្បីបំភ្លឺការពិតជូនតុលាការពេលសវនាការ។

អាស្រ័យដូចបានគោរពជូនខាងលើនេះសូម **ប្រធាន** មេត្តាសំរេច តាមសំណូមពរ ខ្ញុំបាទ ដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ធ្វើនៅថ្ងៃទី ១៥ ខែវិច្ឆកា ឆ្នាំ
ស្នាមមេដៃស្តាំ

បញ្ជូនទៅ.....................
ដើម្បីចាត់ការតាមនីតិវិធីច្បាប់។
បន្ទាយមានជ័យ, ថ្ងៃទី..15...ខែ..11.....ឆ្នាំ
ប្រធានសាលាដំបូង

26/19

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

# លិខិតអញ្ជើញ

យើង គឹម រ័ត្នណារិន ចៅក្រមសាលាដំបូងខេត្តកណ្ដាល

អញ្ជើញ ៖ មេធាវី អត្តលេខ នៃក្រុមមេធាវី មានអាសយដ្ឋាននៅ ផ្ទះលេខ ១០-B2 E₀E₁ ផ្លូវលេខ ២១១ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ជាមេធាវីតំណាងអាណត្តិឱ្យ [illegible]ឈ្មោះ ។

| | |
|---|---|
| សញ្ញាណរឿងក្តី និង ភាគី | សំណុំរឿងរដ្ឋប្បវេណីលេខ ១០៧៧ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦<br>ការទាមទារដោយដើមចោទ ៖ ប្តឹងសុំលែងលះប្រពន្ធ<br>+ ដើមចោទឈ្មោះ អាទ ប្រុស<br>+ ចុងចម្លើយឈ្មោះ អេទ ស្រី |
| កាលបរិច្ឆេទ និងទីកន្លែងដែលបង្ហាញខ្លួន | ថ្ងៃទី ២២ ខែ [illegible] ឆ្នាំ ២០១៩ វេលាម៉ោង ០៧ និង ០០ នាទី ~~ព្រឹក~~/រសៀល<br>☑សាលាដំបូងខេត្តកណ្ដាល ☐បន្ទប់សវនាការទី....... ☑បន្ទប់ "ឆ" |
| ប្រភេទនៃកាលបរិច្ឆេទ<br>( សំគាល់ដោយសញ្ញា ☑ ) | ☐នីតិវិធីត្រៀម ☑ទាញហេតុផលផ្ទាល់មាត់ ☐ ប្រកាសសាលក្រម<br>.................................................................................................... |
| ប្រភេទនៃឯកសារភ្ជាប់មកជាមួយ<br>( សំគាល់ដោយសញ្ញា ☑ ) | ឯកសារស្តីពីចំណុចនៃការសាកសួរ<br>ឯកសារស្តីពីចំណុចនៃការធ្វើកោសល្យវិច្ឆ័យ |
| ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបង្ហាញ ខ្លួនដោយគ្មានមូល ហេតុ ត្រឹមត្រូវ | -បើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសំរាប់ ការទាញហេតុផលទេតុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំង មុខ តាមមាត្រា២០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។<br>-បើចុងចំលើយមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀម សំរាប់ការទាញហេតុផលទេ តុលាការត្រូវបញ្ឈប់នីតិវិធីត្រៀមសំរាប់ការទាញ ហេតុផលដោយភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី១ នៃការទាញ ហេតុ ផលដោយផ្ទាល់មាត់ តាមមាត្រា ២០១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ |

សូមបង្ហាញខ្លួនដូច ដែលបានចែងខាងលើនេះ ។

ថ្ងៃពុធ ១៤រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

កណ្ដាល, ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩

ចៅក្រម

គឹម រ័ត្នណារិន

យើង........................................ជា......................
បានប្រគល់ដីកាកោះនេះឱ្យឈ្មោះ....................................
មានទីលំនៅបច្ចុប្បន្ននៅភូមិ..........................ឃុំ...............
ស្រុក..........................ខេត្ត..........................នៅថ្ងៃទី
.................ខែ.................ឆ្នាំ..............ហើយយើងបាន
ប្រាប់ថាសាមីខ្លួន ត្រូវប្រគល់ចុងដីកាកោះនេះ ដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលមកចំពោះមុខតុលាការខេត្តកណ្ដាល។

អ្នកទទួល អ្នកប្រគល់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

------ ------

សាលាដំបូងខេត្តកណ្តាល

# ដីកាកោះ

យើង គីម រ័ត្នណារិន ចៅក្រមសាលាដំបូងខេត្តកណ្តាល

អញ្ជើញ ៖ ឈ្មោះ ភេទ ស្រី អាយុ ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ននៅ ភូមិរការកោង ឃុំរការកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល ជាចុងចម្លើយ។

| | |
|---|---|
| សញ្ញាណរឿងក្តី និង ភាគី | សំណុំរឿងរដ្ឋប្បវេណីលេខ ១០៧៧ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦<br>ការទាមទារដោយដើមចោទ ៖ ប្តឹងសុំលែងលះប្រពន្ធ<br>+ ដើមចោទឈ្មោះ . ភេទ ប្រុស<br>+ ចុងចម្លើយឈ្មោះ . ភេទ ស្រី |
| កាលបរិច្ឆេទ និងទីកន្លែងដែលបង្ហាញខ្លួន | ថ្ងៃទី ១២ ខែ [illegible] ឆ្នាំ ២០១៩ វេលាម៉ោង ០២ និង ០០.... នាទីព្រឹក/រសៀល<br>☑ សាលាដំបូងខេត្តកណ្តាល ☐ បន្ទប់សវនាការទី...... ☑ បន្ទប់ "ឆ" |
| ប្រភេទនៃកាលបរិច្ឆេទ<br>( សំគាល់ដោយសញ្ញា ☑ ) | ☐ នីតិវិធីត្រៀម ☑ ទាញហេតុផលផ្ទាល់មាត់ ☐ ប្រកាសសាលក្រម<br>........................................................................................ |
| ប្រភេទនៃឯកសារភ្ជាប់មកជាមួយ<br>( សំគាល់ដោយសញ្ញា ☑ ) | ឯកសារស្តីពីចំណុចនៃការសាកសួរ<br>ឯកសារស្តីពីចំណុចនៃការធ្វើកោសល្យវិច្ច័យ |
| ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបង្ហាញ ខ្លួនដោយគ្មានមូល ហេតុ ត្រឹមត្រូវ | -បើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសំរាប់ ការទាញហេតុផលទេតុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំង មុខ តាមមាត្រា២០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។<br>-បើចុងចំលើយមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀម សំរាប់ការទាញហេតុផលទេ តុលាការត្រូវបញ្ចប់នីតិវិធីត្រៀមសំរាប់ការទាញ ហេតុផលដោយភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី១ នៃការទាញ ហេតុ ផលដោយផ្ទាល់មាត់ តាមមាត្រា ២០១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ |

សូមបង្ហាញខ្លួនដូច ដែលបានចែងខាងលើនេះ ។

ថ្ងៃពុធ ១៤រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

[illegible] ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩

ចៅក្រម

គីម រ័ត្នណារិ

យើង...[illegible]...............ជា..[illegible]
បានប្រគល់ដីកាកោះនេះឱ្យឈ្មោះ..[illegible]........
មានទីលំនៅបច្ចុប្បន្ននៅភូមិ..[illegible]........ឃុំ..[illegible]
ស្រុក..[illegible]......ខេត្ត..[illegible]..........នៅថ្ងៃទី
....[illegible]........ខែ..[illegible]....ឆ្នាំ..2019...ហើយយើងបាន
ប្រាប់ថាសាម៉ីខ្លួន ត្រូវប្រគល់ចុងដីកាកោះនេះ ដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលទៅចំពោះមុខតុលាការខេត្តកណ្តាល។

អ្នកទទួល

អ្នកប្រគល់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**
លេខ
ចុះថ្ងៃទី ខែ ឆ្នាំ
សំណុំរឿងរដ្ឋប្បវេណីលេខ
ចុះថ្ងៃទី ខែ ឆ្នាំ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី ខែ ឆ្នាំ វេលាម៉ោង និង នាទីរសៀល នៅសាលសវនាការទី លើសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ ដោយមានសមាសភាព៖

**<u>ចៅក្រមជំនុំជម្រះ</u>**

លោក **ស សំណាង** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**<u>ក្រឡាបញ្ជី</u>**

លោក **ហ៊ីន ស័ក្កដា** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

<u>ដើមចោទ</u>៖ ឈ្មោះ ភេទ អាយុ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

<u>អ្នកតំណាងដោយអាណត្តិ</u>៖ លោកមេធាវី មានការិយាល័យនៅផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

<u>ចុងចម្លើយ</u>៖ ឈ្មោះ ភេទ អាយុ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិ ឃុំ ស្រុក ខេត្ត ។

<u>អ្នកតំណាងដោយអាណត្តិ</u>៖ លោកមេធាវី មានការិយាល័យនៅផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

## <u>អង្គហេតុ និងចំណុចវិវាទ</u>

១-<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ</u>៖

ក-សុំលែងលះពីចុងចម្លើយឈ្មោះ ។

ខ-សុំមានអំណាចមេបាលើកូនឈ្មោះ ភេទ អាយុ ឆ្នាំ កើតថ្ងៃទី ខែ ឆ្នាំ ។

គ-សុំបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នាមាន៖

គ.១-រថយន្តម៉ាក TOYOTA HILUX ពណ៌ ផលិតឆ្នាំ សម្គាល់ដោយស្លាកលេខ ចុះថ្ងៃទី ខែ ឆ្នាំ ។

គ.១-អចលនទ្រព្យ៖ ដី និងផ្ទះទំហំ x ( គុណ ) ម៉ែត្រការ៉េ, លេខក្បាលដី សម្គាល់ដោយគំនូសបង្ហាញទីតាំងដីសាងសង់លំនៅឋាន ចុះថ្ងៃទី ខែ ឆ្នាំ មានទីតាំងស្ថិតនៅផ្លូវជាតិលេខ ភូមិ ឃុំ ស្រុក ខេត្ត ។

ឃ-សុំទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី។

២-<u>ការពន្យល់ត្រួសៗអំពីរឿងក្តី៖</u>

កាលពីថ្ងៃទី ខែ ឆ្នាំ ដើមចោទឈ្មោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។ នៅក្នុងចំណងអាពាហ៍ពិពាហ៍ ដើមចោទ និងចុងចម្លើយមានកូនមួយនាក់ឈ្មោះ ភេទ អាយុ ឆ្នាំ កើតថ្ងៃទី ខែ ឆ្នាំ មានសំបុត្រកំណើតលេខ ចុះថ្ងៃទី ខែ ឆ្នាំ និងមានទ្រព្យសម្បត្តិរួមដូចជា៖ ១.រថយន្តម៉ាក TOYOTA HILUX ពណ៌ ផលិតឆ្នាំ សម្គាល់ដោយស្លាកលេខ ចុះ ថ្ងៃទី ខែ ឆ្នាំ និង ២.អចលនទ្រព្យ៖ ផ្ទះ និងដីទំហំ x ( គុណ ) ម៉ែត្រការ៉េ, លេខក្បាលដី សម្គាល់ដោយគំនូសបង្ហាញទីតាំងដីសាងសង់លំនៅឋាន ចុះថ្ងៃទី ខែ ឆ្នាំ មានទីតាំងស្ថិតនៅផ្លូវជាតិលេខ ភូមិ ឃុំ ស្រុក ខេត្ត (អចលនទ្រព្យនេះកំពុងដំណើរការនីតិវិធីចុះបញ្ជីដីធ្លី ដែលអាជ្ញាធរបានចុះទៅវាស់វែង កំណត់ព្រំរួចរាល់ហើយ និងពុំមានជម្លោះជាមួយបុគ្គលណាម្នាក់ឡើយ)។ ក្រោយពេលរៀបអាពាហ៍ពិពាហ៍ មួយរយៈចុងក្រោយនេះ ដើមចោទ និងចុងចម្លើយរស់នៅពុំចុះសម្រុងនឹងគ្នា និងមិនអាចបន្តរស់នៅជាមួយគ្នាបាន រហូតឈានដល់ការបែកលំនៅឋានពីគ្នាតាំងពីថ្ងៃទី ខែ ឆ្នាំ មកម្ល៉េះ ដែលបច្ចុប្បន្ននេះ ដើមចោទបានមករស់នៅផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។ ដើមចោទ និងចុងចម្លើយអស់មនោសញ្ចេតនាជាប្តីប្រពន្ធនឹងគ្នាតទៅទៀតហើយ ដែលធ្វើឱ្យទំនាក់ទំនងអាពាហ៍ពិពាហ៍នេះត្រូវបែកបាក់ទាំងស្រុង ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានឡើយ។ បន្ថែមពីនេះ ដើមចោទបានសុំសិទ្ធិធ្វើជាអ្នកមានអំណាចមេបាលើកូនប្រុសឈ្មោះ ខាងលើ ដោយសារដើមចោទមានប្រាក់ចំណូលជាក់លាក់គ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន និងអាចឱ្យកូនរៀននៅសាលាល្អបាន។ ជាពិសេស ដើមចោទមានពេលគ្រប់គ្រាន់ក្នុងការមើលថែរក្សាកូនឱ្យបានជិតដល់ ដើម្បីឱ្យកូនរស់នៅប្រកបដោយភាពកក់ក្តៅ និងមានអនាគតល្អ។

៣-<u>អង្គហេតុដែលអះអាងដោយដើមចោទ</u>៖

ខ្លួន និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍កាលពីឆ្នាំ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។ អំឡុងពេលរួមរស់ជាមួយគ្នាជាប្តីប្រពន្ធមានកូនម្នាក់ឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ ។ ខ្លួនទាមទារលែងលះពីចុងចម្លើយ។ ខ្លួននៅតែទាមទារការមានអំណាចមេបាលើកូនដដែល។ ដោយឡែកអចលនទ្រព្យមានផ្ទះ និងដីទំហំ x ( គុណ ) ម៉ែត្រការ៉េ បើជាទ្រព្យដោយឡែករបស់ចុងចម្លើយ ខ្លួនមិនទាមទារទេ។ ចំពោះរថយន្តម៉ាក TOYOTA HILUX ពណ៌ ផលិតឆ្នាំ សម្គាល់ដោយស្លាកលេខ ចុះថ្ងៃទី ខែ ឆ្នាំ ខ្លួនសុំបែងចែកជាពីរចំណែកស្មើគ្នា។

៤-<u>សេចក្តីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ</u>៖

អ្នកតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា៖ កូនក្តីរបស់ខ្លួន និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាកាលពីថ្ងៃទី ខែ ឆ្នាំ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ស្របទៅតាមច្បាប់ ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី ខែ ឆ្នាំ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ ។ នៅក្នុងចំណងអាពាហ៍ពិពាហ៍ ខ្លួន និងចុងចម្លើយមានកូនមួយនាក់ឈ្មោះ ភេទ អាយុ ឆ្នាំ កើតថ្ងៃទី ខែ ឆ្នាំ មានសំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី ខែ ឆ្នាំ និងមានទ្រព្យរួមដូចជា៖ ១.រថយន្តម៉ាក TOYOTA HILUX ពណ៌ ផលិតឆ្នាំ សម្គាល់ដោយស្លាកលេខ ចុះថ្ងៃទី ខែ ឆ្នាំ ដែលមានឈ្មោះកូនក្តីខ្លួនឈ្មោះ ជាកម្មសិទ្ធិករលើប័ណ្ណសម្គាល់រថយន្ត, ២.ដីសម្គាល់ដោយវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ ស្ថិតនៅភូមិ ឃុំ ស្រុក ខេត្ត ។

ចំពោះដីនេះ កូនក្តីខ្លួនបានប្រគល់ប្រាក់សុទ្ធដោយផ្ទាល់ចំនួន ( ) ដុល្លារអាមេរិក ឱ្យទៅលោក ដែលជាឪពុករបស់ចុងចម្លើយដើម្បីជាថ្នូរនឹងការធ្វើអំណោយលើដីខាងលើមកឱ្យកូនក្តីរបស់ខ្លួន និងចុងចម្លើយជាទ្រព្យរួមក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ កាលពីអំឡុងឆ្នាំ ដែលក្នុងនោះប្រាក់ចំនួន ( ) ដុល្លារអាមេរិក ជាប្រាក់ចំណងដៃអាពាហ៍ពិពាហ៍របស់កូនក្តីរបស់ខ្លួន និងចុងចម្លើយ និងប្រាក់ចំនួន ( ) ដុល្លារអាមេរិក ជាប្រាក់ផ្ទាល់ខ្លួនរបស់កូនក្តីរបស់ខ្លួន, ៣.ផ្ទះទំហំ x ម² មានជាន់ផ្ទាល់ដី ជាន់ឡៅតឿ និងជាន់ទី១ ព្រមទាំងអគារចង្ក្រានបាយដែលបានសាងសង់នៅលើទីតាំងខាងលើ អស់ទឹកប្រាក់ចំនួន ( ) ដុល្លារអាមេរិក ជាប្រាក់ដែលកូនក្តីខ្លួន និងចុងចម្លើយរកបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍, ប្រាក់សុទ្ធចំនួន ( ) ដុល្លារអាមេរិក (បានផ្ទេរតាមធនាគារទៅឱ្យចុងចម្លើយ), ៥.ប្រាក់លក់ដីចំការនៅខេត្តកោះកុងចំនួន ( ) ដុល្លារអាមេរិក (បានប្រគល់ឱ្យចុងចម្លើយដោយផ្ទាល់) និងទ្រព្យដោយឡែករបស់ដើមចោទ៖ នៅមុនពេលអាពាហ៍ពិពាហ៍ កូនក្តីរបស់ខ្លួនមានសម្ភារៈដូចជា ។ បច្ចុប្បន្ន ទ្រព្យដោយឡែកនេះបានដាក់នៅក្នុងឃ្លាំងនៃដីដែលជាទ្រព្យរួមខាងលើ។

យោងតាមអង្គហេតុខាងលើឃើញថា កូនក្តីខ្លួន និងចុងចម្លើយរស់នៅពុំចុះសំរុងនឹងគ្នា និងមិនអាចបន្តរស់នៅជាមួយគ្នាបានរហូតឈានដល់ការបែកលំនៅឋានពីគ្នាតាំងពីថ្ងៃទី ខែ ឆ្នាំ រហូតមកដល់បច្ចុប្បន្ននេះ។ ទំនាក់ទំនងអាពាហ៍ពិពាហ៍នេះត្រូវបានបែកបាក់ទាំងស្រុង និងគ្មានសង្ឃឹមថានឹងអាចត្រឡប់ទៅត្រូវគ្នាដូចដើមវិញបានឡើយ។ ករណីនេះយើងឃើញថា វាជាមូលហេតុមួយនៃការលែងលះដូចមានចែងក្នុងចំណុច ង កថាខណ្ឌទី១ នៃមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណីខាងលើ ដែលចែងថា អាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន។ សរុបមកដោយផ្អែកតាមអង្គហេតុ និងមាត្រា៩៧៨-១-ង ដើមចោទអាចប្តឹងលែងលះពីចុងចម្លើយបាន។

យោងតាមពាក្យស្នើសុំពិនិត្យភស្តុតាង ចុះថ្ងៃទី ខែ ឆ្នាំ ដែលកូនក្តីខ្លួនបានដាក់ជូនតុលាការពិនិត្យឃើញថា កូនក្តីខ្លួនជា មានការអប់រំ និងមានប្រាក់ចំណូលខ្ពស់ មានជីវភាពធូរធារ ដូចនេះកូនក្តីរបស់ខ្លួនមានលទ្ធភាពឱ្យកូនចូលសិក្សាសាលាល្អ ផ្តល់សម្ភារៈផ្សេងៗដើម្បីបំពេញតាមតម្រូវការរបស់កូន និងមានក្រុមគ្រួសារជួយមើលថែរក្សាជិតដល់គ្រប់ពេលវេលា ដែលអាចធានាបានពីសុខសុវត្ថិភាព ភាពកក់ក្តៅ និងក្លាយជាកូនល្អ ពលរដ្ឋល្អ និងមានអនាគតល្អ។ ជាពិសេសជាងនេះទៅទៀត កូនក្តីខ្លួនសូមអះអាងថា នឹងផ្តល់ពេលវេលាដ៏សប្បាយរីករាយដល់កូន ដោយនាំគាត់ទៅដើរកម្សាន្តនៅរមណីយដ្ឋាននានានាពេលចុងសប្តាហ៍ ឬពេលសម្រាកពីការសិក្សារបស់កូន ដើម្បីឱ្យកូនរស់នៅក្នុងបរិយាកាសសប្បាយរីករាយ និងមានភាពកក់ក្តៅជាទីបំផុត។ ម្យ៉ាងវិញទៀត កូនក្តីខ្លួននឹងមិនទាមទារឱ្យចុងចម្លើយផ្តល់អាហារកាតព្វកិច្ចក្នុងការចិញ្ចឹមកូនអ្វីទាំងអស់ ក្នុងករណីយល់ព្រមប្រគល់សិទ្ធិអំណាចមេបាលើកូនមកឱ្យកូនក្តីខ្លួន។ ទាំងនេះបង្ហាញឱ្យឃើញពីលទ្ធភាព និងឆន្ទៈរបស់កូនក្តីខ្លួនដែលអាចផ្តល់ផលប្រយោជន៍ដល់កូនបានសព្វគ្រប់បែបយ៉ាង ស្របតាមស្មារតីនៃមាត្រា១០៣៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីខាងលើ។ សរុបមក តុលាការអាចកំណត់យកកូនក្តីខ្លួនធ្វើជាអ្នកមានសិទ្ធិអំណាចមេបាលើកូនបាននៅក្រោយពេលលែងលះគ្នា ព្រោះកូនក្តីខ្លួនអាចផ្តល់នូវផលប្រយោជន៍ដល់កូនបានគ្រប់បែបយ៉ាង។

យោងតាមអង្គហេតុខាងលើ និងពាក្យស្នើសុំពិនិត្យភស្តុតាង ចុះថ្ងៃទី ខែ ឆ្នាំ ត្រង់ចំណុច១ (តារាងតម្លៃសាងសង់ និងរូបភាពផ្ទះវីឡាដែលបានសាងសង់) និងចំណុច២ (គម្រោងសាងសង់លំនៅស្ថាន-ផ្ទះល្វែង) និងពាក្យស្នើសុំពិនិត្យភស្តុតាងបន្ថែម ចុះថ្ងៃទី ខែ ឆ្នាំ ដែលកូនក្តីខ្លួនបានដាក់ជូនតុលាការពិនិត្យ ឃើញថានៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ កូនក្តីខ្លួន និងចុងចម្លើយមានទ្រព្យរួមដូចជា៖ ១.រថយន្តម៉ាក TOYOTA HILUX ពណ៌ ផលិតឆ្នាំ

សម្គាល់ដោយស្លាកលេខ ចុះថ្ងៃទី ខែ ឆ្នាំ ដែលមានឈ្មោះ ជាកម្មសិទ្ធិករលើប័ណ្ណសម្គាល់រថយន្ត, ២.ដីសម្គាល់ដោយវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ ស្ថិតនៅភូមិ ឃុំ ស្រុក ខេត្ត ។ ចំពោះដីនេះ កូនក្តីខ្លួនបានប្រគល់ប្រាក់ចំនួន ( ) ដុល្លារអាមេរិក ឲ្យទៅលោក ដែលជាឪពុករបស់ចុងចម្លើយដើម្បីជាថ្នូរនឹងការធ្វើអំណោយលើដីខាងលើមកឲ្យកូនក្តីខ្លួន និងចុងចម្លើយជាទ្រព្យរួមក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ កាលពីអំឡុងឆ្នាំ ដែលក្នុងនោះប្រាក់ចំនួន ( ) ដុល្លារអាមេរិក ជាប្រាក់ចំណងដៃអាពាហ៍ពិពាហ៍របស់កូនក្តីខ្ល និងចុងចម្លើយ និងប្រាក់ចំនួន ( ) ដុល្លារអាមេរិក ជាប្រាក់ផ្ទាល់ខ្លួនរបស់កូនក្តីខ្លួន។ កាលនោះ ដីនេះនៅពុំទាន់ចុះបញ្ជីប្លង់កម្មសិទ្ធិ (ប្លង់រឹង) នៅឡើយទេ ហើយចុងចម្លើយអះអាងថានឹងចុះបញ្ជីធ្វើប្លង់កម្មសិទ្ធិ (ប្លង់រឹង) មកជាទ្រព្យសម្បត្តិរួមរវាងកូនក្តីខ្លួន និងចុងចម្លើយ។ ជាក់ស្តែងកាលពីថ្ងៃទី ខែ ឆ្នាំ កូនក្តីខ្លួន និងចុងចម្លើយបានទៅខ្ចីប្រាក់ពីធនាគារ ចំនួន ( ) ដុល្លារអាមេរិក ដោយយកដីខាងលើទៅដាក់ធានាកាតព្វកិច្ចជាមួយធនាគារ (បង្កើតហ៊ីប៉ូតែក) ដែលមានបញ្ជាក់ថាជាកម្មសិទ្ធិរបស់ឈ្មោះ និងឈ្មោះ ។ នេះបង្ហាញឲ្យឃើញថា ចុងចម្លើយបានទទួលស្គាល់ថាដីនោះជាដីកម្មសិទ្ធិរួមរបស់ខ្លួនជាមួយនឹងកូនក្តីរបស់ខ្លួនរួចទៅហើយ។ ប៉ុន្តែ ក្រោយពេលដែលកូនក្តីខ្លួនមានបញ្ហា និងរស់នៅមិនចុះសម្រុងគ្នាជាមួយនឹងចុងចម្លើយ ទើបចុងចម្លើយបានទៅចុះបញ្ជីធ្វើប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) នៅរដ្ឋបាលសុរិយោដីតែឯកឯងស្ងាត់ៗ ដោយដាក់ឈ្មោះខ្លួនឯងតែម្នាក់ជាម្ចាស់កម្មសិទ្ធិ ដោយលួចលាក់ពុំឲ្យកូនក្តីខ្លួនបានដឹងឡើយ (ប្រែក្រឡាស់ពីការអះអាងរបស់ខ្លួនពីមុន ដែលសន្យាថានឹងចុះបញ្ជីធ្វើប័ណ្ណកម្មសិទ្ធិជាទ្រព្យសម្បត្តិរួម)។ ២.ផ្ទះ៖ កូនក្តីខ្លួនបានចំណាយពេលវេលា និងចំណេះជំនាញរបស់ខ្លួនក្នុងនាមជា ។ ចំពោះការសាងសង់ផ្ទះនេះ ត្រូវចំណាយអស់ប្រាក់ចំនួន ( និង ) ដុល្លារអាមេរិក ដោយគិតបញ្ចូលទាំងថ្លៃទិញសម្ភារៈទាំងអស់ និងចំណេះជំនាញដែលកូនក្តីខ្លួនមាន ក្នុងនាមជា ។ ប្រាក់ចំណាយក្នុងការសាងសង់ផ្ទះនេះ ជាប្រាក់ដែលរកបានក្នុងចំណងអាពាហ៍ពិពាហ៍ទាំងអស់ ហើយកូនក្តីខ្លួនសូមបដិសេធចោលទាំងស្រុងចំពោះលិខិតខ្ចីប្រាក់ដែលចុងចម្លើយខ្ចីពីឪពុករបស់ខ្លួន និងលិខិតខ្ចីប្រាក់ដែលចុងចម្លើយខ្ចីពីបងស្រីរបស់ខ្លួន ព្រោះវាគ្រាន់តែជាលិខិតឯកជនធម្មតា សន្លឹក ដែលគ្មានកាលបរិច្ឆេទស្នាម, គ្មានសាក្សី, គ្មានអាជ្ញាធរ ឬសាការីដឹងឮឡើយ ដូចនេះវាមិនមែនជាលិខិតយថាភូតដែលអាចយកមកធ្វើជាភស្តុតាងបន្ទាល់បានឡើយ ហើយលិខិតប្រភេទនេះអ្នកណាក៏អាចរៀបចំឡើងបានដែរ ដែលវាគ្មានតម្លៃជាភស្តុតាងដែលគួរឲ្យជឿទុកចិត្តសូម្បីតែបន្តិច។ ជាពិសេសជាងនេះទៅទៀត សូមលោកចៅក្រមមេត្តាកត់សម្គាល់ថា បើពិតជាមានការខ្ចីប្រាក់ពីឪពុក និងបងស្រីរបស់ចុងចម្លើយដើម្បីយកមកសាងសង់ផ្ទះនេះពិតប្រាកដមែន ហេតុអ្វីក៏គ្មានវត្តមានរបស់កូនក្តីខ្លួនចូលរួមខ្ចីជាមួយដែរ? ហើយការខ្ចីប្រាក់នេះមានដល់ទៅ លើក និងមានចំនួនសរុបយ៉ាងច្រើនដល់ទៅ ( ) ដុល្លារអាមេរិកឯណោះ! ដោយឡែក សូមក្រឡេកមើលទៅការខ្ចីប្រាក់ពីធនាគារ កាលពីថ្ងៃទី ខែ ឆ្នាំ ជាភស្តុតាងដែលចុងចម្លើយបានដាក់ជូនតុលាការពិនិត្យវិញម្តង ឃើញថាកម្ចីត្រឹមតែចំនួនទឹកប្រាក់ ( ) ដុល្លារអាមេរិក ប៉ុណ្ណោះក៏ចុងចម្លើយដាក់ឈ្មោះកូនក្តីខ្លួនឲ្យក្លាយជាអ្នកកម្ចីរួមគ្នាដែរ ចុះទម្រាំខ្ចីប្រាក់ពីឪពុក និងបងស្រីរបស់ខ្លួនយ៉ាងច្រើនសន្ធឹកសន្ធាប់បែបនេះ ចុះម្តេចមិនបបួលកូនខ្លួនឲ្យខ្ចីរួមគ្នាផង? នេះសបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថា តាមពិតគ្មានការខ្ចីប្រាក់ពិតប្រាកដឡើយ វាគ្រាន់តែជាលិខិតឯកជនមួយដែលចុងចម្លើយរៀបចំជាភស្តុតាងឡើងតែប៉ុណ្ណោះ។ ដូចនេះយើងឃើញថា រថយន្ត, ដី និងផ្ទះ ដូចដែលបានរៀបរាប់ខាងលើនេះ សុទ្ធតែជាទ្រព្យសម្បត្តិរួមរបស់កូនក្តីខ្លួន និងចុងចម្លើយស្របតាមមាត្រា

៩៧៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ហើយដោយសារតែជាទ្រព្យសម្បត្តិរួម កូនក្តីរបស់ខ្លួន និងចុងចម្លើយមានសិទ្ធិទទួលបានម្នាក់ៗ ១ ភាគ ២ នៃទ្រព្យសម្បត្តិរួម ដោយផ្អែកតាមមាត្រា៩៨០ កថាខណ្ឌ២ ចំណុចខ ស្តីពីការបែងចែកទ្រព្យសម្បត្តិរួមនៅពេលលែងលះគ្នា នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

សរុបមក កូនក្តីរបស់ខ្លួនមានសិទ្ធិទាមទារចំណែក ១ ភាគ ២ នៃដី និងថ្លៃចំណាយសរុបក្នុងការសាងសង់ផ្ទះខាងលើ ដោយស្របតាមច្បាប់ដែលនៅជាធរមាន។

៥-<u>អង្គហេតុដែលការអះអាងដោយចុងចម្លើយ</u>៖

ខ្លួនឯកភាពក្នុងការលែងលះពីដើមចោទ តែបដិសេធក្នុងការប្រគល់ការមានអំណាចមេបាលើកូនឱ្យទៅដើមចោទ។ ចុងចម្លើយបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នានូវរថយន្តម៉ាក TOYOTA HILUX ពណ៌ ផលិតឆ្នាំ សម្គាល់ដោយស្លាកលេខ ចុះថ្ងៃទី ខែ ឆ្នាំ ប៉ុន្តែចំពោះអចលនទ្រព្យ ខ្លួនមិនព្រមបែងចែកជាពីរចំណែកទេ ដោយសារទ្រព្យនេះជាកេរ្តិ៍ដែលឪពុកម្តាយខ្លួនប្រគល់ឱ្យខ្លួន។

៦-<u>សេចក្តីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយ</u>៖

អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា៖ កាលពីថ្ងៃទី ខែ ឆ្នាំ ដើមចោទបានដាក់ពាក្យបណ្តឹងលែងលះជាមួយកូនក្តីរបស់ខ្លួន និងសុំកំណត់យកអំណាចមេបាលើកូនមួយនាក់ និងបែងចែកទ្រព្យសម្បត្តិមានរថយន្តមួយគ្រឿង និងអចលនទ្រព្យមួយកន្លែង។ យោងតាមសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី ខែ ឆ្នាំ កូនក្តីរបស់ខ្លួនយល់ព្រមក្នុងការលែងលះជាមួយនឹងដើមចោទ។ យោងតាមសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី ខែ ឆ្នាំ របស់កូនឈ្មោះ កូនក្តីរបស់ខ្លួននៅតែទាមទារអំណាចមេបាដោយហេតុថា៖ ១.ដូចនឹងការអះអាងរបស់កូនក្តីខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្រោយពីការរស់នៅមិនចុះសម្រុង ដើមចោទបានចុះចាកចេញពីផ្ទះរយៈពេលជិតមួយឆ្នាំមកហើយ យោងតាមពាក្យបណ្តឹងចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ ដោយទុកឱ្យកូនក្តីនៅចិញ្ចឹមបីបាច់កូនតូចតែម្នាក់ឯង ហើយដើមចោទពុំដែលមកមើលកូន និងផ្តល់ជាសោហ៊ុយក្នុងការចិញ្ចឹមបីបាច់កូនឡើយ រហូតដល់ថ្ងៃនេះ។ ការអះអាងនេះក៏ត្រូវបានទទួលស្គាល់ពីដើមចោទនៅក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផងដែរ ហើយដើមចោទមកមើលកូនតែពីរដងគត់ក្នុងរយៈពេល២សប្តាហ៍ដំបូង ក្រោយពីចុះចាកចេញពីផ្ទះ។ ២.ដូចនឹងការអះអាងរបស់កូនក្តីខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើមចោទពុំមានមុខរបរដែលមានចំណូលទៀងទាត់ និងពុំមានទីស្នាក់អាស្រ័យជាអចិន្ត្រៃយ៍ឡើយ ដែលសព្វថ្ងៃស្នាក់នៅជាមួយឪពុកម្តាយនៅ ដោយឡែកកូនក្តីខ្លួនមានផ្ទះនៅទីប្រជុំជន និងមុខរបរនៅផ្ទះលក់គ្រឿងសំណង់ ដែលមានចំណូលយ៉ាងទៀងទាត់ជាប្រចាំថ្ងៃ។ ជាក់ស្តែងតាំងពីដើមចោទចុះចាកចេញពីផ្ទះរបស់កូនក្តីខ្លួនមក កូនក្តីខ្លួនពុំមានផលវិបាកណាមួយចំពោះកូនឡើយ ផ្ទុយទៅវិញក៏បានចិញ្ចឹមបីបាច់កូនមានសុខភាពល្អ និងបញ្ជូនកូនទៅសិក្សារៀនសូត្រនៅសាលារៀនជិតផ្ទះរស់នៅរាល់ថ្ងៃផងដែរ។ ការអះអាងនេះក៏ត្រូវបានទទួលស្គាល់ពីដើមចោទនៅក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដែរ។ ៣.ដូចនឹងការអះអាងរបស់កូនក្តីខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើមចោទក៏ធ្លាប់ធ្វើសកម្មភាពបោកប្រាស់ទ្រព្យសម្បត្តិនៅក្នុងផ្ទះ និងនៅចំពោះមុខកូនតូចផងដែរ ដែលជាមូលហេតុចម្បងមួយអាចនឹងធ្វើឱ្យប៉ះពាល់ដល់ការរស់នៅ និងផ្លូវចិត្តរបស់កូន។ ហេតុដូចនេះ កូនក្តីរបស់ខ្លួនស្នើសុំអំណាចមេបាលើកូន ដោយពុំទាមទារសោហ៊ុយអាហារកាតព្វកិច្ចអ្វីឡើយ។ ៤.ចំពោះរថយន្តមួយគ្រឿងម៉ាក TOYOTA HILUX ពណ៌ ផលិតឆ្នាំ យោងតាមកិច្ចសន្យាលក់ទិញរថយន្ត ចុះថ្ងៃទី ខែ ឆ្នាំ និងរូបភាពប្រតិបត្តិការផ្ញើប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ និងចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ កូនក្តីរបស់ខ្លួនយល់ព្រមបែងចែកជាពីរចំណែកស្មើគ្នា។ ហេតុដូចនេះ កូនក្តីរបស់ខ្លួនស្នើ

សុំបែងចែកជាពីរចំណែកស្មើគ្នាលើរថយន្តមួយគ្រឿងនេះតាមការព្រមព្រៀង។ ៥.ចំពោះអចលនវត្ថុទំហំ ម៉ែត្រការ៉េ ស្ថិតនៅភូមិ ឃុំ ស្រុក ខេត្ត យោងតាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ចុះថ្ងៃទី ខែ ឆ្នាំ ជាកម្មសិទ្ធិដោយឡែករបស់ឈ្មោះ និងលិខិតបញ្ជាក់ប្រវត្តិដី ចុះថ្ងៃទី ខែ ឆ្នាំ របស់ចៅសង្កាត់ កូនក្តីរបស់ខ្លួនពុំយល់ព្រមក្នុងការបែងចែកឡើយ ដោយហេតុថា អចលនវត្ថុនោះគឺជារបស់ឪពុកកូនក្តីខ្លួនដែលធ្វើអំណោយមកឱ្យកូនក្តីខ្លួន ហើយវាជាទ្រព្យសម្បត្តិដោយឡែក ដូចមានបញ្ជាក់ក្នុងភស្តុតាងខាងលើ។ នៅក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើមចោទក៏បានអះអាងថា ដើមចោទពុំបានធ្វើការទាមទារ និងទទួលស្គាល់ថាជាទ្រព្យសម្បត្តិដោយឡែករបស់កូនក្តីខ្លួនដែរ ប្រសិនបើកូនក្តីខ្លួនមានភស្តុតាងបង្ហាញ។ ដូចនឹងការអះអាងរបស់កូនក្តីខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចំពោះសំណង់ផ្ទះ គឺដើមចោទពុំដែលចេញប្រាក់ណាមួយយកមកសាងសង់ឡើយ គឺជាប្រាក់របស់កូនក្តីខ្លួនទៅខ្ចីគេមកសាងសង់ទាំងអស់ ដូចមានក្នុងភស្តុតាងកិច្ចសន្យា ចុះថ្ងៃទី ខែ ឆ្នាំ រវាងឈ្មោះ ឈ្មោះ និងធនាគារ និងលិខិតខ្ចីប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និងលិខិតខ្ចីប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ ។ បំណុលទាំងអស់ ដើមចោទពុំដែលធ្វើការសងប្រាក់ទៅម្ចាស់បំណុលមួយណាឡើយ គឺកូនក្តីខ្លួនជាអ្នកសងគេទាំងអស់ចំពោះប្រាក់ដែលខ្ចីយកមកសាងសង់ផ្ទះនេះ។ ចំពោះភស្តុតាងដែលដើមចោទបានដាក់មានពាក្យសុំអនុញ្ញាតសាងសង់ កិច្ចសន្យាសាងសង់ក្នុងតំបន់ពុំទាន់អភិវឌ្ឍន៍ កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន គំនូសប្លង់បង្ហាញទីតាំងដីសាងសង់ គឺសុទ្ធតែជាបែបបទរដ្ឋបាលក្នុងការសាងសង់ដោយពុំមានចំណាយប្រាក់ណាមួយឡើយ។ ផ្ទុយទៅវិញចំពោះសម្ភារៈសំណង់គ្រប់យ៉ាង គឺកូនក្តីខ្លួនជាអ្នកខ្ចីប្រាក់គេទៅទិញយកមកសាងសង់ទាំងអស់។ កូនក្តីខ្លួនសូមបដិសេធចំពោះភស្តុតាងតារាងតម្លៃសាងសង់ដែលរៀបចំវាយកុំព្យូទ័រជាឯកតោភាគីរបស់ដើមចោទ ដោយពុំមានការទទួលស្គាល់ពីភាគីណាមួយថាដើមចោទបានចំណាយប្រាក់ក្នុងតារាងនោះឡើយ។ ៧.ចំណុចសុំដោយតុលាការធ្វើការចាប់អារម្មណ៍ក្នុងការពិចារណា ដោយហេតុថាត្បិតកូនក្តីខ្លួនរៀបអាពាហ៍ពិពាហ៍ជាមួយដើមចោទពិតប្រាកដមែន ដូចនឹងការអះអាងរបស់កូនក្តីខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើមចោទពុំដែលផ្គត់ផ្គង់គ្រួសារឡើយ ដែលជាហេតុនាំឱ្យគ្រួសារបែកបាក់នេះ ជាក់ស្តែងមើលការទិញឡាន ក៏កូនក្តីរបស់ខ្លួនផ្ញើប្រាក់ផ្ទាល់ខ្លួនពីគណនីធនាគារផ្ទាល់ទៅកក់ក្រុមហ៊ុន និងផ្ញើទៅដើមចោទដើម្បីយកទៅបង់ឱ្យក្រុមហ៊ុនដែរ ពោលគឺកូនក្តីរបស់ខ្លួន និងដើមចោទទុកដាក់ប្រាក់រៀងខ្លួនតាំងពីដើមមក។ ប្រសិនបើដើមចោទពុំមានភស្តុតាងបញ្ជាក់អំពីការចំណាយប្រាក់ផ្ទាល់ខ្លួនក្នុងការសាងសង់ផ្ទះ ក្រៅពីតារាងតម្លៃសាងសង់ដែលរៀបចំវាយកុំព្យូទ័រឯកតោភាគីនោះទេ ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ រវាងឈ្មោះ ឈ្មោះ និងធនាគារ និងលិខិតខ្ចីប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និងលិខិតខ្ចីប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ

ពិតប្រភពប្រាក់ទាំងអស់ដែលយកមកសាងសង់ផ្ទះពិតប្រាកដមែន ហើយបំណុលទាំងអស់នេះ ក៏កូនក្តីខ្លួនធ្វើការសងប្រាក់ទៅម្ចាស់បំណុលតែម្នាក់ឯងដែរ។ ហេតុដូចនេះ កូនក្តីខ្លួនស្នើសុំឱ្យតុលាការប្រគល់អចលនវត្ថុទំហំ ម៉ែត្រការ៉េ ស្ថិតនៅ ឃុំ ស្រុក ខេត្ត យោងតាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ចុះថ្ងៃទី ខែ ឆ្នាំ ដែលជាកម្មសិទ្ធិដោយឡែករបស់ឈ្មោះ មកឱ្យកូនក្តីរបស់ខ្លួនតែម្នាក់ឯង។

៥-<u>អង្គហេតុដែលគូភាគីទទួលស្គាល់</u>៖ ការរៀបអាពាហ៍ពិពាហ៍, ការលែងលះ។

៦-<u>ចំណុចគ្មានវិវាទ</u>៖ ការលែងលះ។

៧-<u>ចំណុចវិវាទ</u>៖ ការមានអំណាចមេបា និងការបែងចែកទ្រព្យសម្បត្តិ។

## ការពិនិត្យភស្តុតាង

**១-ភស្តុតាងជាឯកសាររបស់ដើមចោទ៖**

១.១-អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

១.២-អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ របស់ឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

១.៣-សំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី ខែ ឆ្នាំ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ ស្រុក ខេត្ត របស់ឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

១.៤-បណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

១.៥-ពាក្យសុំអនុញ្ញាតសាងសង់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និងឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

១.៦-កិច្ចសន្យាសាងសង់ក្នុងតំបន់ពុំទាន់អភិវឌ្ឍន៍ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និង ឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

១.៧-កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និងឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

១.៨-គំនូសប្លង់បង្ហាញទីតាំងដីសាងសង់លំនៅឋានរបស់ឈ្មោះ និងឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

១.៩-តារាងតម្លៃសាងសង់ និងរូបភាពផ្ទះវីឡាដែលបានសាងសង់ (ថតចម្លង) ចំនួន០១ច្បាប់។

១.១០-គម្រោងសាងសង់លំនៅស្ថាន-ផ្ទះល្វែង (ប្លង់ស្ថាបត្យកម្ម និងគម្រោងអគារ, ប្លង់ប្រព័ន្ធបណ្តាញទឹកក្នុងអគារ និងប្លង់បណ្តាញអគ្គិសនីក្នុងអគារ (ថតចម្លង) ចំនួន០១ច្បាប់។

១.១១-បរិញ្ញាបត្ររបស់ឈ្មោះ ចេញដោយសាកលវិទ្យាល័យ ចុះថ្ងៃទី ខែ ឆ្នាំ (ថតចម្លង) ចំនួន០១ច្បាប់។

១.១២-តារាងផ្ទេរប្រាក់ និងវិក្កយបត្រផ្ទេរប្រាក់ពីធនាគារ ឱ្យទៅចុងចម្លើយ (ថតចម្លង) ចំនួន០៨ច្បាប់។

**២-ភស្តុតាងជាឯកសាររបស់ចុងចម្លើយ៖**

២.១-សំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និងឈ្មោះ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ ស្រុក ខេត្ត (ថតចម្លង) ចំនួន០១ច្បាប់។

២.២-សំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី ខែ ឆ្នាំ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ ស្រុក ខេត្ត របស់ឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

២.៣-ពាក្យបណ្តឹង ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

២.៤-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ ចេញដោយ ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត (ថតចម្លង) ចំនួន០១ច្បាប់។

២.៥-រូបភាពក្នុងប្រព័ន្ធសុរិយោដី (ថតចម្លង) ចំនួន០១ច្បាប់។

២.៦-បង្កាន់ដៃចុះបញ្ជីកម្មសិទ្ធិរបស់ឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

២.៧-លិខិតបញ្ជាក់ប្រវត្តិរូប ចុះថ្ងៃទី ខែ ឆ្នាំ ចេញដោយចៅសង្កាត់ (ថតចម្លង) ចំនួន០១ច្បាប់។

២.៨-កិច្ចសន្យាលក់ទិញរថយន្តរបស់ឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

២.៩-រូបភាពប្រតិបត្តិការផ្ញើប្រាក់ ចុះថ្ងៃទី និងថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ (ថតចម្លង) ចំនួន០៥ច្បាប់។

២.១០-កិច្ចសន្យាខ្ចីប្រាក់ (ឥណទានអាជីវកម្មខ្នាតតូច) របស់ឈ្មោះ ឈ្មោះ និងធនាគារ ចុះថ្ងៃទី ខែ ឆ្នាំ (ថតចម្លង) ចំនួន០១ច្បាប់។

២.១១-លិខិតខ្ចីប្រាក់របស់ឈ្មោះ (ថតចម្លង) ចំនួន០២ច្បាប់។

៣-ការសាកសួរសាក្សី៖ គ្មាន។

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា៖

១-ដើមចោទឈ្មោះ និងចុងចម្លើយឈ្មោះ បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី ខែ ឆ្នាំ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ ស្រុក ខេត្ត ដែលសមស្របតាមមាត្រា៩៥៥ នៃក្រមរដ្ឋប្បវេណី។

២-ដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាក្នុងការលែងលះដោយមានការស្ម័គ្រចិត្តរៀងៗខ្លួន ដោយមូលហេតុការរស់នៅមិនចុះសម្រុងនឹងគ្នា ទើបបណ្តាលឱ្យអស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នាជាប្តីប្រពន្ធតទៅទៀត អាចឱ្យតុលាការជឿបានថា៖ គូភាគីពិតជាមានបំណងក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ប្រាកដមែន។ ហេតុនេះ គប្បីតុលាការពិចារណា និងសម្រេចតាមការព្រមព្រៀងរបស់គូភាគីដែលសមស្របទៅនឹងមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី។

៣-ការរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ ដើមចោទ និងចុងចម្លើយមានកូនម្នាក់ឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ ។ ដើមចោទសុំមានអំណាចមេបាលើកូន ប៉ុន្តែចុងចម្លើយបដិសេធ។ អ្នកតំណាងដោយអាណត្តិឱ្យដើមចោទបានលើកឡើងថា កូនក្តីខ្លួនជា មានការអប់រំ និងមានប្រាក់ចំណូលខ្ពស់ មានជីវភាពធូរធារ ដូចនេះកូនក្តីរបស់ខ្លួនមានលទ្ធភាព ឱ្យកូនចូលសិក្សាសាលាល្អ ផ្តល់សម្ភារៈផ្សេងៗដើម្បីបំពេញតាមតម្រូវការរបស់កូន និងមានក្រុមគ្រួសារជួយមើលថែរក្សា ជិតដល់គ្រប់ពេលវេលា ដែលអាចធានាបានពីសុខសុវត្ថិភាព ភាពកក់ក្តៅ និងក្លាយជាកូនល្អ ពលរដ្ឋល្អ និងមានអនាគតល្អ។ ជាពិសេសជាងនេះទៅទៀត កូនក្តីខ្លួនសូមអះអាងថា នឹងផ្តល់ពេលវេលាដ៏សប្បាយរីករាយដល់កូន ដោយនាំគាត់ទៅដើរ កម្សាន្តនៅរមណីយដ្ឋាននានានាពេលចុងសប្តាហ៍ ឬពេលសម្រាកពីការសិក្សារបស់កូន ដើម្បីឱ្យកូនរស់នៅក្នុងបរិយាកាសសប្បាយរីករាយ និងមានភាពកក់ក្តៅជាទីបំផុត។ ម្យ៉ាងវិញទៀត កូនក្តីខ្លួននឹងមិនទាមទារឱ្យចុងចម្លើយផ្តល់អាហារកាតព្វកិច្ចក្នុងការចិញ្ចឹមកូនអ្វីទាំងអស់ ក្នុងករណីយល់ព្រមប្រគល់សិទ្ធិអំណាចមេបាលើកូនមកឱ្យកូនក្តីខ្លួន។ ទាំងនេះបង្ហាញឱ្យឃើញពីលទ្ធភាព និងឆន្ទៈរបស់កូនក្តីខ្លួនដែលអាចផ្តល់ផលប្រយោជន៍ដល់កូនបានសព្វគ្រប់បែបយ៉ាង ស្របតាមស្មារតីនៃមាត្រា ១០៣៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីខាងលើ។ សរុបមក តុលាការអាចកំណត់យកកូនក្តីខ្លួនធ្វើជាអ្នកមានសិទ្ធិអំណាចមេបាលើកូនបាននៅក្រោយពេលលែងលះគ្នា ព្រោះកូនក្តីខ្លួនអាចផ្តល់នូវផលប្រយោជន៍ដល់កូនបានគ្រប់បែបយ៉ាង។ ចំណែក អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយបានលើកឡើងថា កាលពីថ្ងៃទី ខែ ឆ្នាំ ដើមចោទបានដាក់ពាក្យបណ្តឹងលែងលះជាមួយកូនក្តីរបស់ខ្លួន និងសុំកំណត់យកអំណាចមេបាលើកូនមួយនាក់ និងបែងចែកទ្រព្យសម្បត្តិមានរថយន្តមួយគ្រឿង និងអចលនទ្រព្យមួយកន្លែង។ យោងតាមសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី ខែ ឆ្នាំ

កូនក្តីរបស់ខ្លួនយល់ព្រមក្នុងការលែងលះជាមួយនឹងដើមចោទ។ យោងតាមសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី ខែ ឆ្នាំ របស់កូនឈ្មោះ កូនក្តីរបស់ខ្លួននៅតែទាមទារអំណាចមេបាដោយហេតុថា៖ ១.ដូចនឹងការអះអាងរបស់កូនក្តីខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្រោយពីការរស់នៅមិនចុះសម្រុង ដើមចោទបានចុះចាកចេញពីផ្ទះរយៈពេលជិតមួយឆ្នាំមកហើយ យោងតាមពាក្យបណ្តឹងចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ ដោយទុកឱ្យកូនក្តីនៅចិញ្ចឹមបីបាច់កូនតូចតែម្នាក់ឯង ហើយដើមចោទពុំដែលមកមើលកូន និងផ្តល់ជាសោហ៊ុយក្នុងការចិញ្ចឹមបីបាច់កូនឡើយ រហូតដល់ថ្ងៃនេះ។ ការអះអាងនេះក៏ត្រូវបានទទួលស្គាល់ពីដើមចោទនៅក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផងដែរ ហើយដើមចោទមកមើលកូនតែពីរដងគត់ក្នុងរយៈពេល២សប្តាហ៍ដំបូង ក្រោយពីចុះចាកចេញពីផ្ទះ។ ២.ដូចនឹងការអះអាងរបស់កូនក្តីខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើមចោទពុំមានមុខរបរដែលមានចំណូលទៀងទាត់ និងពុំមានទីស្នាក់អាស្រ័យជាអចិន្ត្រៃយ៍ឡើយ ដែលសព្វថ្ងៃស្នាក់នៅជាមួយឪពុកម្តាយនៅខេត្ត ដោយឡែកកូនក្តីខ្លួនមានផ្ទះនៅទីប្រជុំជន និងមុខរបរនៅផ្ទះលក់គ្រឿងសំណង់ ដែលមានចំណូលយ៉ាងទៀងទាត់ជាប្រចាំថ្ងៃ។ ជាក់ស្តែងតាំងពីដើមចោទចុះចាកចេញពីផ្ទះរបស់កូនក្តីខ្លួនមក កូនក្តីខ្លួនពុំមានផលវិបាកណាមួយចំពោះកូនឡើយ ផ្ទុយទៅវិញក៏បានចិញ្ចឹមបីបាច់កូនមានសុខភាពល្អ និងបញ្ជូនកូនទៅសិក្សារៀនសូត្រនៅសាលារៀនជិតផ្ទះរស់នៅរាល់ថ្ងៃផងដែរ។ ការអះអាងនេះក៏ត្រូវបានទទួលស្គាល់ពីដើមចោទនៅក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដែរ។ ៣.ដូចនឹងការអះអាងរបស់កូនក្តីខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើមចោទក៏ធ្លាប់ធ្វើសកម្មភាពបោកប្រាស់ទ្រព្យសម្បត្តិនៅក្នុងផ្ទះ និងនៅចំពោះមុខកូនតូចផងដែរ ដែលជាមូលហេតុចម្បងមួយអាចនឹងធ្វើឱ្យប៉ះពាល់ដល់ការរស់នៅ និងផ្លូវចិត្តរបស់កូន។ ហេតុដូចនេះ កូនក្តីរបស់ខ្លួនស្នើសុំអំណាចមេបាលើកូន ដោយពុំទាមទារសោហ៊ុយអាហារកាតព្វកិច្ចអ្វីឡើយ។ ហេតុនេះ គប្បីតុលាការពិចារណា និងសម្រេចតាមបញ្ញត្តិមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី។

៤-អំឡុងពេលរួមរស់ជាមួយគ្នា ដើមចោទ និងចុងចម្លើយមានទ្រព្យសម្បត្តិរួមដូចជា៖ ១. រថយន្តម៉ាក TOYOTA HILUX ពណ៌ ផលិតឆ្នាំ សម្គាល់ដោយស្លាកលេខ ចុះថ្ងៃទី ខែ ឆ្នាំ ដែលមានឈ្មោះ និង ២.អចលនទ្រព្យមានដី និងផ្ទះទំហំ x ម៉ែត្រការ៉េ លេខក្បាលដី សម្គាល់ដោយគំនូសបង្ហាញទីតាំងដីសាងសង់លំនៅឋាន ចុះថ្ងៃទី ខែ ឆ្នាំ មានទីតាំងស្ថិតនៅផ្លូវជាតិលេខ ភូមិ ឃុំ ស្រុក ខេត្ត ។ ចំពោះរថយន្តម៉ាក TOYOTA HILUX ពណ៌ ផលិតឆ្នាំ សម្គាល់ដោយស្លាកលេខ គូភាគីឯកភាពក្នុងបែងចែកជាពីរចំណែកស្មើគ្នា។ ចំណែកឯ អចលនទ្រព្យមានផ្ទះ និងដីទំហំ x ម៉ែត្រការ៉េ លេខក្បាលដី សម្គាល់ដោយគំនូសបង្ហាញ ទីតាំងដីសាងសង់លំនៅឋាន ចុះថ្ងៃទី ខែ ឆ្នាំ មានទីតាំងស្ថិតនៅផ្លូវជាតិលេខ ភូមិ ឃុំ ស្រុក ខេត្ត ដើមចោទស្នើសុំធ្វើការបែងចែកជាពីរចំណែកស្មើគ្នា ប៉ុន្តែចុងចម្លើយមិនឯកភាពក្នុងការបែងពីរទ្រព្យនេះជាពីរចំណែកស្មើគ្នាទេ។ អ្នកតំណាងដោយអាណត្តិឱ្យដើមចោទបានលើកឡើងថា កូនក្តីខ្លួនបានប្រគល់ប្រាក់ចំនួន ( ) ដុល្លារអាមេរិក ឱ្យទៅលោក ជាឪពុកបង្កើតរបស់ចុងចម្លើយ ដើម្បីជាថ្នូរនឹងការធ្វើអំណោយដីខាងលើមកឱ្យកូនក្តីខ្លួន និងចុងចម្លើយ។ ការលើកឡើងនេះមិនមានភស្តុតាងដើម្បីឱ្យតុលាការពិនិត្យនោះទេ ហេតុនេះ គប្បីតុលាការមិនលើកយកចំណុចនេះមកពិចារណា និងសម្រេចឡើយ។ ដើមចោទបានផ្ទេរប្រាក់សុទ្ធចំនួន ( ) ដុល្លារអាមេរិក ឱ្យទៅចុងចម្លើយតាមរយៈធនាគារ ដើម្បីធ្វើការសាងសង់ផ្ទះ ដូចមាននៅក្នុងតារាងផ្ទេរប្រាក់ និងវិក្កយបត្រផ្ទេរប្រាក់ពីធនាគារឱ្យទៅចុងចម្លើយ (ថតចម្លង) ចំនួន០៨ច្បាប់។ ចំណុចនេះ គប្បីតុលាការលើកយកមកពិចារណា និងសម្រេចតាមមាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី។ ចំពោះប្រាក់លក់ដីចំការនៅខេត្តកោះកុង បានចំនួន ( ) ដុល្លារអាមេរិក

ដើមចោទបានប្រគល់ឱ្យចុងចម្លើយដោយផ្ទាល់ ដើមចោទមិនមានភស្តុតាងដាក់ជូនឱ្យតុលាការពិនិត្យនោះទេ ហេតុនេះ គប្បីតុលាការមិនលើកយកចំណុចនេះមកពិចារណា និងសម្រេចឡើយ។ ចំណែក អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ បានលើកឡើងថា ចំពោះអចលនវត្ថុទំហំ ម៉ែត្រការ៉េ ស្ថិតនៅភូមិ ឃុំ ស្រុក ខេត្ត យោងតាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ចុះថ្ងៃទី ខែ ឆ្នាំ ជាកម្មសិទ្ធិដោយឡែករបស់ឈ្មោះ និងលិខិតបញ្ជាក់ប្រវត្តិដី ចុះថ្ងៃទី ខែ ឆ្នាំ របស់ចៅសង្កាត់ កូនក្តីរបស់ខ្លួនពុំយល់ព្រមក្នុងការបែងចែកឡើយ ដោយហេតុថា អចលនវត្ថុនោះគឺជារបស់ឪពុក កូនក្តីខ្លួនដែលធ្វើអំណោយមកឱ្យកូនក្តីខ្លួន ហើយវាជាទ្រព្យសម្បត្តិដោយឡែក ដូចមានបញ្ជាក់ក្នុងភស្តុតាងខាងលើ។ នៅក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើមចោទក៏បានអះអាងថា ដើមចោទពុំបានធ្វើការទាមទារ និងទទួលស្គាល់ថាជាទ្រព្យសម្បត្តិដោយឡែករបស់កូនក្តីខ្លួនដែរ ប្រសិនបើកូនក្តីខ្លួនមានភស្តុតាងបង្ហាញ។ ដូចនឹងការអះអាងរបស់កូន ក្តីខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចំពោះសំណង់ផ្ទះ គឺដើមចោទពុំដែលចេញប្រាក់ណាមួយយកមកសាងសង់ឡើយ គឺជាប្រាក់របស់កូនក្តីខ្លួនទៅខ្ចីគេមកសាងសង់ទាំងអស់ ដូចមានក្នុងភស្តុតាងកិច្ចសន្យា ចុះថ្ងៃទី ខែ ឆ្នាំ រវាងឈ្មោះ ឈ្មោះ និងធនាគារ និងលិខិតខ្ចីប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និងលិខិតខ្ចីប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ ។ បំណុលទាំងអស់ ដើមចោទពុំដែលធ្វើការសងប្រាក់ទៅម្ចាស់បំណុលមួយណាឡើយ គឺកូនក្តីខ្លួនជាអ្នកសងគេទាំងអស់ចំពោះប្រាក់ ដែលខ្ចីយកមកសាងសង់ផ្ទះនេះ។ ចំពោះភស្តុតាងដែលដើមចោទបានដាក់មានពាក្យសុំអនុញ្ញាតសាងសង់ កិច្ចសន្យាសាងសង់ ក្នុងតំបន់ពុំទាន់អភិវឌ្ឍន៍ កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន គំនូសប្លង់បង្ហាញទីតាំងដីសាងសង់ គឺសុទ្ធតែជាបែបបទរដ្ឋបាលក្នុងការសាងសង់ដោយពុំមានចំណាយប្រាក់ណាមួយឡើយ។ ផ្ទុយទៅវិញចំពោះសម្ភារៈសំណង់គ្រប់យ៉ាង គឺកូនក្តីខ្លួនជាអ្នកខ្ចីប្រាក់ គេទៅទិញយកមកសាងសង់ទាំងអស់។ កូនក្តីខ្លួនសូមបដិសេធចំពោះភស្តុតាងតារាងតម្លៃសាងសង់ដែលរៀបចំវាយកុំព្យូទ័រ ជាឯកតោភាគីរបស់ដើមចោទ ដោយពុំមានការទទួលស្គាល់ពីភាគីណាមួយថាដើមចោទបានចំណាយប្រាក់ក្នុងតារាងនោះឡើយ។ ដោយហេតុថាត្បិតកូនក្តីខ្លួនរៀបអាពាហ៍ពិពាហ៍ជាមួយដើមចោទពិតប្រាកដមែន ដូចនឹងការអះអាងរបស់កូនក្តីខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើមចោទពុំដែលផ្គត់ផ្គង់គ្រួសារឡើយ ដែលជាហេតុនាំឱ្យគ្រួសារបែកបាក់នេះ ជាក់ស្តែងមើលការទិញឡាន ក៏កូនក្តីរបស់ខ្លួនផ្ញើប្រាក់ផ្ទាល់ខ្លួនពីគណនីធនាគារផ្ទាល់ទៅកក់ក្រុមហ៊ុន និងផ្ញើទៅដើមចោទដើម្បីយកទៅបង់ឱ្យក្រុមហ៊ុនដែរ ពោលគឺកូនក្តីរបស់ខ្លួន និងដើមចោទទុកដាក់ប្រាក់រៀងខ្លួនតាំងពីដើមមក។ ប្រសិនបើដើមចោទពុំមានភស្តុតាងបញ្ជាក់អំពីការចំណាយប្រាក់ផ្ទាល់ខ្លួនក្នុងការសាងសង់ផ្ទះ ក្រៅពីតារាងតម្លៃសាងសង់ដែលរៀបចំវាយកុំព្យូទ័រឯកតោភាគីនោះទេ ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ រវាងឈ្មោះ ឈ្មោះ និងធនាគារ និងលិខិតខ្ចីប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និងលិខិតខ្ចីប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ

ពិតប្រភពប្រាក់ទាំងអស់ដែលយកមកសាងសង់ផ្ទះពិតប្រាកដមែន ហើយបំណុលទាំងអស់នេះ ក៏កូនក្តីខ្លួនធ្វើការសងប្រាក់ទៅម្ចាស់បំណុលតែម្នាក់ឯងដែរ។ ហេតុដូចនេះ កូនក្តីខ្លួនស្នើសុំឱ្យតុលាការប្រគល់អចលនវត្ថុទំហំ ម៉ែត្រការ៉េ ស្ថិតនៅភូមិ ឃុំ ស្រុក ខេត្ត យោងតាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ចុះថ្ងៃទី ខែ ឆ្នាំ ដែលជាកម្មសិទ្ធិដោយឡែករបស់ឈ្មោះ មកឱ្យកូនក្តីរបស់ខ្លួនតែម្នាក់ឯង។ ហេតុនេះ គប្បីតុលាការពិចារណា និងសម្រេចតាមមាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី។

៥-ប្រាក់ប្រដាប់ក្តីគប្បីអនុវត្តតាមមាត្រា៦៤ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

<u>**សេចក្ដីសម្រេចបញ្ចប់**</u>

១-ឲ្យដើមចោទឈ្មោះ និងចុងចម្លើយឈ្មោះ បានលែងលះគ្នា។

២-ឲ្យចុងចម្លើយឈ្មោះ មានអំណាចមេបាលើកូនឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ ។ ភាគីដែលមិនមានអំណាចមេបាលើកូនមានសិទ្ធិជួបប្រាស្រ័យទាក់ទង និងសួរសុខទុក្ខជាមួយកូនបានជាធម្មតា។

៣-ប្រគល់អចលនទ្រព្យមាន៖ ដីទំហំ ( ) ម៉ែត្រការ៉េ និងផ្ទះទំហំ x ម៉ែត្រការ៉េ លេខក្បាលដី សម្គាល់ដោយតំនួសបង្ហាញទីតាំងដីសាងសង់លំនៅឋាន ចុះថ្ងៃទី ខែ ឆ្នាំ មានទីតាំងស្ថិតនៅផ្លូវជាតិលេខ ភូមិ ឃុំ ស្រុក ខេត្ត ឲ្យទៅចុងចម្លើយជាអ្នកគ្រប់គ្រង។

៤-ប្រគល់ប្រាក់ចំនួន ( ) ដុល្លារអាមេរិក ឲ្យទៅដើមចោទ។

៥-បែងចែកទ្រព្យសម្បត្តិរួមមាន រថយន្តម៉ាក TOYOTA HILUX ពណ៌ ផលិតឆ្នាំ សម្គាល់ដោយស្លាកលេខ ភ្នំពេញ ចុះថ្ងៃទី ខែ ឆ្នាំ ឲ្យទៅដើមចោទឈ្មោះ និងចុងចម្លើយឈ្មោះ ជាពីរចំណែកស្មើគ្នា។

៦-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ខែ ឆ្នាំ និងប្រកាសជាសាធារណៈនៅថ្ងៃទី ខែ ឆ្នាំ ។ **គូភាគីមានសិទ្ធិប្ដឹងឧទ្ធរណ៍តាមច្បាប់កំណត់។**

ថ្ងៃ ខែ ឆ្នាំ ព.ស.

**រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ**

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា៖ **ស សំណាង**

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ ខែ ឆ្នាំ ព.ស.

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

**ស_សំណាង**

**រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ**

**ក្រឡាបញ្ជី**

ហ៊ិន សក្កដា

សាលាដំបូងរាជធានីភ្នំពេញ

លេខ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## <u>លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រម</u>

**យើង គឹក ស្រីមុំ ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញ មាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម នស/រកម/០៧០៦/២១ ចុះថ្ងៃទី ០៦.០៧.២០០៦ ។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូង រាជធានីភ្នំពេញ ។

-បានឃើញ សាលក្រមលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ពាក្យសុំចុះថ្ងៃទី ខែ ឆ្នាំ របស់មេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ដែលមានខ្លឹមសារសុំលិខិតបញ្ជាក់ការចូលស្ថាពរ នៃសាលក្រមលេខ ចុះថ្ងៃទី ខែធ្នូ ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សេចក្តីអនុញ្ញាត ចុះថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ប្រធានសាលាដំបូងរាជធានីភ្នំពេញ។

## <u>សូមបញ្ជាក់ថា</u>

១/សាលក្រមលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ បានចូលជា ចាប់ពីថ្ងៃទី ខែ ឆ្នាំ រួចហើយ ។

២/លិខិតបញ្ជាក់ការចូលស្ថាពរនៃសាលក្រមនេះ ចេញឲ្យសាមីខ្លួន ដើម្បីយកទៅប្រើប្រាស់តាមផ្លូវច្បាប់ ។

ថ្ងៃ ខែ ឆ្នាំ ព.ស

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ

**ក្រឡាបញ្ជី**

គឹក. ស្រីមុំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ
ចូល លេខ ........
ថ្ងៃទី ខែ ឆ្នាំ
ម៉ោង

# ពាក្យបណ្តឹងឧទ្ធរណ៍

ខ្ញុំបាទ កើតនៅថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី ខែ ឆ្នាំ មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះលេខ១៧៨ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ទូរស័ព្ទលេខ៖ ។

**សូមគោរពជូន**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

*សូមទានជ្រាប។*

**កម្មវត្ថុ** ៖ សុំប្តឹងឧទ្ធរណ៍ចំពោះសាលក្រមរដ្ឋប្បវេណីលេខ៖ **ចុះថ្ងៃទី ខែ ឆ្នាំ** របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់សេចក្តីសម្រេចបញ្ចប់**ចំណុច ២** និងចំណុចដែលតុលាការមិនបានសម្រេចសេចក្តីតាមការទាមទាររបស់ខ្ញុំបាទ ដែលទាក់ទងនឹងទ្រព្យដោយឡែកដូចបានរៀបរាប់ក្នុង **ចំណុច ២ នៃសេចក្តីថ្លែងការណ៍បន្ថែម** របស់លោក**មេធាវី** ចុះថ្ងៃទី ខែ ឆ្នាំ ។

**យោង** ៖ **សាលក្រមរដ្ឋប្បវេណីលេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ** របស់សាលាដំបូងរាជធានីភ្នំពេញ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី ខែ ឆ្នាំ សាលាដំបូងរាជធានីភ្នំពេញបានប្រកាស**សាលក្រមរដ្ឋប្បវេណីលេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ** ជាសាធារណៈ និងបានប្រគល់សាលក្រមនេះមកឱ្យខ្ញុំបាទ តាមរយៈមេធាវីតំណាងដោយអាណត្តិរបស់ខ្ញុំបាទ នៅថ្ងៃទី ខែ ឆ្នាំ ។

ដោយហេតុថា ខ្ញុំបាទមិនសុខចិត្តចំពោះសេចក្តីសម្រេចនៃសាលក្រមខាងលើនេះត្រង់**ចំណុច ២** ទាំងស្រុង និងចំណុចដែលតុលាការមិនបានសម្រេចសេចក្តីតាមការទាមទាររបស់ខ្ញុំបាទ ទាក់ទងនឹងទ្រព្យដោយឡែករបស់ខ្ញុំបាទ ដែលរួមមានសម្ភារៈ ដូចជា ក្អារពុម្ព, ទីប, ជន្ទល, ម៉ូទ័របុក, ម៉ូទ័រស្វាន, ម៉ាស៊ីនបង្ហាប់ និងសម្ភារៈសំណង់ផ្សេងទៀត ដូចដែលបានរៀបរាប់ក្នុង**ចំណុច ២ នៃសេចក្តីថ្លែងការណ៍បន្ថែម** របស់លោក**មេធាវី** (មេធាវីតំណាងដោយអាណត្តិរបស់ខ្ញុំបាទ) ចុះថ្ងៃទី ខែ ឆ្នាំ ។

សេចក្តីសម្រេចនេះ មានភាពអយុត្តិធម៌ និងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទ ហេតុដូច្នោះហើយ ទើបខ្ញុំបាទដាក់ពាក្យបណ្តឹងឧទ្ធរណ៍ចំពោះ**សាលក្រមរដ្ឋប្បវេណីលេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ** របស់សាលាដំបូងរាជធានីភ្នំពេញត្រង់សេចក្តីសម្រេចបញ្ចប់**ចំណុច ២** និងចំណុច

ដែលតុលាការមិនបានសម្រេចសេចក្តីតាមការទាមទាររបស់ខ្ញុំបាទ ដែលទាក់ទងនឹងទ្រព្យដោយឡែកដូចបាន រៀបរាប់ក្នុង**ចំណុច ២ នៃសេចក្តីថ្លែងការណ៍បន្ថែម** របស់លោក**មេធាវី** ចុះថ្ងៃទី ខែ ឆ្នាំ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់ខ្ញុំបាទ ខាងលើ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ៕

ថ្ងៃ ខែ ឆ្នាំ ព.ស

ថ្ងៃទី ខែ ឆ្នាំ

**ស្នាមមេដៃស្តាំ**

<u>ជូនភ្ជាប់មកជាមួយនូវ៖</u>

- សាលក្រមរដ្ឋប្បវេណីលេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ (ច្បាប់ថតចម្លង១ច្បាប់)។
- សេចក្តីថ្លែងការណ៍បន្ថែម ចុះថ្ងៃទី ខែ ឆ្នាំ របស់លោកមេធាវី (ច្បាប់ថតចម្លង១ច្បាប់)។